សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និសិត្សឈ្មោះ៖ **កញ្ញា រស់ វិច្ឆ័រ៉ា**

**កញ្ញា ហេង ម៉ាលីស**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំ **រស់ វិជ្ជរ៉ា** និង **ហេង ម៉ាលីស** ជានិស្សិតបរិញ្ញាបត្រ **នីតិសាស្ត្រ** ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៨ រហូតដល់ ឆ្នាំ២០២២។

**សូមគោរពលំអោនកាយវាចាចិត្ត សម្តែងលុះចមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

**លោកឪពុក រស់ សាម៉ន** | **លោកឪពុក ហេង គឹមឡេង**

**អ្នកម្តាយ សូ ចន្ថា** | **អ្នកម្តាយ ចត សុភាព**

ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅជួយទំនុកបម្រុងតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ លោកទាំងពីរបានព្យាយាមប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីឱ្យកូនៗមានអនាគត់ភ្លឺស្វាងរីកចម្រើន និងអភិវឌ្ឍខ្លួនក្លាយជាសិស្សល្អ និងពលរដ្ឋល្អក្នុងសង្គមជាតិ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង សមត្ថភាព ក៏ដូចជាការ ស្រាវជ្រាវក្នុងផ្នែកនីតិសាស្ត្រ នេះតាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ប្រកបដោយភាពជោគជ័យ ផ្លែផ្កា និងសមិទ្ធផលចំណេះដឹងយ៉ាងគាប់ប្រសើរ។

ឯកឧត្តម **លុយ ចន្ធ្នា** សាកលវិទ្យាការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងបានជួយជ្រោមជ្រែងតម្រង់ទិសយើងខ្ញុំ តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រដល់សព្វថ្ងៃ។

លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកគ្រូបានបង្ហាត់បង្ហាញនូវគំនិត ក៏ដូចជាវិធីសាស្ត្រជាច្រើននៅក្នុងការស្រាវជ្រាវនូវប្រធានបទមួយនេះ ដោយលោកគ្រូបានខិតខំ ចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយជ្រោមជ្រែងការស្រាវជ្រាវមួយនេះ តាំងពីដើមរហូតដល់បញ្ចប់។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ សូមធ្វើការអគុណ និងដឹងគុណម្តងទៀតដល់អ្នកមានគុណទាំងពួងដែលបានរៀបរាប់ខាងលើ សូមប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមក ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបាននូវចំណេះដឹងពីលោកលោកស្រីសាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលការអនុញ្ញាតិពីសាកលវិទ្យាល័យដើម្បីសរសេរ សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ «**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**» ។

ប្រធានបទមួយនេះ គឺកើតឡើងចេញពីចម្ងល់ និងការចង់ដឹងឲ្យកាន់តែស៊ីជម្រៅរបស់យើងខ្ញុំទៅលើកិច្ចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជន។ កិច្ចការស្រាវជ្រាវនេះ ផ្តោតសំខាន់ទៅ លើសិទ្ធិ និងករណីយកិច្ចរបស់អនីតិជនក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ ព្រមជាមួយនឹង នីតិវិធីអនុវត្តទៅលើអនីតិជន ដែលធ្វើយ៉ាងណាធានាដល់ឧត្តមប្រយោជន៍របស់អនីតិជន។ លើសពីនេះទៀត សារណាមួយនេះអាចលេចចេញជារូបរាងឡើងក៏ដោយសារមានការជួយជ្រោមជ្រែង ណែនាំ តម្រង់ទិសពីសំណាក់លោកសាស្ត្រាចារ្យ ជួន ប៊ុនធី ដែលលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗ សម្រាប់ជាពុទ្ធិដល់យើងខ្ញុំ ។

ថ្វីបើយើងខ្ញុំបានធ្វើការពិនិត្យផ្ទៀងផ្ទាត់រួចមកហើយ ក៏កំហុសឆ្គងនៅតែអាចនឹងកើត មានឡើងជាពុំខាន។ ដូចនេះ សូមធ្វើការអភ័យទោសនូវរាល់កំហុសឆ្គងដោយអចេតនាដែលអាចកើតមានឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយក៏រងចាំទទួលនូវការរិះគន់ និងការកែលម្អក្នុងន័យស្ថាបនា ដើម្បីអាចធ្វើឲ្យស្នាដៃបន្តបន្ទាប់ទៀតកាន់តែមាននូវភាពល្អប្រសើរឡើង។

ជាចុងបញ្ចប់ ក្នុងនាមយើងខ្ញុំជាអ្នករៀបរៀងសារណានេះ ក៏សង្ឃឹមថាឯកសារមួយនេះនឹងក្លាយជាប្រយោជន៍ និងជាវិភាគទាន ព្រមទាំងផ្តល់ជាចំណេះដឹងបន្ថែម សម្រាប់ជាគន្លឹះ និង ជំនួយ ស្មារតីដល់ប្អូនៗជំនាន់ក្រោយៗទៀតអាចធ្វើការសិក្សាស្រាវជ្រាវបន្តបាន។ ហើយយើងខ្ញុំទាំងពីររូបក៏សូមជូនពរដល់អស់លោកលោកស្រីដែលកំពុងអានសៀវភៅមួយនេះ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..................................................... ០១

**ជំពូកទី១**

**បទបញ្ញត្តិទូទៅ និងអានុភាពនៃការទទួលខុសត្រូវរបស់អនីតិជន**

**១.១ មូលសាស្ត្រ និងសិទ្ធិជាមូលដ្ឋាន** ..................................................... ០៤

១.១.១ មូលសាស្ត្រជាមូលដ្ឋានរបស់អនីតិជន ..................................................... ០៤

១.១.២ សិទ្ធិជាមូលដ្ឋានរបស់អនីតិជន ..................................................... ០៥

**១.២ លក្ខខណ្ឌនៃការអនុវត្តទោសចំពោះអនីតិជន** ..................................................... ០៧

១.២.១ នីតិភាពរបស់អនីតិជនក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ..................................................... ០៧

១.២.២ លក្ខខណ្ឌផ្សេងៗ ..................................................... ១១

**១.៣ មូលហេតុដែលបង្កឱ្យមានបទល្មើស** ..................................................... ១៤

**១.៤ កិច្ចការពារអនីតិជន** ..................................................... ១៥

**១.៥ ការរួចផុតពីការទទួលខុសត្រូវទោសព្រហ្មទណ្ឌ** ..................................................... ១៦

១.៥.១ មូលហេតុទាក់ទងនឹងនីតិភាព ..................................................... ១៧

១.៥.២ មូលហេតុទាក់ទងនឹងបទល្មើស ..................................................... ១៧

**ជំពូកទី២**

**នីតិវិធីរបស់ស្ថាប័នតុលាការក្នុងការអនុវត្តចំពោះអនីតិជន**

**២.១ ការបង្វែរអនីតិជនចេញពីការផ្តន្ទាទោស** ..................................................... ២០

២.១.១ គោលបំណង និងគោលការណ៍ក្នុងការបង្វែរ ..................................................... ២០

២.១.២ លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យក្នុងការបង្វែរ ..................................................... ២១

២.១.៣ ការរៀបចំបង្កើតផែនការបង្វែរ ..................................................... ២១

២.១.៤ ការអនុវត្តផែនការបង្វែរ ..................................................... ២២

២.១.៥ ការកែប្រែវិធានការបង្វែរ ..................................................... ២៣

២.១.៦ ការបរាជ័យនៃវិធានការបង្វែរ ..................................................... ២៣

**២.២ នីតិវិធីអនុវត្តចំពោះអនីតិជន** ..................................................... ២៣

២.២.១ ដំណាក់កាលនគរបាលយុត្តិធម៌ ........ ២៣

២.២.២ ដំណាក់កាលអយ្យការ ........ ២៦

២.២.៣ ដំណាក់កាលស៊ើបសួរ ........ ៣០

២.២.៤ ដំណាក់កាលជំនុំជម្រះ ........ ៣៤

## ជំពូកទី៣

## ទោសព្រហ្មទណ្ឌចំពោះអនីតិជន

**៣.១ ប្រភេទទោសដែលអនុវត្តចំពោះអនីតិជន** ........ ៣៩

៣.១.១ មូលទោស ........ ៣៩

៣.១.២ ទោសបន្ថែម ........ ៤០

៣.១.៣ ទោសសហគមន៍ ........ ៤១

**៣.២ ការអនុវត្តទោសចំពោះអនីតិជន** ........ ៤២

៣.២.១ ការអនុវត្តទោសពិន័យ ........ ៤៣

៣.២.២ ការអនុវត្តទោសដាក់ពន្ធនាគារ ........ ៤៤

៣.២.៣ ការអនុវត្តទោសក្នុងមណ្ឌលយុវនីតិសម្បទា ........ ៤៦

**៣.៣ ការដោះលែងដោយមានលក្ខខណ្ឌ** ........ ៤៨

៣.៣.១ ការដោះលែងដោយផ្អែកលើអត្តចរិក ........ ៤៨

៣.៣.២ ការដោះលែងតាមការស្នើសុំ ........ ៤៨

**៣.៤ ការស្តារនីតិសម្បទាឡើងវិញ** ........ ៤៩

៣.៤.១ ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ........ ៤៩

៣.៤.២ ការស្តារនីតិសម្បទាឡើងវិញតាមច្បាប់ ........ ៥០

**សេចក្តីសន្និដ្ឋាន** ........ ៥១

**អនុសាសន៍** ........ ៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅបណ្តាលរដ្ឋក្នុងសកលលោកយើងនេះ រដ្ឋនីមួយៗតែងតែមានការគ្រប់គ្រងខុសៗគ្នាទៅតាមរបបដឹកនាំនៃរដ្ឋនោះ ហើយដើម្បីឱ្យប្រទេសមួយមានសណ្តាប់ធ្នាប់ សុខសុវត្ថិភាព និងចៀសវាងពីភាពអាណាធិបតេយ្យ ភាពគ្មានរបៀបរៀបរយ អសន្តិសុខ និងធ្វើឱ្យខូចសណ្តាប់ធ្នាប់សង្គម ឬការប្រើប្រាស់សិទ្ធិរបស់ខ្លួនហួសកម្រិតដោយបំពានទៅអ្នកដទៃ។ ដូច្នេះហើយមេដឹកនាំប្រទេសនីមួយៗបានធ្វើការរៀបចំបង្កើតបទដ្ឋានគតិយុត្តមួយចំនួនក្នុងការគ្រប់គ្រងប្រទេស រួមទាំងមានវិធានការក្នុងការគ្រប់គ្រង ឬក៏ជានាសណ្តាប់ធ្នាប់រស់នៅរបស់ប្រជាពលរដ្ឋផងដែរ។ ដោយវិធានការខ្លះនោះបានកំណត់ឱ្យបុគ្គលដែលបានបង្កផលប៉ះពាល់ដល់អ្នកដទៃ ឬសង្គមជាតិខ្លួន ឬសង្គមជាតិបរទេស បុគ្គលទាំងនោះត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានបង្ក ដោយការទទួលខុសត្រូវនោះមានទាំងផ្នែកព្រហ្មទណ្ឌ ផ្នែករដ្ឋប្បវេណី ចំពោះជនរងគ្រោះ ឬរដ្ឋដែលរងគ្រោះជាដើម។ ចំណែកឯប្រទេសមួយចំនួនទៀត ដែលមានការរីកចម្រើនគ្រប់វិស័យដូចជាវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម និងវិស័យអប់រំជាដើម និងសម្បូរទៅដោយធនធានសម្បត្តិធម្មជាតិជាច្រើន ដូច្នេះហើយប្រទេសទាំងនោះមិនមានការទាមទារច្រើនក្នុងការទទួលខុសត្រូវនោះទេ។ ចំពោះអំពើមួយចំនួនមិនតម្រូវឱ្យមានការទទួលខុសត្រូវនោះទេ ប្រសិនបើអំពើនោះមិនបង្កលក្ខណៈឱ្យមានការខូចខាតធ្ងន់ធ្ងរ រដ្ឋទាំងនោះមិនចាត់ទុកជាអំពើដែលច្បាប់បានហាមឃាត់ ហើយក៏មិនតម្រូវឱ្យមានការទទួលខុសត្រូវចំពោះអំពើនោះផងដែរ។

ចំណែកឯច្បាប់នៅព្រះរាជាណាចក្រកម្ពុជា តាមគោលការណ៍ទូទៅ នៃនីតិព្រហ្មទណ្ឌ នៅពេលដែលមានបទល្មើសណាមួយកើតឡើង ត្រូវតែមានបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះបទល្មើសនោះ មិនថាបុគ្គលជានីតិជនក្តី (សំដៅលើជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើង) ឬអនីតិជនក្តី (សំដៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ) គឺតម្រូវឱ្យមានការទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីចំពោះជនរងគ្រោះ ឬការដាក់ទណ្ឌកម្មផ្សេងៗតាមរយៈការដាក់ពន្ធនាគារ ដើម្បីយកមកអប់រំណែនាំឱ្យដឹងពីកំហុសខ្លួន និងបន្ទាប់ពីអនុវត្តទោសរួចហើយនឹងបញ្ចូលជននោះទៅរស់នៅក្នុងសង្គមវិញ ដើម្បីធ្វើជាពលរដ្ឋល្អដែលមានប្រយោជន៍សម្រាប់សង្គម គ្រួសារ មិត្តភក្តិជាដើម។ មួយវិញទៀត យើងដឹងហើយថាអនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ហើយអនីតិជនជាទូទៅតែងតែមានការការពារពីអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលអនុសញ្ញានេះតម្រូវឱ្យរដ្ឋដែលជាភាគីត្រូវកំណត់អំពីកម្រិតអាយុអប្បបរមា នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ។ មានន័យថាកុមារដែលមានអាយុក្រោមអប្បបរមានេះ ត្រូវបានសន្មតជាមុនថាពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសឡើយ។

សមត្ថភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្ស នៅពេលដែលបានប្រព្រឹត្ត អំពើគ្រោះថ្នាក់ដល់សង្គម ហើយជននោះយល់ដឹងអំពីចរិតគ្រោះថ្នាក់ នៃអំពើរបស់ខ្លួន នឹងអាចបញ្ជានូវរាល់ អំពើទាំងនោះបាន។ រូបវន្តបុគ្គលដែលត្រូវបានចាត់ទុកថាមានសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើពេលប្រព្រឹត្តអំពើគ្រោះថ្នាក់ដល់សង្គម ហើយជននោះបានឈានដល់កម្រិតអាយុ នៃការទទួលខុស ត្រូវព្រហ្មទណ្ឌ។ ហើយការកំណត់កម្រិតអាយុ នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះនឹងបង្កើតបានទៅជាមូល ដ្ឋានផ្នែកគតិយុត្តមួយសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជន។ សម្រាប់អនីតិជននៅកម្ពុជា ច្បាប់ក៏បានកំណត់វិធានពិសេសមួយចំនួនចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស ដោយវិធានពិសេស បានកំណត់អំពីអនុវត្តច្បាប់ចំពោះអនីតិជនដូចជាលក្ខខណ្ឌ នីតិវិធី ការដាក់ទណ្ឌកម្មជាដើមក្នុងការទទួល ខុសត្រូវចំពោះមុខច្បាប់។

## ១. ចំណោទបញ្ហា

ជាគោលការណ៍ស្របតាមអនុសញ្ញាអន្តរជាតិ អនីតិជនតែងតែមានការការពារពីប្រព័ន្ធគតិយុត្តទាំងចំពោះ សិទ្ធិសេរីដោយមិនមានការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសំអាងថាអនីតិជននោះមិនទាន់យល់ដឹង ពីភាពគ្រោះថ្នាក់ នៃអំពើរបស់ខ្លួន។ ម៉្យាងទៀតចំពោះអនីតិជន នៅក្នុងប្រទេសកម្ពុជាពេលប្រព្រឹត្តបទល្មើសពិត ជាមិនទទួលខុសត្រូវចំពោះការខូតខាតនោះមែនទេ? ហើយបើមានការការទទួលខុសត្រូវ តើការអនុវត្តនីតិវិធី និងទណ្ឌកម្មចំពោះអនីតិជនមានលក្ខណៈដូចម្តេច ឬក៏អនុវត្តដូចទៅនឹងនីតិជន? ដោយសារមានបញ្ហាចោទជា ច្រើនទាក់ទងនឹងអនីតិជននៅពេលបានប្រព្រឹត្តបទល្មើស ដូនេះហើយការស្រាវជ្រាវចំពោះប្រធានបទ៖ **ការ ទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន** ត្រូវបានជ្រើសរើស ដើម្បីបកស្រាយនូវចម្ងល់ នឹងបង្ហាញឱ្យ សាធារណៈជនក៏ដូចជានិស្សិតយើងដឹងថា តើនៅពេលដែលអនីតិជនដែលបានប្រព្រឹត្តបទល្មើស ពិតជាត្រូវ ទទួលខុសត្រូវចំពោះមុខច្បាប់ដែរឬទេ? ហើយបើមានការទទួលខុសត្រូវ តើនីតិវិធី និងទណ្ឌកម្មត្រូវអនុវត្តយ៉ាងដូច ម្តេច?

## ២. គោលបំណងស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវ និងធ្វើការចងក្រងនូវឯកសារនេះឡើង ក្នុងគោលបំណងឱ្យនិស្សិត និង សាធារណៈជន ដែលមានបំណងចង់ឈ្វេងយល់ពីប្រធានបទនេះកាន់តែច្បាស់ អាចមានឯកសារក្នុង ការសិក្សា និងចង់បង្ហាញឱ្យដឹងថាការប្រព្រឹត្តអំពើខុសច្បាប់ត្រូវតែមានការទទួលខុសចំពោះមុខច្បាប់មិន លើកលែងសូម្បីអនីតិជនក៏ដោយ ដូច្នេះហើយយើងទាំងអស់គ្នាគប្បីគោរពបទបញ្ញត្តិនៅក្នុងប្រទេសឱ្យ បានត្រឹមត្រូវ និងភ្ជាប់ភ្ជួន ដើម្បីឱ្យសង្គមយើងប្រកបទៅដោយចីរភាព។

## ៣. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ ដែលបានលើកឡើងក្នុងចំណោទបញ្ហាខាងលើនេះ សារណានេះត្រូវបានធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារជាមូលដ្ឋានដែលមានដូចជា ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ សៀវភៅនីតិព្រហ្មទណ្ឌទូទៅ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន អនុសញ្ញាស្តីពីសិទ្ធិកុមារ និងឯកសារបទដ្ឋានគតិយុត្តិផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអនីតិជន។

នៅក្នុងការសរសេរសារណានេះ គឺលើកឡើងតែពីការពាក់ព័ន្ធទាំងឡាយណាដែលទាក់ទងជាមួយនឹងការទទួលខុសត្រូវរបស់អនីតិជន នីតិវិធី និងទណ្ឌកម្មដែលត្រូវយកមកអនុវត្តចំពោះអនីតិជនតែប៉ុណ្ណោះ។

## ៤. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ការសរសេរសារណានេះ ត្រូវបានធ្វើការសិក្សាបែបពិពណ៌នា ហើយតាមរយៈ នៃការសិក្សាស្រាវជ្រាវនេះដែរ គឺត្រូវបានធ្វើឡើងតាមរយៈការប្រមូលទិន្នន័យ និងព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងប្រធានបទសារណានេះពីស្ថាប័នមានសមត្ថកិច្ច ដើម្បីធ្វើឱ្យខ្លឹមសារនៃសារណានេះមានភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពកាន់តែច្បាស់។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះនឹងផ្តល់ឱ្យបងប្អូននិស្សិត ក៏ដូចជាសាធារណៈជនដទៃទៀតទុកជាឯកសារជំនួយស្មារតី និងជាចំណេះដឹងបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់ខ្លួន និងយល់ដឹងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនថាតើមានភាពដូចគ្នា ឬខុសគ្នាយ៉ាងដូចម្តេចទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន ក៏ដូចជាលក្ខខណ្ឌផ្សេងៗ នៃការទទួលខុសត្រូវព្រហ្មទណ្ឌ នីតិវិធីសម្រាប់អនុវត្តចំពោះអនីតិជន និងទណ្ឌកម្មសម្រាប់អនុវត្តលើអនីតិជនតាមដំណាក់កាលនីមួយៗ។

សារណានេះបានបញ្ចូលបន្ថែមនូវឯកសារផ្លូវការដែលមានអត្ថប្រយោជន៍ និងអាចជឿជាក់បានមួយចំនួនដើម្បីទុកជាឧទាហរណ៍ជាក់ស្តែងឱ្យសាធារណៈជន ដែលមានចំណាប់អារម្មណ៍ចង់សិក្សាស្រាវជ្រាវងាយយល់។ ឯកសារទាំងនឹងធ្វើការចងក្រងនៅផ្នែកឧបសម្ព័ន្ធ ដើម្បីងាយស្រួលក្នុងការស្វែករក។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ ត្រូវបានធ្វើការបែកចែកជាបីជំពូកៈ

ជំពូកទី១ ៖ បទបញ្ញត្តិទូទៅ និងអាទានភាព នៃការទទួលខុសត្រូវរបស់អនីតិជន

ជំពូកទី២ ៖ នីតិវិធីរបស់ស្ថាប័នតុលាការក្នុងការអនុវត្តចំពោះអនីតិជន

ជំពូកទី៣ ៖ ទោសព្រហ្មទណ្ឌចំពោះអនីតិជន

# ជំពូកទី១
# បទបញ្ញត្តិទូទៅ និងអាទានភាព
# នៃការទទួលខុសត្រូវរបស់អនីតិជន

# ជំពូកទី១

# បទបញ្ញត្តិទូទៅ និងអាទានភាព នៃការទទួលខុសត្រូវរបស់អនីតិជន

## ១.១ មូលសាស្ត្រ និងសិទ្ធិជាមូលដ្ឋាន

យោងតាមគោលការណ៍រដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ បានកំណត់ឱ្យមនុស្សគ្រប់រូបមានសិទ្ធិនឹងសេរីភាព និងមានការទទួលស្គាល់សេចក្ដីថ្លៃថ្នូរជាប់ខ្លួនតាំងពីកំណើតដោយមិនអាចលក់ដូរ ដកហូតបានឡើយ។ ហើយចំពោះកុមារដែលជាក្រុមមនុស្សមានអាយុក្រោម ១៨ ឆ្នាំ ក៏ទទួលបានសិទ្ធិការពារតាំងពីកំណើតដូចគ្នាដែលគោលការណ៍ និងសិទ្ធិរបស់កុមារត្រូវបានកំណត់ដាច់ដោយឡែកតាមរយៈអនុសញ្ញាស្ដីពីសិទ្ធិកុមារ ហើយចំពោះការអនុវត្តក្នុងរដ្ឋជាភាគី នៃអនុសញ្ញានេះ រដ្ឋជាភាគីត្រូវរៀបចំសិទ្ធិរបស់កុមារស្របតាមអនុសញ្ញានេះរួមទាំងប្រពៃណី និងវប្បធម៌របស់ប្រជាជាតិនីមួយៗ ដើម្បីធានាឱ្យបាននូវការលើកកម្ពស់លក្ខខណ្ឌជីវភាពរបស់កុមារគ្រប់ប្រទេស ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាដែលជារដ្ឋមួយក្នុងចំណោមរដ្ឋភាគីនៃអនុសញ្ញានេះក៏បានធ្វើការកំណត់អំពីគោលការណ៍ និងសិទ្ធិរបស់កុមារជាទូទៅ និងគោលការណ៍ និងសិទ្ធិមូលដ្ឋានក្នុងករណីដែលអនីតិជននោះបានបង្កបទល្មើសផងដែរ ដូច្នេះហើយយើងនឹងលើកយកគោលការណ៍ជាមូលដ្ឋាន (១.១.១) និងសិទ្ធិជាមូលដ្ឋានរបស់កុមារ (១.១.២) ក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

### ១.១.១ មូលសាស្ត្រជាមូលដ្ឋាន

នៅក្នុងវិធានការទាំងអស់ ដែលពាក់ព័ន្ធនឹងកុមារ ត្រូវតែធានាថាផលប្រយោជន៍របស់កុមារត្រូវបានយកចិត្តទុកដាក់ជាចម្បង ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈទទួលភារៈខាងសុខុមាលភាពសង្គម ឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិ[1]។ ប្រសិនបើធ្វើដោយស្ថាប័នតុលាការ នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានភារកិច្ចក្នុងនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជនត្រូវគោរពគោលការណ៍ជាមូលដ្ឋានដែលធានាបាននូវផែនការជាក់លាក់សម្រាប់ដំណើរការ ដើម្បីឱ្យជីវិតអនីតិជនបានប្រសើរឡើង ដោយមានការយកចិត្តទុកដាក់ នឹងរក្សាឧត្ដមប្រយោជន៍របស់កុមារជាចម្បង។ ហើយប្រតិបត្តិការ នៃនីតិវិធីត្រូវប្រកបដោយមនុស្សធម៌ និងត្រូវផ្ដល់ឱកាសឱ្យកុមារក្នុងការសម្ដែងនូវមតិដោយសេរី ដើម្បីយកទស្សនទាំងនោះទៅវិនិច្ឆ័យ ពិចារណាថ្លឹងថ្លែង ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិត នៃការយល់ដឹងរបស់អនីតិជន ចំពោះសកម្មភាពរបស់ខ្លួន។ ចំពោះអត្តសញ្ញាណអនីតិជន មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព ឬព័ត៌មានទាំងឡាយ ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារ ក្នុងការទទួលបាននូវការអប់រំ

[1] មាត្រា ៣ កថាខណ្ឌទី១ នៃអនុសញ្ញាស្ដីពីសិទ្ធកុមារ ឆ្នាំ១៩៨៩

ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ប៉ុន្តែការផ្សព្វផ្សាយរឿងក្តីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ។ វិធានការឃុំឃាំង ការដាក់ពន្ធនាគារ គឺជាយុទ្ធនាការចុងក្រោយបង្អស់ក្នុងការអនុវត្តចំពោះអនីតិជន ដែលបានទំនាស់នឹងច្បាប់[2]។ ផែនការយុទ្ធសាស្ត្រទាំងនេះ ជាភាពចាំបាច់ដើម្បីការការពារពិសេសដល់កុមារ។

**១.១.២ សិទ្ធិជាមូលដ្ឋានរបស់កុមារ**

កុមារ គឺជាវ័យមួយដែលពុំអាចមានការពិចារណាអំពីការរក្សាផលប្រយោជន៍ខ្លួនបាននៅឡើយ ហើយក៏មិនអាចវិនិច្ឆ័យចំពោះទង្វើរបស់ខ្លួននោះទេ។ ដោយហេតុនេះបានជាមានកុមារជាច្រើន បានទទួលការគំរាមកំហែង រងគ្រោះដោយសារពាក្យបោកបញ្ឆោត នៃជនអាក្រក់មួយចំនួន ឬប្រព្រឹត្តបទល្មើសដោយមិនដឹងខ្លួនទៀតផងក៏មានដែរ។ ដោយកត្តាទាំងនេះហើយ ទើបនៅក្នុងស្ថាប័នធំៗនៅក្នុងពិភពលោកមានការខ្វល់ខ្វាយព្រួយបារម្ភពីអនាគតអនីតិជនទាំងនោះ នៅពេលដែលពួកគេបានប្រព្រឹត្តបទល្មើស នឹងត្រូវទទួលរងទណ្ឌកម្ម ដូចនីតិជនឬយ៉ាងណា? បើពួកគេមិនទាំងដឹងផងថាទង្វើដែលពួកគេប្រព្រឹត្តជាបទល្មើស ដូច្នេះហើយទើបបណ្តាលឱ្យមានបទបញ្ញត្តិទាំងច្បាប់ជាតិ និងអន្តរជាតិ ដើម្បីការពារផលប្រយោជន៍របស់កុមារ នៅដែលពួកគេបានប្រព្រឹត្តបទល្មើស។ ខាងក្រោមនេះ គឺជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ (១.១.២.១) និងជាតិ (១.១.២.២) ក្នុងការគាំពារកុមារដែលបានប្រព្រឹត្តបទល្មើស។

**១.១ ២.១.លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ**

សិទ្ធិរបស់កុមារ ត្រូវបានធានាជាសកលដោយស្ថាប័នកំពូលនៅលើពិភពលោក ពោលគឺអង្គការសហប្រជាជាតិជាដើម ដើម្បីជាការធានាថាកុមារនឹងទទួលបានសិទ្ធិពេញលេញក្នុងការរស់នៅ នៃបរិយាកាសសង្គមសព្វថ្ងៃ ដូច្នេះយើងនឹងលើកយកលិខិតតុបករណ៍ដែលចែងពាក់ព័ន្ធនឹងសិទ្ធិរបស់អនីតិជនទំនាស់នឹងច្បាប់។ វិធានខាងក្រោមនេះផ្តល់នូវសេចក្តីណែនាំក្នុងការអនុវត្តដល់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នកអនុវត្តច្បាប់ អ្នកធ្វើសេចក្តីសម្រេច ព្រះរាជអាជ្ញា និងចៅក្រមចំពោះកុមារ។ លិខិតបទដ្ឋានគតិយុត្តដែលគាំពារដល់កុមារមានដូចជាអនុសញ្ញាស្តីសិទ្ធកុមារ (មាត្រា៣៧, មាត្រា៤០) វិធានប៉េកាំង (វិធាន១១, វិធាន១២, វិធាន១៥, វិធាន១៨, វិធាន២២, វិធាន៣០) វិធានរបស់អង្គការសហប្រជាជាតិសម្រាប់កិច្ចការពារកុមារដែលត្រូវបានដកហូតសេរីភាព (វិធាន Havana 1990) (វិធាន១, វិធាន៣, វិធាន៦, វិធាន១២, វិធាន១៧, វិធាន១៨, វិធាន២៩, វិធាន៣០, វិធាន៣២, វិធាន៣៣, វិធាន៣៤, វិធាន៣៨ និងវិធាន៤២) ជាដើម។ កុមារទំនាស់នឹងច្បាប់គួរត្រូវបានអនុវត្តទៅតាមអាយុ ហើយត្រូវពិចារណាក្នុងការធ្វើសមាហរកម្មពួកគេទៅក្នុងសង្គមវិញ[3]។ មួយវិញទៀត សិទ្ធិអនីតិជនទំនាស់នឹង

[2] មាត្រា៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[3] មាត្រា ៤០ ចំណុច ៣ក នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩

ច្បាប់ត្រូវបានការពារដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ហើយក៏មានចែងនៅក្នុងវិធាន និង គោលការណ៍អន្តរជាតិផ្សេងទៀតដែរ។ ដើម្បីឱ្យស្របនឹងលិខិតតុបករណ៍ទាំងនេះ វិធីសាស្ត្រត្រូវបានបង្កើតឡើង ដោយរួមបញ្ចូលទាំងការអនុវត្តគោលការណ៍ណែនាំ បទដ្ឋានអន្តរជាតិ ការពិចារណាទៅលើការអនុវត្តល្អ។ នៅមុនដំណាក់កាល ក្នុងដំណាក់កាល និងក្រោយដំណាក់កាល នៃនីតិវិធីលើអនីតិជន គឺអនីតិជនមានសិទ្ធិដែលការពារដោយច្បាប់ពេញលេញ ដូចជាសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី[4]។

### ១.១ ២.២.លិខិតបទដ្ឋានគតិយុត្តជាតិ

ស្ថានភាពនៅកម្ពុជា ក្រោយពីបានបញ្ចប់សង្គ្រាមក៏បានស្តារហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស រួមទាំងរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីឱ្យប្រទេសក្លាយជានីតិរដ្ឋ ស្របទៅតាមច្បាប់។ ប្រទេសកម្ពុជាបានធ្វើការផ្តល់សច្ចាប័ន និងទទួលស្គាល់ច្បាប់អន្តរជាតិជាច្រើន ដែលក្នុងចំណោមច្បាប់ទាំងនោះក៏មានបញ្ញត្តិដែលកំណត់អំពីសិទ្ធិកុមារ និងការគាំពារកុមារ ដែលជាហេតុនាំឱ្យប្រទេសកម្ពុជាបង្កើតបទបញ្ញត្តិពាក់ព័ន្ធនឹងកុមារដើម្បីការពារ និងគាំពារកុមារ ដែលជាសរសរទ្រូងរបស់ប្រទេសជាតិនាពេលអនាគត។ ដូច្នេះ ខាងក្រោមនេះជាបទបញ្ញត្តិដែលប្រទេសកម្ពុជាបានអនុម័តពាក់ព័ន្ធនឹងកុមារ មានដូចជារដ្ឋធម្មនុញ្ញ (មាត្រា៣១ និងមាត្រា៤៨) ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីយុត្តិធម៌អនីតិជន គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩ ដល់ ២០២៩។

ជាក់ស្តែងនៅកម្ពុជាកុមារទំនាស់នឹងច្បាប់ អាចមានសិទ្ធិដូចជានៅមុនពេលចាប់ផ្តើមនីតិវិធីស៊ើបសួរមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាមានតួនាទីក្នុងការរំលឹកដល់អនីតិជនថាខ្លួនមានសិទ្ធិក្នុងការមិនផ្តល់ចម្លើយក្នុងកាលៈទេសៈណាមួយ ម៉្យាងទៀតអនីតិជនក៏មានសេរីភាពក្នុងការឆ្លើយដោយពុំត្រូវបានទទួលរងសម្ពាធក្នុងការបង្ខិតបង្ខំឱ្យផ្តល់ចម្លើយដែលមិនមែនជាការពិតនោះដែរ។ អនីតិជនមានសិទ្ធិក្នុងការរក្សាការសម្ងាត់នូវជីវិតឯកជនរបស់ខ្លួនដូចជាអំពីអត្តសញ្ញាណ ប្រវត្តិរូប ប្រវត្តិគ្រួសាររបស់អនីតិជន ត្រូវទុកជាការសម្ងាត់មិនឱ្យលេចឮដល់សាធារណៈជនណាឡើយ។ ហើយចំពោះអនីតិជនដែលទទួលរងនូវរបួស ឬមានជំងឺ ឬជួបគ្រោះថ្នាក់ អនីតិជននឹងទទួលបានសិទ្ធិក្នុងការពិនិត្យសុខភាព និងសម្រាកព្យាបាល។ ប្រសិនអនីតិជនត្រូវបានចាប់ខ្លួនមុនពេលចាប់ខ្លួនអនីតិជនមានសិទ្ធិក្នុងការទទួលបានដំណឹងពីការចាប់ខ្លួន ដោយអាជ្ញាធរមិនអាចមកធ្វើការចាប់ខ្លួនភ្លាមៗ ដោយមិនមានការជូនដំណឹងជាមុននោះទេដែលនាំឱ្យមានភាពផ្ទុយនឹងច្បាប់ ម៉្យាងទៀតអ្នកតំណាងដែលច្បាប់កំណត់ក៏ត្រូវទទួលបានសិទ្ធិពីការផ្តល់ដំណឹង នៃការចាប់ខ្លួនអនីតិជនដែលជាជនស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។ នៅក្នុងដំណាក់កាលនីតិវិធីអនីតិជនមានសិទ្ធិក្នុងការទទួលបានការពារក្តីពីមេធាវីតាមការជ្រើស

[4] អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ឆ្នាំ២០០៩

រើសរបស់អនីតិជនផ្ទាល់ ប៉ុន្តែបើអនីតិជនពុំមានលទ្ធភាពក្នុងការពឹងពាក់មេធាវីដោយខ្លួនឯងនោះទេ ពួកគេនឹងទទួលបានការចាត់តាំងមេធាវីដោយមិនទទួលកម្រៃដែលវាជាសិទ្ធិពិសេសរបស់អនីតិជន។ ដោយឡែកអ្នកតំណាងដែលច្បាប់បានកំណត់មានសិទ្ធិចូលរួមក្នុងដំណើរនីតិវិធីរបស់អនីតិជន លើកលែងតែងការចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់មានភាពផ្ទុយពីឧត្តមប្រយោជន៍របស់អនីតិជន។ មួយវិញទៀតប្រសិនបើអ-នីតិជនជាជនបរទេស ជននោះនឹងទទួលបានជំនួយក្នុងការបកប្រែភាសាដោយមិនគិតថ្លៃសេវាកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់អនីតិជនដែលជាជនបរទេសក្នុងដំណើរនីតិវិធីតុលាការ។ នៅក្នុងដំណាក់ការសើបសួរអនីតិជនមានសិទ្ធិក្នុងការបង្ហាញភស្តុតាង សិទ្ធិស្នើសុំកោះហៅសាក្សីដើម្បីមកបំភ្លឺក្នុងរឿងក្តី។ ជាចុងក្រោយអនីតិជនមានសិទ្ធិស្នើសុំអនុញ្ញាតនាំសេចក្តីសម្រេចរបស់តុលាការឱ្យខ្លួនស្ថិតនៅក្រៅឃុំ ឬមានសិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ រួមទាំងសិទ្ធិផ្សេងទៀតដែលមានចែងក្នុងវិធានផ្សេងៗទៀតដែលទាក់ទងនឹងអនីតិជន[5]។

## ១.២ លក្ខខណ្ឌ នៃការអនុវត្តទោសចំពោះអនីតិជន

យោងតាមគោលការណ៍ទូទៅនៃក្រមព្រហ្មទណ្ឌ បទល្មើសមួយអាចកើតឡើងដោយចេតនា ឬអចេតនា ឬការមិនប្រុងប្រយ័ត្ន ឬដោយភាពខ្ជីខ្ជា ឬដោយធ្វេសប្រហែស ហើយបណ្តាលឱ្យមានព្យសនកម្មដល់អ្នកដ៏ទៃដែលជាកត្តាដំបូងការទទួលខុសត្រូវ តែបទល្មើសទាំងនោះត្រូវតែមានជាតុផ្សំ នៃបទល្មើស ទើបអាចធ្វើការផ្តន្ទាទោសបានចំពោះអនីតិជនក៏ត្រូវគោរពគោលការណ៍ខាងលើផងដែរ គ្រាន់តែមានលក្ខខណ្ឌពិសេសបន្ថែមទៀត ដូចជា៖ លក្ខខណ្ឌនីតិភាព នៃអនីតិជន (១.២.១) និងកាលៈទេសៈ នៃបទល្មើស និងបុគ្គលិកលក្ខណៈ នៃជនល្មើស (១.២.២) ដែលជាកត្តាសំខាន់ ដើម្បីឱ្យអនីតិជនធ្វើការទទួលខុសត្រូវព្រហ្មទណ្ឌ។

### ១.២.១ នីតិភាពរបស់អនីតិជនក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ

កុមារដែលទំនាស់នឹងច្បាប់គួរត្រូវបានអនុវត្តទៅតាមអាយុរបស់គេ ហើយត្រូវពិចារណាក្នុងការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមវិញ។ ដោយស្ថានភាពនៅកម្ពុជាទាក់ទងទៅនឹងយុត្តិធម៌អនីតិជន មុនការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺមិនមានភាពល្អទេ បើទោះជាប្រទេសកម្ពុជាបានទទួលយកអនុសញ្ញានេះយូរហើយក៏ដោយ។ ប្រទេសកម្ពុជាបានធ្វើការកំណត់អាយុ នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ហើយកាលកំណត់ត្រូវគិតនៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើស ហើយចំពោះឯកសារដែលជាភស្តុតាងក្នុងការបញ្ជាក់អាយុរបស់កុមារត្រូវបញ្ជាក់ដោយមានដូចជាសំបុត្រកំណើត ឬឯកសារបញ្ជាក់អាយុ ឬបើពុំមានឯកសារទាំងនេះទេត្រូវជំនួសដោយឯកសារផ្សេងៗទៀត ដែលតុលាការអាចធ្វើការទទួលយកបាន ឬបើមិនដូច្នេះទេ

[5] មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

អាជ្ញាធរដែលមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ម៉្យាងវិញក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យ នៃអាយុនេះត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ[6]។ ប៉ុន្តែអ្វីជាផលលំបាកក្នុងការកំណត់អាយុរបស់អនីតិជននៅក្នុងប្រទេសកម្ពុជា ដោយហេតុថាប្រព័ន្ធចុះសំបុត្រកំណើតនៅក្នុងប្រទេសយើងនៅមានកម្រិតនៅឡើយ ដែលជាកត្តាចាំបាច់ត្រូវតែធ្វើការបំពេញបន្ថែម។ ម៉្យាងទៀតប្រទេសយើងមិនទាន់មានវិធីសាស្ត្របញ្ជាក់ពីអាយុតាមលក្ខណៈវិទ្យាសាស្ត្រ ឬវេជ្ជសាស្ត្រឱ្យបានត្រឹមត្រូវនៅឡើយ[7]។ ជាដំណោះស្រាយដ៏ល្អ និងយូរអង្វែង គួរកំណត់លក្ខខណ្ឌផ្លូវច្បាប់ដល់ឪពុកម្តាយឱ្យចុះសំបុត្រកំណើតដល់កូន បើពុំនោះទេត្រូវធ្វើការដាក់ពិន័យក្នុងករណីបរាជ័យលើការចុះសំបុត្រកំណើតដល់កូន ហើយអាជ្ញាធរត្រូវផ្តល់សេវាចុះសំបុត្រកំណើតដល់ឪពុកម្តាយគ្រប់រូបនៅគ្រប់ទីកន្លែង។ ការកំណត់អាយុនៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌគឺកត្តាចាំបាច់ និងជាប្រយោជន៍ដល់អនីតិជនដែលត្រូវតែមានដោយនីតិភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវកំណត់អាយុចាប់ពី១៨(ដប់ប្រាំបី) ឆ្នាំឡើង[8]។ ប៉ុន្តែចំពោះអនីតិជនក្នុងការអនុវត្តគោលការណ៍ចំពោះអនីតិជនឱ្យខុសពីមនុស្សពេញវ័យ ដូច្នេះទើបនីតិភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ សម្រាប់អនីតិជនត្រូវបានកំណត់ពីអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើង នៅពេលពួកគេបានប្រព្រឹត្តបទល្មើស ចុះចំណែកអនីតិជនក្រោម ១៤ ឆ្នាំវិញពេលប្រព្រឹត្តបទល្មើសអាចនឹងទទួលទណ្ឌកម្មដែរឬទេ? ដូច្នេះហើយទើបយើងធ្វើការបែងចែកជា ២ (ពីរ) ចំណុចក្នុងការបកស្រាយ គឺអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ (១.២.១.១) និងអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ (១.២.១.២)។

#### ១.២.១.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

ក្នុងករណីដែលអនីតិជនប្រភេទនេះបានប្រព្រឹត្តបទល្មើស ពួកគេនឹងមិនទទួលរងការផ្តន្ទាទោសណាមួយមិនថាជាបទល្មើសប្រភេទណាក៏ដោយ។ ដោយហេតុថាអនុសញ្ញាស្តីពីសិទ្ធិកុមារបានកំណត់ឱ្យរដ្ឋជាភាគីដែលរួមមានប្រទេសកម្ពុជាផងដែរនោះត្រូវធ្វើការកំណត់អាយុអប្បបរមា នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារ ហើយកុមារដែលមានអាយុក្រោមអាយុអប្បបរមានេះ ហើយពួកគេបានប្រព្រឹត្តបទល្មើស នោះកុមារទាំងនោះត្រូវបានសន្មតជាមុនថាពុំមានសមត្ថភាពប្រព្រឹត្តបទល្មើសនៅឡើយ[9] មានន័យថាដោយសារពួកគេនៅក្មេងពេក ហើយពួកគេមិនទាន់អាចធ្វើការពិចារណា ឬរិះគិតថាទង្វើដែលពួកគេបានប្រព្រឹត្ត គឺត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវនៅឡើយទេ

[6] មាត្រា៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[7] សៀវភៅ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៨-២០២០ ទំព័រ ១២ និង១៣

[8] មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[9] មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធកុមារ ឆ្នាំ២០១៦

ដូច្នេះហើយទើបពួកគេក៏មិនសាកសមក្នុងការទទួលខុសត្រូវចំពោះទង្វើដែលពួកគេមិនអាចយល់ដឹងក្នុងការបែងចែកថាទង្វើនោះត្រូវ ឬខុសនោះទេ។ ចំណែកឯច្បាប់នៅក្នុងប្រទេសកម្ពុជាក៏បានធ្វើការកំណត់ថាអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានឃាត់ខ្លួនបានឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់[10]។ ម៉្យាងទៀតក្នុងដំណាក់កាលព្រះរាជអាជ្ញាក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញ[11] ហើយអ្វីដែលជាចំណុចសំខាន់ក្នុងដំណាក់កាលនីតិវិធី អាជ្ញាធរមានសមត្ថកិច្ចមិនអាចធ្វើការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនបានឡើយ។ តាមការបកស្រាយខាងលើអាចធ្វើការសន្និដ្ឋានបានថាអនីតិជនដែលមានអាយុក្រោមអប្បបរមាដែលច្បាប់បានកំណត់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺជាកុមារដែលមានអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ នឹងមិនទទួលខុសត្រូវចំពោះទង្វើ នៃបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្តនោះទេ។ ឧទាហរណ៍៖ កុមារ ក ដែលមានអាយុ ១៣ ឆ្នាំ បានប្រលែងគ្នាជាមួយកុមារ ខ ដែលមានវ័យស្របាលគ្នាហើយនៅអំឡុងពេលកំពុងប្រលែងគ្នា កុមារ ក បានគប់ដំបងទៅឱ្យកុមារ ខ ចាប់ ប៉ុន្តែដំបងនោះបានធ្លាក់មកត្រូវនឹងស្មារបស់ កុមារ ខ ទៅវិញ ដែលបណ្តាលឱ្យកុមារ ខ បាក់ឆ្អឹងដងកាំបិតមានបញ្ហាក្នុងការប្រើប្រាស់ដៃមួយរយៈធំ។ ក្នុងករណីនេះកុមារ ក ដែលបានគប់ដំបងត្រូវកុមារ ខ បង្កបានជាបទល្មើសព្រហ្មទណ្ឌនោះពុំទទួលខុសត្រូវនោះទេ ដោយហេតុថាកុមារ ក នៅមិនទាន់អាចពិចារណាថាទង្វើខ្លួនខុស ឬត្រូវនៅឡើយ ដោយគេគិតថាគ្រាន់ជាការប្រលែងគ្នាដើម្បីភាពសប្បាយរីករាយ។ គួរបញ្ជាក់ផងដែរអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ អាចនឹងមិនទទួលរងការប្រកាសទណ្ឌកម្មពីតុលាការ ប៉ុន្តែអនីតិជនប្រភេទនេះអាចនឹងទទួលបានការប្រកាសសេចក្តីសម្រេចដែលអាចកំណត់អំពីការស្តីបន្ទោស ឬវិធានអប់រំ។ សរុបជារួមមកអនីតិជនប្រភេទនេះ តុលាការនឹងមិនធ្វើការប្រកាសទណ្ឌកម្ម តែតុលាការអាចធ្វើការប្រកាសឱ្យអនីតិជននេះស្ថិតក្នុងវិធានណាមួយក្នុងចំណោមវិធានដូចជា៖ វិធានការការពារ វិធានការអប់រំ វិធានការឧបត្ថម្ភ ឬក៏ប្រគល់អនីតិជនទៅឱ្យសាច់ញាតិ ឬសេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា ឬស្ថាប័នឯកទេស និងអាចដាក់អនីតិជននោះឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការផងដែរ។

### ១.២.១.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ

អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ នៅពេលដែលពួកគេបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ពួកគេត្រូវបានសន្មតថាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវទង្វើរបស់ខ្លួនចំពោះមុខ

[10] មាត្រា ១៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[11] មាត្រា ២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

សមត្ថភាពក្នុងការទទួលខុសត្រូវកន្លែងនេះចង់សំដៅថាអនីតិជនប្រភេទនេះ គាត់មានសមត្ថភាពការយល់ដឹងនិងអាចធ្វើការពិចារណាចំពោះទង្វើរបស់ខ្លួនដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម និងជននេះក៏អាចយល់ដឹងអំពីចរិតលក្ខណៈគ្រោះថ្នាក់របស់ខ្លួននឹងអាចបញ្ជានូវរាល់អំពើទាំងនោះបាន។ កត្តាដែលនាំឱ្យមានការយល់ឃើញបែបនេះផ្អែកទៅលើការរីកចម្រើន នៃរូបរាងកាយ ប្រាជ្ញាស្មារតី និងការសន្សំបទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅប្រចាំថ្ងៃកន្លងមករបស់អនីតិជន ហេតុនេះទើបច្បាប់បានធ្វើការសន្មតថាអនីតិជនប្រភេទនេះគ្មានសមត្ថភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ករណីអនីតិជនប្រភេទនេះទទួលខុសត្រូវតែចំពោះបទល្មើសមជ្ឈិម បទឧក្រិដ្ឋជាក់ស្តែងប៉ុណ្ណោះ ដោយឡែកចំពោះអនីតិជនប្រភេទនេះដែលបានប្រព្រឹត្តបទលហុពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ដោយមន្ត្រីនគរបាលមានសមត្ថកិច្ចគ្រាន់តែយកអនីតិជននោះធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ បន្ទាប់មកប្រគល់អនីតិជននោះឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ហើយបើអនីតិជនសារភាពកំហុសខ្លួនគេអាចអនុវត្តវិធានការសម្រុះសម្រួលរវាងភាគីដើម្បីបញ្ចប់វិវាទ[12]។ ទោះបីជាយ៉ាងណាក៏ដោយការទទួលខុសត្រូវរបស់អនីតិជនមិនមានលក្ខណៈពេញលេញដូចនីតិជនឡើយ ពោលគឺទណ្ឌកម្មដែលអនុវត្តចំពោះអនីតិជន គឺមានកម្រិតស្រាលជាងនីតិជនហើយការប្រកាសទណ្ឌកម្មនេះទៀតសោតអាចធ្វើទៅបានលុះត្រាតែកាលៈទេសៈ នៃបទល្មើសបានចង្អុលបង្ហាញ រួមផ្សំជាមួយនឹងបុគ្គលិកលក្ខណៈរបស់អនីតិជននោះផង។ ការអនុវត្តទណ្ឌកម្មចំពោះអនីតិជនអាយុ ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មានលក្ខណៈខុសពីនីតិជននឹងមិនអាចប្រព្រឹត្តចំពោះអនីតិជនដូចជាមនុស្សពេញវ័យនោះទេ ដោយកម្រិតទោសដែលអនីតិជនទទួលរង គឺត្រូវបន្ថយមកត្រឹមពាក់កណ្តាល[13]បើប្រៀបធៀបទៅនឹងទោសដែលមានចែងចំពោះនីតិជនហើយត្រូវធានាផងដែរថាមនុស្សពេញវ័យនឹងមិនឆ្លៀតយកលក្ខខណ្ឌពិសេសរបស់អនីតិជនមកអនុវត្តចំពោះខ្លួនឡើយ។

**ឧទាហរណ៍** នៅពេលមានបទល្មើស លួច កើតឡើងដោយអនីតិជន ពេលនោះតុលាការនឹងធ្វើការជំនុំជម្រះជាទូទៅចំពោះនីតិជន បទលួច តុលាការប្រកាសផ្តន្ទាទោស ពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ ប៉ុន្តែចំពោះអនីតិ-ជនតុលាការនឹងធ្វើការប្រកាសផ្តន្ទាទោសពី ៣ (បី) ខែ ទៅ ១ (មួយ) ឆ្នាំ និង ៦ (ប្រាំមួយ) ខែវិញ។ បើបទល្មើសនោះជាបទល្មើសព្រហ្មទណ្ឌដែលតម្រូវឱ្យជាប់ពន្ធនាគារមួយជីវិត គឺតុលាការនឹងកាត់បន្ថយទោសនោះមកត្រឹម ២០ឆ្នាំ តែប៉ុណ្ណោះ ចំពោះអនីតិជនដែលមានវ័យពី ១៤ ឆ្នាំ ដល់ ១៨ ឆ្នាំ។

[12] មាត្រា១៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[13] មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

កាលណាបទល្មើសនោះបង្កព្យសន្យកម្ម ឬការខូចខាតផ្សេង ជនរងគ្រោះ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះអាចដាក់បណ្ដឹងរដ្ឋប្បវេណីបាន ដើម្បីទាមទារឱ្យអនីតិជនសងសំណងជាប្រាក់ គេអាចធ្វើបានទោះបីជាមានបណ្ដឹងអាជ្ញាក៏ដោយ[14]។ ករណីនេះអនីតិជននឹងត្រូវទទួលខុសត្រូវបណ្ដឹងរដ្ឋប្បវេណី ដើម្បីជួសជុលសងការខូចខាតដែលបណ្ដាយមកពីអំពើល្មើសរបស់ជនល្មើសចំពោះជនរងគ្រោះ ដើម្បីទទួលបានព្យសនកម្មដែលសមទទួលបាន[15]។ ការបង្ហាញព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែពិតប្រាកដ និងដោយផ្ទាល់ ហើយដើមបណ្ដឹងត្រូវធ្វើឡើងតាំងពីសាលាជម្រះក្ដីថ្នាក់ទីមួយមកម្ល៉េះ។ ទោះជាយ៉ាងណាក្ដីបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវរលត់នៅពេលដែលផុតចិរវេលា នៃអាជ្ញាយុកាលនូវបណ្ដឹងអាជ្ញា មានន័យថាកាលណាជនល្មើសត្រូវបានរួចខ្លួនពីការចោទប្រកាន់ហើយ បណ្ដឹងរដ្ឋប្បវេណីក៏ពុំមានសុពលមានផងដែរ។

### ១.២.២ លក្ខខណ្ឌផ្សេងៗ

យោងតាមគោលការណ៍ នៃការកំណត់អំពីទណ្ឌកម្ម ឬគោលការណ៍ នៃការផ្ដន្ទាទោស តុលាការអាចសេចក្ដីសម្រេចផ្ដន្ទាទោសជនល្មើសណាម្នាក់បាន ត្រូវពិចារណាអំពីបាតុភូតសង្គមដែលបទល្មើសបានកើតឡើងឱ្យគ្រប់ជ្រុងជ្រោយជាមុនសិន ទើបធ្វើការសម្រេចផ្ដន្ទាទោសទៅលើចារីបាន។ ចំពោះអនីតិជនក៏ធ្វើការវិភាគមើលទៅលើបទល្មើសដែលអនីតិជនដែលប្រព្រឹត្ត មានន័យថាដើម្បីឱ្យសេចក្ដីសម្រេចប្រកាសទោសចំពោះពិរុទ្ធជនប្រកបដោយភាពសុក្រឹត្យភាព និងសុភវិនិច្ឆ័យ ចៅក្រមជំនុំជម្រះត្រូវពិចារណាទៅលើចំណុចសំខាន់ៗដូចជា៖ទីមួយ គឺត្រូវពិចារណាពាក់ព័ន្ធនឹងបញ្ហាដែលមានចែងនៅក្នុងច្បាប់ ពោលគឺសំដៅទៅដល់គោលការណ៍នីត្យានុកូល នៃទោស ទីពីរ គឺត្រូវពិចារណាទៅលើស្ថានភាព នៃការប្រព្រឹត្តបទល្មើស ថាតើបទល្មើសនោះបានប្រព្រឹត្តនៅកាលៈទេសៈណា? ពេលវេលាណា? ទីកន្លែងណា? ទីបី គឺត្រូវពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើស។ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដោយផ្ដោតលើកាលៈទេសៈ នៃបទល្មើស (១.២.២.១) ឬ បុគ្គលិកលក្ខណៈរបស់អនីតិជន (១.២.២.១)។

#### ១.២.២.១ កាលៈទេសៈ នៃបទល្មើស

កាលៈទេសនៃបទល្មើស គឺជាធាតុផ្សំមួយសំខាន់សម្រាប់វិនិច្ឆ័យទៅលើការដាក់ទោស អនីតិជនដែលវាប្រៀបដូចជា ធាតុសន្យានុម័តដែលកំណត់ពីបទល្មើស និងកំណត់ព្រំដែន នៃបទល្មើស ដោយផ្អែកទៅលើបទពិសោធន៍ នៃសេចក្ដីសម្រេចរបស់តុលាការ គេមើលទៅមើលមធ្យោបាយប្រព្រឹត្តបទល្មើស វិធីសាស្ត្រប្រព្រឹត្តបទល្មើស ជាពិសេសពេលវេលា ទីកន្លែង និងទិដ្ឋភាពនានា[16]។

---

[14] មាត្រ ៨ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[15] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[16] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ ហ៊ី សោភា ទំព័រ ៧៣ ដល់ ទំព័រ ៧៥

**មធ្យោបាយប្រព្រឹត្តបទល្មើស** គឺស្តែងតាមរយៈថាអនីតិជនប្រើប្រាស់អ្វីសម្រាប់ប្រព្រឹត្តបទល្មើស ហើយចំពោះមធ្យោបាយដែលអនីតិជនអាចប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសមានដូចជា៖ អាវុធ ឬសម្ភារៈ ឬវត្ថុដែលបណ្តាលឱ្យមានព្យសនកម្មធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខសង្គមជាតិ។ ឧទាហរណ៍៖ កុមារវ័យ ១៦ឆ្នាំ បានប្រើកាំបិតចាក់ពោះបុរសម្នាក់ដោយកំហឹង ធ្វើឱ្យបុរសម្នាក់នោះរងរបួសធ្ងន់ត្រូវដេរសាមសិបថ្នេរ។ តុលាការបានធ្វើការបកស្រាយថា កាំបិតជាមធ្យោបាយប្រព្រឹត្តបទល្មើសដែលបង្កជាព្យសនកម្ម នាំឱ្យតុលាការសម្រេចផ្តន្ទាទោសពីបទហិង្សាដោយចេតនាដោយគិតស្ថានទម្ងន់ទោស[17]។

**វិធីសាស្ត្រប្រព្រឹត្តបទល្មើស** សំដៅដល់អនីតិជនប្រើប្រាស់គ្រប់វិធីបែបផែនក្នុងការប្រព្រឹត្តបទល្មើសដើម្បីឱ្យដល់គោលដៅរបស់ខ្លួនដែលបានកំណត់ទុក ដែលជាអំពើជាក់ស្តែងចេញពីសកម្មភាព នៃកាយវិការរបស់ចារី។ ឧទាហរណ៍៖ អនីតិជន ក មានបំណងលួចរបស់មានតម្លៃរបស់អ្នកជិតខាង ដូច្នេះរាល់ល្ងាចនៅពេលអ្នកជិតខាងមកពីធ្វើការ កុមារ ក តែងទៅនិយាយលេង ដើម្បីទៅមើលថាក្នុងផ្ទះរបស់អ្នកជិតខាងមានវត្ថុមានតម្លៃអ្វីខ្លះ និងដើម្បីទៅលួចមើលកន្លែងលាក់សោរផ្ទះ បន្ទាប់ពីបានដឹងកន្លែងលាក់សោរជាក់លាក់ និងត្រៀមខ្លួនរួចហើយគេក៏បានធ្វើសកម្មភាពលួចទ្រព្យសម្បត្តិអ្នកជិតខាងនៅពេលពួកគេបានទៅដើរលេង។ តាមសកម្មភាពខាងលើ តុលាការអាចផ្តន្ទាទោសអនីតិជន ក ពីបទលួច ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ[18]។

**ពេលវេលាប្រព្រឹត្តបទល្មើស** សំដៅទៅលើរយៈពេលកំណត់មួយដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបានស្តែងចេញក្រៅ។ នេះមានន័យថា ពេលវេលាប្រព្រឹត្តដែលបានកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌ ក៏ជាធាតុផ្សំយ៉ាងសំខាន់ ដើម្បីកំណត់នូវបទល្មើសផ្ទាល់តែម្តង។ ជាក់ស្តែងការធ្វើនេសាទក្នុងរដូវបិទនេសាទដែលពុំទទួលបានការអនុញ្ញាតឱ្យធ្វើនេសាទ[19] ដែលយើងត្រូវលើកយកពិចារណាលើពេលវេលា នៃការប្រព្រឹត្តបទល្មើសនេះដែលជនល្មើសនេសាទខុសរដូវ ខុសពេលវេលាដែលនាំឱ្យប៉ះពាល់ដល់មច្ឆជាតិ និងធម្មជាតិ។

**ទីកន្លែងបទល្មើស** សំដៅដល់ដែនដី ទីតាំង ឬជារង្វង់ដែនដីមួយជាកំណត់ដែលជនល្មើសបានប្រព្រឹត្តបទល្មើស រាប់តាំងពីទីកន្លែងចាប់ផ្តើមប្រព្រឹត្ត រហូតដល់ទីកន្លែងដែលបទល្មើសបានបញ្ចប់។ ម៉្យាងទៀតជាទីកន្លែង នៃចំណុចណាមួយ ឬជាតំបន់ដែនដីណាមួយជាកំណត់ដែលច្បាប់ព្រហ្មទណ្ឌបានបញ្ញត្តិថាវាជាទីកន្លែងមួយដែលសម្រាប់កំណត់នូវបទល្មើសព្រហ្មទណ្ឌ។ ឧទាហរណ៍៖ ការហាមឃាត់នូវកន្លែងអភិរក្សជលផលក្នុងធ្វើការនេសាទគ្រប់ប្រភេទរួមមាន តំបន់ទឹកជ្រូរ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹង ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅ

[17] មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[18] មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[19] មាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងវិស័យជលផល ឆ្នាំ២០០៦

សមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាងដែលជាកន្លែងមានសារៈសំខាន់សម្រាប់និរន្តភាព នៃធនធានជលផល[20]។ ការនេសាទនៅតំបន់អភិរក្សនេះធ្វើបានលុះត្រាតែមានការអនុញ្ញាតពីក្រសួង ហើយបើជនល្មើសនៅតែប្រព្រឹត្ត បទល្មើសនៅកន្លែងហាមឃាត់នេះនឹងត្រូវទទួលទោសតាមកាលកំណត់របស់ច្បាប់។

**១.២.២.២ លក្ខខណ្ឌបុគ្គលិកលក្ខណៈ**

បុគ្គលិកលក្ខណៈរបស់អនីតិជន សំដៅដល់ការយល់ដឹងបញ្ញាស្មារតី អាយុ អត្តចរិត[21] របស់អនីតិជន ដែលមានសមត្ថភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះសកម្មភាពដែលបានប្រព្រឹត្ត។ ជាទូទៅរាល់អនីតិជន អាយុ ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសទាំងអស់ តុលាការអាច សម្រេចដាក់ត្រឹមតែការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ។ ប៉ុន្តែក្នុងករណី មួយចំនួនតុលាការនឹងធ្វើការប្រកាសទណ្ឌកម្មចំពោះអនីតិជនដោយពិចារណាលើកម្រិត នៃការយល់ដឹងជា មុនសិន ដោយគេមានលក្ខខណ្ឌពីរយ៉ាងដើម្បីធ្វើការវាយតម្លៃថាអនីតិជនមានចំណេះយល់ដឹងពិចារណាចំពោះ ទង្វើរបស់ខ្លួនដល់កម្រិតណា ឬក៏មិនអាចពិចារណាបានដោយធ្វើការវាយតម្លៃតាមបែបធម្មជាតិ និងតាមបែប វេជ្ជសាស្ត្រ[22]។

**ការវាយតម្លៃតាមបែបធម្មជាតិ** នៅក្នុងរបៀបនេះគេត្រូវធ្វើការពិចារណាចំពោះរូបរាងកាយ ចំណេះដឹង និងធ្វើការពិនិត្យទៅលើអាយុរបស់ពួកគាត់ផងដែរ។ ការពិចារណានេះ គឺផ្អែកលើការរីកចម្រើន នៃផ្នែកសរីរាង្គ ដែលពាក់ព័ន្ធរួមមាន បញ្ហាសរសៃប្រសាទ និងរាងកាយរបស់គាត់នោះឯង។ ចំពោះបញ្ហាសរសៃប្រសាទវិទ្យា សាស្ត្រផ្នែកសរសៃប្រសាទបានបង្ហាញថាការអភិវឌ្ឍខួរក្បាលដោយបង្ហាញឱ្យឃើញថាចលនាអភិវឌ្ឍប្រព័ន្ធ សរសៃប្រសាទ គឺមានយ៉ាងហោចណាស់រហូតដល់អាយុ ២០ឆ្នាំ។ ដំណើការ នៃការអភិវឌ្ឍខួរក្បាលនេះគឺជាប់ ពាក់ព័ន្ធនឹងដំណើរ នៃការគិត (ដូចជាកម្រិតនៃបញ្ញាភាពងាយនឹងអូសទាញ ការខ្វះការពិចារណា ការចងចាំ និងការសម្រេចចិត្ត) ហើយដែលដំណើរការ នៃការអភិវឌ្ឍទាំងនេះមិនដូចគ្នាទេនៅក្នុងថតនីមួយៗ។ ថតខួរក្បាល ខាងមុខ (ដែលមានតួនាទីក្នុងការវិនិច្ឆ័យ ធ្វើការសម្រេចចិត្ត និងការគ្រប់គ្រងទង្វើ) មានការអភិវឌ្ឍយឺត។ ផ្ទុយ ទៅវិញផ្នែកខាងក្នុង នៃថតខួរក្បាលកណ្ដាលដែលហៅថា Amygdala ដែលមានតួនាទីគ្រប់គ្រងអារម្មណ៍មាន ការអភិវឌ្ឍនៅពេលជិតចូលវ័យជំទង់។ ភាពក្មេងខ្ចីរបស់កុមារត្រូវបានគេយកមកពិចារណាជាប្រចាំដើម្បីបន្ធូរ បន្ថយទោសដោយមិនមានការផ្ដន្ទាទោសធ្ងន់ធ្ងរនោះទេ[23]។ ដូច្នេះទើបក្រមព្រហ្មទណ្ឌបានកំណត់អនីតិជនដែល

[20] មាត្រា ១៨ និង១៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងវិស័យជលផល ឆ្នាំ២០០៦

[21] មាត្រា ៦៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[22] សៀវភៅនីតិព្រហ្មទណ្ឌ សាស្ត្រាចារ្យ ហ៊ី សោភា ទំព័រ៨០ ដល់៨៣

[23] សៀវភៅផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ស្តីពីច្បាប់ស្ដីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៨-២០២០ ទំព័រ ២១៩ ដល់ ២២០

មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ហើយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយក្នុងកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈ នៃបទល្មើស គឺចៅក្រមអាចប្រកាសផ្ដន្ទាទោសទៅលើអនីតិជននោះបាន[24]។

**ការវាយតម្លៃតាមបែបវេជ្ជសាស្ត្រ** ជាការវាយតម្លៃតាមបែបនេះ គឺវាយតម្លៃតាមស្ថានភាព នៃជម្ងឺដែលនាំឱ្យជននោះមិនអាចយល់ដឹងបានដូចជាមនុស្សដែលស្ថិតក្នុងស្ថានភាពវិបល្លាសស្មារតីជាប្រចាំ ឬជាជនខ្សោយសតិ ឬសតិពុំប្រក្រតី ឬជំងឺផ្សេងៗទៀតដែលបណ្ដាលឱ្យមានភាពរីករាលក្នុងសកម្មភាពនេះតែម្ដង។ ភាពសរសៃប្រសាទនេះអាចមានរូបភាពជាក់ស្ដែងខុសៗគ្នាដែលនាំមកនូវលទ្ធផលសភាពជំងឺជាប្រចាំ ឬយូរអង្វែង។ ក្នុងករណីខ្លះភាពនៃសរសៃប្រសាទអាចជាបណ្ដោះអាសន្នស្ដែងឡើងភ្លាមៗ ក្នុងរយៈពេលខ្លីធ្វើឱ្យមានការបាត់បង់នូវការយល់ដឹងភ្លេចទាំងស្រុង ឬមួយផ្នែក នៃករណីដែលបានកើតឡើងក្នុងពេលវេលាណាមួយដែលជំងឺនោះបានធ្វើសកម្មភាព។

## ១.៣ មូលហេតុដែលបង្កឱ្យមានបទល្មើស

នៅក្នុងសង្គមខ្មែរកត្តាដែលបណ្ដាល ឬបង្កឱ្យកើតជាបទល្មើសមានច្រើនរូបភាព និងផ្សេងៗពីគ្នាទៅតាមប្រភេទនៃបទល្មើសនីមួយៗ ជាពិសេសទាក់ទងទៅនឹងកំរិតគ្រោះថ្នាក់នៃបទល្មើសរួមជាមួយព្យសនកម្មដែលទទួលរង និងផលនៃបទល្មើសនោះផងដែរ។ ជាក់ស្ដែងនៅក្នុងសង្គមឃើញថាកត្តាដែលនាំឱ្យជនល្មើសបានប្រព្រឹត្តបទល្មើសមានដូចជា៖

- **កត្តាវប្បធម៌** : ប្រទេសនីមួយៗតែងតែមានវប្បធម៌ផ្សេងៗពីគ្នា ប៉ុន្តែដោយសារការមានទំនាក់ទំនងគ្នាទៅវិញទៅមកនិងការធ្វើសមាហរណកម្ម ក៏ចៀសមិនផុតពីការសាយភាយ នៃវប្បធម៌ដ៏ទៃចូលមកក្នុងប្រទេសរបស់យើង ហើយការជ្រៀតចូលវប្បធម៌បរទេសចូលមកប្រទេសយើង ក៏ជាហេតុនាំមានការប្រព្រឹត្តបទល្មើសផងដែរ។ ឧទាហរណ៍ កាលពីថ្ងៃចូលឆ្នាំថ្មីប្រពៃណីខ្មែរកន្លងទៅនេះ យើងសង្កេតឃើញថាប្រជាពលរដ្ឋខ្មែរហាក់បីដូចជារីករាយជាមួយនឹងល្បែងកម្សាន្តបាច់ទឹក និងលាបម្សៅដែលជាល្បែងកម្សាន្តមួយបានសាយភាយពីប្រទេសជិតខាងមកចូលក្នុងប្រទេសរបស់យើង ហើយល្បែងកម្សាន្តនេះទៀតសោតក៏អាចបង្កជាបទល្មើសផងដែរ ដូចជាបទល្មើសលួច គ្រោះថ្នាក់ចរាចរណ៍ជាដើម។
- **កត្តាអប់រំ** : ការអប់រំគឺជាគ្រឹះនៃការអភិវឌ្ឍខ្លួន ហើយការអភិវឌ្ឍខ្លួនជាគ្រឹះក្នុងការបណ្ដុះធនធានល្អ។ ដើម្បីឱ្យមានធនធានល្អ ការអប់រំមានគុណភាពនៅពេលការអប់រំមានគុណភាពប្រទេសជាតិក៏មានការរីកចម្រើន និងមានសុខសន្តិភាព។ ដូច្នេះហើយប្រទេសនីមួយៗព្យាយាមក្នុងការផ្ដល់ការអប់រំទៅដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ព្រោះការមានចំណេះដឹងធ្វើឱ្យបុគ្គលម្នាក់មានការគិតពិចារណាមាន

[24] មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដូច្នេះហើយវាជាសូចនាករ[25]ថាការអប់រំពិតជាមានសារៈសំខាន់ក្នុងការស្វែងរកសហសន្តិជីវភាព[26]។ ផ្ទុយមកវិញ ប្រសិនបើប្រជាពលរដ្ឋប្រទេសមួយគ្មានការអប់រំ ឬការអប់រំនៅមានកម្រិតនោះយើងនឹងឃើញថាសង្គម នៃប្រទេសទាំងនោះនឹងជួបវិបត្តិការរស់នៅគ្មានស្ថេរភាព អនាធិបតេយ្យដែលជាហេតុបង្កឱ្យមានការប្រព្រឹត្តបទល្មើសផ្សេងៗដូចជាបទល្មើសលួច ឃាតកម្ម កេងប្រវ័ញ្ច ការគំរាមកំហែង។ល។

- **កត្តាច្បាប់** : ជាបទបញ្ញត្តិមួយដែលបានចងក្រងឡើងក្នុងគោលបំណងបង្កាកុំឱ្យមានបទល្មើសឡើង និងបង្រ្កាបបទល្មើសដែលធ្វើឱ្យមានព្យសនកម្មដល់សង្គម ដើម្បីធានានូវប្រយោជន៍នៃសង្គមឱ្យមានស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយជាដើម។ ប៉ុន្តែបើបទបញ្ញត្តិច្បាប់ដែលបានបង្កើតឡើងគ្មានការផ្សព្វផ្សាយឱ្យទូលំទូលាយទៅប្រជាពលរដ្ឋនោះទេ នោះបទបញ្ញត្តិក៏មិនមានប្រសិទ្ធភាពក្នុងការអនុវត្តឡើយ។ ម្យ៉ាងទៀតប្រជាពលរដ្ឋអាចនឹងធ្វើសកម្មភាពដែលច្បាប់បានហាមឃាត់ដោយមិនដឹងថាជាអំពើល្មើស ដូច្នេះការបង្កើតច្បាប់ត្រូវតែមានការផ្សព្វផ្សាយឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋដែលជាអ្នកអនុវត្ត។
- **កត្តាភូមិសាស្ត្រ** : ទីតាំងភូមិសាស្ត្រក៏ជាកត្តាមួយដែលមានឥទ្ធិពលផងដែរក្នុងការប្រព្រឹត្តបទល្មើស។ រវាងទីក្រុង និងជនបទទំនាបនៃស្ថានភាពបទល្មើសមានលក្ខណៈ និងការវិវឌ្ឍខុសគ្នាចំពោះបទល្មើសដែលកើតឡើងអាស្រ័យដោយស្ថានភាពនៃទីតាំងភូមិសាស្ត្រ ដូចជាការកាប់ព្រៃឈើខុសច្បាប់អាចកើតឡើងនៅតែតំបន់មានព្រៃឈើ បទនេសាទអាចកើតឡើងនៅតែតំបន់ដែលមានទន្លេ បឹង ស្ទឹង ព្រែក ការកកស្ទះចរាចរណ៍អាចកើតឡើងនៅក្នុងទីក្រុង ដែលបង្កឱ្យមានបទល្មើសចរាចរណ៍ ទីកន្លែងស្ងប់ស្ងាត់ជាកាលៈទេសៈគាប់ប្រសើរសម្រាប់ការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈជាដើម។

## ១.៤ កិច្ចការពារកុមារ

នៅក្នុងប្រទេសកម្ពុជា ប្រជាជនភាគច្រើនមានវ័យក្មេង ដែលបុគ្គលទាំងនោះជាសសរទ្រូងរបស់ប្រទេសជាតិ ប៉ុន្តែបច្ចុប្បន្នយើងមើលឃើញថាកុមារទាំងនោះហាក់បីជាមានការទទួលរងផលប៉ះពាល់ពីបរិបទសង្គមដែលមានកត្តាដូចជា ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ការគំរាមកំហែង ការរំលោភបំពានទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ការកេងប្រវ័ញ្ចគ្រប់ទម្រង់ ដោយសារទាំងអស់នេះហើយ បានជំរុញឱ្យកុមារជាច្រើនក្លាយទៅជាជន-រងគ្រោះ ព្រមទាំងក្លាយជាជនល្មើសផងដែរ។ នៅពេលប្រទេសមួយមានកុមារជាជនល្មើស និងជនរងគ្រោះ និង

[25] សន្ទានុក្រមពាក្យថ្មី រៀបរៀងដោយសាស្ត្រាចារ្យ ទូច គីមស្រ៊ាង ឆ្នាំ២០១៤ ទំព័រ ៧៣

[26] សន្ទានុក្រមពាក្យថ្មី រៀបរៀងដោយសាស្ត្រាចារ្យ ទូច គីមស្រ៊ាង ឆ្នាំ២០១៤ ទំព័រ ៧១

ធ្វើឱ្យការអភិវឌ្ឍគ្មានស្ថេរភាពនៅពេលអនាគត ដោយសម្លឹងមើលឃើញនូវបញ្ហាទាំងនេះ រដ្ឋាភិបាលកម្ពុជាបានយកចិត្តដាក់យ៉ាងខ្លាំងក្នុងការការពារ និងគាំពារកុមារ ដោយធានាឱ្យបានថាទោះបីជាកុមារស្ថិតនៅក្រោមការឃុំខ្លួនក៏ដោយក៏ពួកគេទទួលបានការយកចិត្តទុកដាក់ ទទួលបានការអប់រំ មិនទទួលបានការការរើសអើងពីមជ្ឈដ្ឋានខាងក្រៅ។ ដោយការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះសិទ្ធិកុមារ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ និងបានដាក់ចេញនូវបទបញ្ញត្តិ គោលនយោបាយ និងផែនការសកម្មភាពជាតិ រួមទាំងយន្តការជាច្រើនទាក់ទងនឹងកិច្ចការពារកុមារ ដើម្បីធានាការអនុវត្តពេញលេញនូវគោលការណ៍ និងបទបញ្ញត្តិនានារបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ។ ជាមួយនឹងការយកចិត្តទុកដាក់ចំពោះសិទ្ធិ និងសុខុមាលភាពកុមារ រាជរដ្ឋាភិបាលក៏បានចាត់បញ្ហាកុមារជាបញ្ហាអាទិភាព ក្នុងកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន។ ក្នុងក្របខណ្ឌគោលនយោបាយជាតិ នៃប្រព័ន្ធកិច្ចការពារកុមារនេះផ្តោតសំខាន់លើសសរស្តម្ភទាំង៣ គឺការបង្ការទប់ស្កាត់ ការអន្តរាគមន៍ ការផ្តល់សេវា និងការឆ្លើយតបជាពហុវិស័យទាន់ពេលវេលាចំពោះកុមារគ្រប់រូបដោយគ្មានការរើសអើង និងត្រូវឱ្យមានភាពប្រទាក់ក្រឡា និងស៊ីចង្វាក់គ្នាចាប់ពីវិធានាការទប់ស្កាត់រហូតដល់ការឆ្លើយតបចំពោះកុមាររងគ្រោះឱ្យទទួលបានសុវត្ថិភាពទាំងផ្លូវកាយ ផ្លូវចិត្ត និងសុខុមាលភាព។ ក្នុងនោះកុមារគ្រប់រូបត្រូវទទួលបានការពារដោយច្បាប់ កុមាររងគ្រោះ និងគ្រួសារត្រូវទទួលបានសេវាសមស្របត្រូវមានធនធានមនុស្ស និងថវិកាគ្រប់គ្រាន់សម្រាប់កិច្ចការពារកុមារ និងត្រូវផ្លាស់ប្តូរឥរិយាបថសង្គមចំពោះការប្រព្រឹត្តទៅលើកុមារ។

កុមារ ត្រូវបានការពារជាពិសេសនៅពេលដែលពួកគេបានប្រព្រឹត្តបទល្មើស។ ដូច្នេះ ក្នុងយុត្តិធម៌អ-នីតិជន ការចេញការព្រមានត្រូវបានប្រើប្រាស់ដើម្បីដាក់ពិន័យកុមារ ដោយមិនចាំបាច់បញ្ជូនទៅឃុំឃាំងទេ ការចេញសេចក្តីព្រមាននេះ ត្រូវបានអនុវត្តចំពោះកុមារប្រព្រឹត្តបទល្មើសជាលើកដំបូង។ ការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅពេលដែលពួកគេប្រព្រឹត្តបទល្មើសតូចតាច ត្រូវផ្តល់សេវាអប់រំកែប្រែដ៏សមស្រប ដោយមានគោលការណ៍ចំនួន ៣គឺ **ទី១** ផ្តល់សេវាចំពោះករណីដែលមានហានិភ័យខ្ពស់ **ទី២** កំណត់ឱ្យដឹងពីឫសគល់នៃបញ្ហាដែលបណ្តាលឱ្យកុមារប្រព្រឹត្តបទល្មើស និង**ទី៣** ប្រើប្រាស់វិធីសាស្ត្រដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កុមារ[27]។

## ១.៥ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើស ច្បាប់តម្រូវឱ្យបុគ្គលទាំងនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដោយបានកំណត់ថាមានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុង

[27] សៀវភៅផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៨-២០២០ ទំព័រ ២៣

បទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន[28]។ ប៉ុន្តែមានមូលហេតុមួយចំនួនដែលជាមូលហេតុ នៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬក៏ជាការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌនឹងនាំទៅដល់ការរួចផុតពីការទទួលទណ្ឌកម្មព្រហ្មទណ្ឌ ឬការសម្រាលនូវទោសព្រហ្មទណ្ឌដែលក្នុងចំណោមមូលហេតុទាំងនោះមានមូលហេតុដែលជនល្មើសជាអនីតិជន។ ដូច្នេះនៅក្នុងចំណុចនេះត្រូវស្វែងយល់អំពីការរួចផុតពីការទទួលខុសត្រូវរបស់អនីតិជនក្នុងបទល្មើសព្រហ្មទណ្ឌ ដែលមានមូលហេតុដូចជា៖

**១.៥.១ មូលហេតុទាក់ទងនឹងនីតិភាព**

យោងតាមគោលការណ៍ នៃព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានកំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺត្រឹមអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ[29] ហើយក៏អាចទទួលខុសត្រូវចាប់ពីអាយុ ១៤ (ដប់បួន) ឆ្នាំដល់ ១៨ (ដប់ប្រាំបី) ឆ្នាំផងដែរ។ ម៉្យាងវិញទៀតមិនថាមានកាលៈទេសៈណា ប្រសិនបើបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះជាអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ អនីតិជនប្រភេទនេះមិនត្រូវបានអនុញ្ញាតឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើសនេះត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ[30]។ ដោយអនីតិជនដែលស្ថិតក្នុងប្រភេទនេះមិនត្រូវបានធ្វើការឃាត់ខ្លួនឡើយ លើសពីនេះទៅទៀតសូម្បីតែការឃុំខ្លួនបណ្តោះអាសន្នដែលជាសិទ្ធិអំណាចផ្ទាល់តែមួយគត់របស់ចៅក្រមស៊ើបសួរក៏មិនអនុវត្តទៅបានដែរចំពោះអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ[31]។ ចៅក្រមស៊ើបសួរអាចសម្រេចត្រឹមតែប្រគល់អនីតិជននេះទៅឱ្យអាណាព្យាបាល ឬបើក្នុងករណីគ្មានអាព្យាបាលត្រូវប្រគល់ឱ្យទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ។ មួយវិញទៀត អនីតិជនដដែលនេះមិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ[32]។ សរុបជារួមមកអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះឡើយ។

**១.៥.២ មូលហេតុទាក់ទងនឹងបទល្មើស**

តាមការសិក្សាជាមួយក្រមព្រហ្មទណ្ឌ បានកំណត់អំពីបុគ្គលមួយចំនួនដែលច្បាប់តម្រូវលើកលែងទោសដែលជាការមិនខុសចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តឡើយ មិនថាបុគ្គលមានសមត្ថភាពពេញលេញក៏ដោយហើយបើចំពោះបុគ្គលដែលគ្មានសមត្ថភាពនឹងគ្មានកំហុស ច្បាប់នឹងធ្វើការលើកលែងទោសជាស្វ័យប្រវត្តិ។ ក្នុងករណីលើកលែងនេះផងដែរ ចំពោះបុគ្គលណាមួយសម្រាប់បទល្មើសណាមួយតម្រូវឱ្យច្បាប់ធ្វើការកំណត់ឱ្យ

[28] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[29] មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[30] មាត្រា ១៤ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[31] មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[32] មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បានជាក់លាក់។ ដូច្នេះហើយយើងនិងលើកយកបទបញ្ញត្តិដែលមានការលើកលែងទោសដោយក្រមព្រហ្មទណ្ឌ (ក) និងដោយច្បាប់ផ្សេងៗ (ខ) យើងនឹងធ្វើការបង្ហាញដូចតទៅះ

**ក. ក្រមព្រហ្មទណ្ឌ**

នៅក្នុងក្រមព្រហ្មទណ្ឌបានធ្វើការកំណត់អំពីបុគ្គលដែលច្បាប់តម្រូវឱ្យមានការលើកលែងចំពោះបទល្មើសមួយចំនួនដូចជាៈបទមិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង[33]បទមិនផ្តល់ភស្តុតាង នៃភាពគ្មានទោស និងលើកលែង[34]និងបទផ្តល់ជំនួយដល់ចារីជាអាទិ៍ និងការលើកលែង[35]ចំពោះបទល្មើសទាំងនេះ ច្បាប់បានធ្វើការកំណត់អំពីបុគ្គលដែលត្រូវលើកលែង គឺត្រូវលើកលែងចំពោះ ជីដូន ជីតា ឪពុក ម្តាយ មា មីង ចៅ កូន ក្មួយ បងប្អូន និងប្រពន្ធ ឬប្តី របស់ចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត រួមទាំងបុគ្គលដែលច្បាប់ឱ្យរក្សាអាថ៌កំបាំង នៃវិជ្ជាជីវៈ។ មួយវិញទៀត ចំពោះបទការផ្តល់សក្ខីកម្មក្លែងក្លាយ និងការលើកលែង ច្បាប់នឹងលើកលែងឱ្យសាក្សីដែលបានភូតកុហក ប្រសិនបើនេះប្រែក្រឡាស់ដោយឯកឯង នូវសក្ខីកម្មរបស់ខ្លួន ហើយនិយាយតែការពិតមុនសេចក្តីសម្រេចបញ្ចប់នីតិវិធីស៊ើបសួរ ឬនីតិវិធីជំនុំជម្រះ[36]។ បុគ្គលណាដែលមានឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកផ្សំគំនិតដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយដែលកំណត់នៅមាត្រា ៥៦១ (ទោសដែលត្រូវអនុវត្ត) និងពីមាត្រា ៥៦៣ (បទគំរាមកំហែងដោយអាវុធ ឬដោយសកម្មភាពដែលមានការព្រមព្រៀង) រហូតដល់មាត្រា ៥៧០ (ស្ថានទម្ងន់ទោស នៃអំពើជួយសម្រួលការលួចត់ប្រព្រឹត្តដោយបុគ្គលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ) ច្បាប់និងធ្វើការលើកលែងឱ្យរួចផុតពីទោស ប្រសិនបើបុគ្គលនេះឱ្យដំណឹងដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាល ដើម្បីកុំឱ្យមានការរត់នេះបានសម្រេចលទ្ធផល[37]។ ជាចុងក្រោយបទល្មើសដែលទាក់ទងនឹងរូបិយវត្ថុ (ពីមាត្រា ៦៤៥ ដល់មាត្រា ៦៥១) បុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមដែលលើកឡើងនឹងត្រូវបានលើកលែងឱ្យរួចផុតពីទោស ប្រសិនបើបុគ្គលនោះបានធ្វើឱ្យបទល្មើសនោះមិនបានសម្រេច និងនាំឱ្យដឹងពីអត្តសញ្ញាណជាយថាហេតុរបស់បទល្មើសផ្សេងៗទៀត ដោយបានផ្តល់ដំណឹងដល់អាជ្ញាធររដ្ឋបាល ឬតុលាការ[38]។ សរុបមកបទល្មើសខាងលើនេះជាប្រភេទបទល្មើសដែលក្រមព្រហ្មទណ្ឌធ្វើការលើកលែងទោសចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសស្របលក្ខខណ្ឌដែលច្បាប់បានកំណត់។

**ខ.ច្បាប់ផ្សេងៗទៀត**

[33] មាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[34] មាត្រា ៥៣៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[35] មាត្រា ៥៤៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[36] មាត្រា ៥៤៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[37] មាត្រា ៥៧៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[38] មាត្រា ៦៥២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ក្រៅពីបទល្មើសដែលមានចែងក្នុងក្រមទណ្ឌដែលបានកំណត់អំពីការរួចផុតពីទោសក៏មានអត្ថបទច្បាប់មួយចំនួនទៀតបានធ្វើការកំណត់ការរួចផុតពីទោសនូវបុគ្គលដែលបានប្រព្រឹត្តបទល្មើសផងដែរ។ ជនណាដែលរួមភេទជាមួយជនដទៃដែលមានអាយុតិចជាង ១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ[39]។ ចំណែកឯពាក្យថាអំពើអាសមានន័យថាជាអំពើនៃការប៉ះពាល់ ឬការបង្ហាញកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬការឱ្យជនដទៃប៉ះពាល់កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬរបស់តតិយជនក្នុងចេតនាធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ហើយជនណាដែលប្រព្រឹត្តអំពើអាសទៅលើជនដែលមានអាយុតិចជាង ១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០ រៀល ដល់ ៦,០០០,០០០ រៀល[40]។

[39] មាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨

[40] មាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨

# ជំពូកទី២
# នីតិវិធីរបស់ស្ថាប័នតុលាការក្នុងការអនុវត្តចំពោះអនីតិជន

# ជំពូកទី២
# នីតិវិធីរបស់ស្ថាប័នតុលាការក្នុងការអនុវត្តចំពោះអនីតិជន

## ២.១ ការបង្វែរអនីតិជនពីការផ្តន្ទាទោស

ការបង្វែរ ជាវិធានការដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើសហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែនចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ។ អាជ្ញាធរទទួលបន្ទុកបង្វែររួមមានតំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ នៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាឧទ្ធរណ៍។

ក្នុងករណីត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកការបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើនសម្រាប់ឱ្យអនីតិជនបំពេញកាតព្វកិច្ចដូចជាចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការទៅសាលារៀនឱ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ ខែចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ ខែ តម្រូវឱ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងថិរវេលាមិនលើសពី ៦ ខែ ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ ម៉ោង ហើយការងារសហគមន៍នេះសម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំឡើងទៅ ហើយមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។ ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានប្រយោជន៍សម្រាប់ជួយអនីតិជនមិនឱ្យប្រព្រឹត្តបទល្មើសសារជាថ្មី ស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់ និងជួសជុលសំណងការខូចខាតទៅជនរងគ្រោះ។ រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារត្រូវអនុលោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់[41]។

### ២.១.១ គោលបំណង និងគោលការណ៍

ការបង្វែរអនីតិជនមានគោលបំណងដូចជាលើកទឹកចិត្តអនីតិជនឱ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង ជំរុញឱ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន លើកទឹកចិត្តឱ្យមានការជួលជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ច្រាសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើស

[41] មាត្រា ៦៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសារជាថ្មី និងបង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិជាប់ទោសក្នុងបញ្ជីថ្កោលទោស[42]។

### ២.១.២ លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកនូវវិធានការមួយ ឬច្រើន សម្រាប់ឱ្យអនីតិជនបំពេញជាកាតព្វកិច្ច។ ផែនការយុត្តិសាស្ត្រក៏បានគាំទ្រឱ្យមានការប្រើប្រាស់ជម្រើសផ្សេងក្រៅពីការដាក់ពន្ធនាគារបន្ថែមពីលើវិធានការបង្វែរផងដែរ ដើម្បីធានាឱ្យបានថា ការឃុំខ្លួន គឺជាវិធានការចុងក្រោយបង្អស់ ហើយស្ថិតក្នុងរយៈពេលខ្លីបំផុតក្រៅពីការឃុំខ្លួនមុនពេលធ្វើសវនាការផងដែរ។ នៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចង្អុលបង្ហាញជាពិសេសលើវិធានការបង្វែរនេះ ក៏ដូចជាកំណត់លក្ខខណ្ឌជាអប្បបរមា និងលក្ខណៈវិនិច្ឆ័យជាក់លាក់ថាតើនៅពេលណាដែលវិធានការបង្វែរនេះគួរតែត្រូវយកមកពិចារណា និងថាតើនៅពេលណាវិធានការជាក់លាក់លម្អិតអាចត្រូវបានអនុវត្តក្រោមវិធានការបង្វែរនេះ។

**លក្ខខណ្ឌអប្បបរមា នៃការបង្វែរ រួមមាន៖**[43]

- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន។
- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ។
- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬមជ្ឈិម។
- អនីតិជនយល់ព្រមឱ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែរ។

**លក្ខណៈវិនិច្ឆ័យ នៃការបង្វែរ រួមមាន៖**[44]

- កាលៈទេសៈនៃបទល្មើស។
- ស្ថានភាពនៃបទល្មើស។
- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត។
- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន។
- ព្យសនកម្មរបស់ជនរងគ្រោះ និង
- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គមផងដែរ។

---

[42] មាត្រា ៦២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[43] មាត្រា ៦៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[44] មាត្រា ៦៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ២.១.៣ ការរៀបចំបង្កើតផែនការបង្វែរ

ក្រោយពីបានទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកការបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន។ ក្នុងការបង្កើតផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម៖[45]

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន។

ផែនការបង្វែរសម្រាប់អនីតិជនត្រូវ៖

- ផ្តល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឱ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះ នៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត
- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ចៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឱ្យអន្តរាយ ឬធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង
- មិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ។

### ២.១.៤ ការអនុវត្តផែនការបង្វែរ

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធានាការពាររងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ។

[45] មាត្រា ៦៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាននៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួនទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត។

### ២.១.៥ ការកែប្រែវិធានការបង្វែរ

ក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកការបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន។ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច ប៉ុន្តែក្នុងករណីអាជ្ញាធរទទួលបន្ទុកការបង្វែរមិនបានសម្រេចក្នុងថិរវេលានេះត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ។ ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ។

### ២.១.៦ ការបរាជ័យនៃវិធានការបង្វែរ

ការបរាជ័យក្នុងការអនុវត្តផែនការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ។ ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការមិនគោរពកាតព្វកិច្ចដែលបានកំណត់នៅក្នុងវិធានការបង្វែរ ឬក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែរួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកការបង្វែរដើម្បីសម្រេចដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត។

អាជ្ញាធរទទួលបន្ទុកការបង្វែរត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមវិធានការបង្វែរ ក្រោយពីបានពិចារណាអំពីទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និង បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកការបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

ក្នុងករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប អាជ្ញាធរទទួលបន្ទុកការបង្វែរត្រូវបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

## ២.២ នីតិវិធីអនុវត្តចំពោះអនីតិជន

នីតិវិធីដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន ក៏មានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីអនុវត្តចំពោះនីតិជនដែរ។ ដោយហេតុថានីតិវិធីនេះតម្រូវឱ្យមានការឆ្លងកាត់ពីសំណាក់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាល

យុត្តិធម៌ ចំណាត់ការសំណុំរឿងរបស់ស្ថាប័នអយ្យការ ការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះធ្វើឡើងនៅក្នុងសវនាការជាអាទិ៍។

**២.២.១ ដំណាក់កាលនគរបាលយុត្តិធម៌**

នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនមានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង។ នគរបាលយុត្តិធម៌ដែលចាប់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួនអនីតិជនត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្តីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជនទៅឱ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកលើអនីតិជនមានអំណាចនៅក្នុងការបំពេញកិច្ចរបស់ខ្លួន ដោយផ្អែកទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលកិច្ចទាំងនោះអាចជាការចាប់ខ្លួន ការឆែកឆេរ ការឃាត់ខ្លួន ការជូនដំណឹង ការស្តាប់ចម្លើយ និងការបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា។

**២.២.១.១ ការចាប់ខ្លួន**

នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទល្មើសបទមជ្ឈិម ឬឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា។ រាល់ការចាប់ខ្លួនមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបន្ទាប់ពីការចាប់ខ្លួនអនីតិជននោះ។ ក្នុងករណីមិនអាចជូនដំណឹងនេះជាបន្ទាន់ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើទៅបានអំពី៖[46]

- មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស
- ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ
- សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាពនគរបាល។

ទោះបីជាយ៉ាងណាក៏ដោយការចាប់ខ្លួនគួរតែអនុវត្តសម្រាប់វិធានចុងក្រោយបំផុតប៉ុណ្ណោះ។ ការចាប់ខ្លួនត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់ ទោះបីជាការចាប់ខ្លួននោះត្រូវធ្វើឡើងដោយដីកាចាប់ខ្លួនតាមភស្តុតាងស៊ីសង្វាក់ ឬតាមបទល្មើសជាក់ស្តែងក្តី។ ច្បាប់ចម្លងនៃកំណត់ហេតុស្តីពីការចាប់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនត្រូវផ្តល់ឱ្យមេធាវីតាមការស្នើសុំ។

**២.២.១.២ ការឆែកឆេរ**

[46] មាត្រា ១៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើបុគ្គលដែលជាអនីតិជនបាន។ ការឆែកឆេរខ្លួនបុគ្គលដែលធ្វើឡើងត្រូវតែជាភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និតជាមួយអនីតិជននោះឡើយ លើកលែងតែករណីមិនអាចជៀសវាងបាន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ និងចុះនិទ្ទេសអំពីបញ្ហានេះ។

### ២.២.១.៣ ការឃាត់ខ្លួន

អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនអនីតិជនបាន ប្រសិនបើជឿជាក់ថាអនីតិជននោះអាចរត់គេចខ្លួន និងបង្កផលប៉ះពាល់ទៅដល់ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ[47]។ ដោយឡែកករណីអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ ១៦ ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនាប៉ុណ្ណោះ ហើយរាល់ការឃាត់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធានាឱ្យបាននូវសុវត្ថិភាពរបស់អនីតិជន ដោយមិនត្រូវឱ្យអនីតិជនទទួលរងនូវការធ្វើទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬអាចទទួលរងនូវអំពើអមនុស្សធម៌ណាមួយឡើយ។ រាល់ការឃាត់ខ្លួនអនីតិជនត្រូវដាក់ដោយឡែកពីនីតិជន និងទៅតាមភេទ។

រយៈពេល នៃការឃាត់ខ្លួនអនីតិជនមិនត្រូវបានពន្យាឡើយ ហើយការឃាត់ខ្លួនត្រូវអនុវត្តយ៉ាងជាក់លាក់តាមការកំណត់៖

- អនីតិជនដែលបានប្រព្រឹត្តបទមជ្ឈិម ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ។ ប៉ុន្តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការឃាត់ខ្លួនបានមិនឱ្យលើសរយៈពេល ៣៦ ម៉ោងបានទេ។

អនីតិជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។ ប៉ុន្តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការឃាត់ខ្លួនមិនឱ្យលើសរយៈពេល ៤៨ម៉ោង បានទេ។

**តារាងរយៈពេលឃាត់ខ្លួន[48]**

[47] មាត្រា ១៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[48] សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ទំព័រ ២៤ រៀបរៀងដោយឧត្តមសេនីយ៍ត្រី អាន សូវីដា

| អាយុ | ក្រោម១៤ឆ្នាំ | ពី ១៤ឆ្នាំ ទៅក្រោម ១៦ឆ្នាំ | ពី ១៦ឆ្នាំ ទៅក្រោម ១៨ឆ្នាំ |
|---|---|---|---|
| បទមជ្ឈិម | មិនអាចឃាត់ | ២៤ ម៉ោង | ៣៦ ម៉ោង |
| បទឧក្រិដ្ឋ | មិនអាចឃាត់ | ៣៦ ម៉ោង | ៤៨ ម៉ោង |

**២.២.១.៤ ការស្តាប់ចម្លើយ**

មុនពេលចាប់ផ្តើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋាន និងសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវីដូចទៅនឹងនីតិវិធីអនុវត្តចំពោះបុគ្គលដែលជានីតិជនដែរ។ អនីតិជនទទួលបាននូវសិទ្ធិសន្ទនាជាលក្ខណៈឯកជន និងជាសម្ងាត់ជាមួយមេធាវី អ្នកតំណាង ភ្នាក់ងារសង្គមកិច្ច ប្រសិនបើមានការស្នើសុំ។ បន្ទាប់ពីធ្វើការស្តាប់ចម្លើយភ្លាម អនីតិជន និងបុគ្គលដែលបានរៀបរាប់ខាងលើអាចអាន និងធ្វើការពិនិត្យកំណត់ហេតុស្តាប់ចម្លើយបាន ហើយអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបានមុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ។

**២.២.១.៥ ការបញ្ជូននីតិវិធី**

មន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតរបស់ខ្លួនឱ្យបានឆាប់ និងលឿនបំផុតតាមដែលអាចធ្វើទៅបានសម្រាប់ជាប្រយោជន៍ដល់អនីតិជន ដោយហេតុថារយៈពេលនៃការឃាត់ខ្លួនរបស់អនីតិជនមានរយៈពេលត្រឹមតែ ៤៨ ម៉ោងតែប៉ុណ្ណោះ ហើយមិនអាចពន្យាពេលឃាត់ខ្លួនបានទេ។ នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬដោះលែងឱ្យមានសេរីភាពឡើងវិញ។ សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។ កាលណាបុគ្គលដែលត្រូវឃាត់ខ្លួនត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញានោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន។ មូលហេតុនៃការយឺតយ៉ាវត្រូវចុះក្នុងកំណត់ហេតុដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌[49]។

ក្រោយពីធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ហើយ ប៉ុន្តែក្នុងករណីគ្មានតម្រុយពីបទល្មើសដែលអនីតិជននោះបានប្រព្រឹត្តនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការដោះលែងអនីតិជននោះឱ្យត្រឡប់ទៅវិញដោយមានការធានាពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជន។

**២.២.២ដំណាក់កាលអយ្យការ**

[49] មាត្រា ១០៤ កថាខណ្ឌទី៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ក្រោយពីទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការត្រូវធ្វើការអនុវត្តនូវបណ្តឹងអាជ្ញា ដោយត្រួតពិនិត្យទៅលើសំណុំរឿង និងធ្វើការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌដែលច្បាប់បានកំណត់។ ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ត្រូវឱ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឱ្យកាន់រឿងក្តីអនីតិជន ទោះជាការចាត់តាំងនោះឱ្យធ្វើតែរឿងអនីតិជនដាច់ខាត ឬមិនដាច់ខាតក្តី តំណាងអយ្យការដែលនឹងត្រូវចាត់ឱ្យកាន់រឿងអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទបញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន។ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ[50]។ តំណាងអយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌតាមរយៈការបើកធ្វើការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[51]។

### ២.២.២.១ ការកំណត់អំពីនីតិភាពអនីតិជន

ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាអនីតិជនពិតជាគ្រប់អាយុ ឬលើសអាយុ ១៤ ឆ្នាំ ដែលអាចទទួលខុសត្រូវចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះហើយព្រះរាជអាជ្ញាត្រូវត្រួតពិនិត្យអាយុអនីតិជនលើឯកសារផ្លូវការដែលអាចជឿទុកចិត្តបាន ដូចជាសំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬឯកសារផ្សេងៗទៀតជាអាទិ៍។ ប្រសិនបើតំណាងអយ្យការត្រួតពិនិត្យឃើញថា អនីតិជននោះមានអាយុក្រោម ១៤ ឆ្នាំ គិតពីថ្ងៃដែលត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងឥតចាត់ការ និងប្រគល់អនីតិជននោះ ទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញ។

### ២.២.២.២ ការបើកការស៊ើបអង្កេត

ការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរចេញដោយព្រះរាជអាជ្ញា ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរមានៈ

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

[50] មាត្រា ៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។

ប្រសិនបើព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថាអំពើប្រព្រឹត្តនោះមានសហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឱ្យដាច់ដោយឡែកពីគ្នា[52]។

### ២.២.២.៣ ការស្តាប់ចម្លើយ

ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយអំពីសិទ្ធិជាមូលដ្ឋានដោយប្រើភាសា និងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជនមុនពេលធ្វើការស្តាប់ចម្លើយ។ ការស្តាប់ចម្លើយអនីតិជនត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវីការពារ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច។ បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុចម្លើយបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឱ្យអនីតិជនស្តាប់។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបានមុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ។ ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឱ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានការស្នើសុំ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ[53]។

### ២.២.២.៤ ការតម្កល់រឿងឥតចាត់ការ

ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើមូលហេតុដូចជា៖[54]

- មរណភាពនៃជនល្មើស
- បណ្តឹងអាជ្ញាត្រូវបានផុតរលត់
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

[52] មាត្រា ៣០ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[53] មាត្រា ២៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[54] សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ទំព័រ ៥៧ រៀបរៀងដោយ ឧត្តមសេនីយ៍ត្រី អាន សុវីដា

- អាជ្ញាអស់ជំនុំ

ក្រៅពីមូលហេតុខាងលើនេះ ព្រះរាជអាជ្ញាក៏អាចតម្កល់រឿងទុកឥតចាត់ការបានដែរដូចជា៖

- អង្គហេតុនៃរឿងមិនមែនជារឿងព្រហ្មទណ្ឌ
- គោលការណ៍កាលានុវត្តភាព មានន័យថាអង្គហេតុនៃរឿងជារឿងព្រហ្មទណ្ឌ ប៉ុន្តែវាជាបទល្មើសតូចតាច។

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងហេតុ និងសំអាងច្បាប់ ហើយវាគ្មានអាជ្ញាអស់ជំនុំទេ មានន័យថាព្រះរាជអាជ្ញាអាចសើរើ កែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបាន ក្នុងករណីបណ្តឹងអាជ្ញាមិនទាន់រលត់។

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន[55]។

### ២.២.២.៥ ការបង្វែររបស់តំណាងអយ្យការ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី១០ (ការបង្វែរ) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ក្នុងករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទបញ្ញត្តិនៃជំពូកទី១០ នៃច្បាប់នេះ ត្រូវយកមកអនុវត្ត។ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អែកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច។

ប្រសិនបើការរៀបចំការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឱ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់។ ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។

[55] មាត្រា ២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឱ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នក

តំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី[56]។

### ២.២.៣ ដំណាក់កាលស៊ើបសួរ

ដំណាក់កាលស៊ើបសួរ គឺជាដំណាក់កាលដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ហើយក៏ជាដំណាក់កាលមួយដែលមានសារៈសំខាន់នៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ដែលចៅក្រមស៊ើបសួរធ្វើការប្រមូលភស្តុតាងចាំបាច់ពាក់ព័ន្ធសម្រាប់សម្រេចសេចក្ដីចំពោះការចោទប្រកាន់មុននឹងបិទការស៊ើបសួរ។ នៅក្នុងការស៊ើបសួរណាដែលទាក់ទងនឹងអនីតិជន គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន[57]។

#### ២.២.៣.១ ការបើកការស៊ើបសួរ

ការស៊ើបសួរត្រូវបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា មានន័យថាចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជ-អាជ្ញាបានទេ។ ចៅក្រមស៊ើបសួរអាចបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់[58]។ ចៅក្រមស៊ើបសួរស្វែងរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុកដែលខុសពីព្រះរាជអាជ្ញាគឺស្វែងរកភស្តុតាងតែដាក់បន្ទុកប៉ុណ្ណោះ[59]។

#### ២.២.៣.២ ការបង្វែររបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ឬបទមជ្ឈិមមានស្ថានទម្ងន់ទោស។ ក្នុងករណីចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឱ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការ

---

[56] មាត្រា ២៨ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[57] មាត្រា ៣១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[58] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[59] មាត្រា ៣២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បង្វែរ ទោះបីផែនការបង្វែរនោះត្រូវការពេលវេលារៀបចំក៏ដោយ។ ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរបានជោគជ័យ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ប៉ុន្តែបើអនីតិជនអនុវត្តផែនការបង្វែងមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីបានដោយពិចារណាទៅលើមូលហេតុដែលនាំឱ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ។[60]

### ២.២.៣.៣ ការឃុំខ្លួនបណ្តោះអាសន្ន

កាឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដែលផ្តល់អំណាចធំបំផុតទៅឱ្យចៅក្រមស៊ើបសួរ ប៉ុន្តែវិធាននេះប៉ះពាល់ដល់សេរីភាពរបស់ជនត្រូវចោទ ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីហើយការឃុំខ្លួនបុគ្គលណាម្នាក់ត្រូវមានសេចក្តីសម្រេចស្ថាពរពីតុលាការ។ តែដោយយោងទៅលើភាពចាំបាច់ដើម្បីឱ្យការស៊ើបសួរប្រព្រឹត្តទៅបានល្អ ចៅក្រមស៊ើបសួរអាចចេញដីកាឃុំខ្លួនបណ្តោះអាសន្នបាន ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនជាវិធានចុងក្រោយ។

អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នបានឡើយ។ ក្នុងករណីអ-នីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ។[61]

ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ។

មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នមានដូចជា៖[62]

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

[60] មាត្រា ៣៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[61] មាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[62] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

បន្ថែមលើបទបញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពរបស់អនីតិជនផងដែរ ប្រសិនបើមាន។[63]

**ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[64]**

| អាយុ | ក្រោម ១៤ឆ្នាំ | ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ | ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ |
|---|---|---|---|
| បទមជ្ឈិម | 0 | ២ខែ + 0 | ៤ខែ + 0 |
| បទឧក្រិដ្ឋ | 0 | ៤ខែ + 0 | ៦ខែ + 0 |

ចៅក្រមស៊ើបសួរមិនអាចសម្រេចពន្យាការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនបានទេ។

### ២.២.៣.៤ ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការដែលកាត់បន្ថយសេរីភាពមួយចំនួនប៉ុណ្ណោះ ដោយឱ្យជនត្រូវចោទនៅក្រៅឃុំ តែត្រូវគោរពកាតព្វកិច្ចមួយ ឬច្រើននៃមាត្រា ២២៣ (កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ដោយមិនកំណត់ពេលវេលាទេ គឺអាស្រ័យទៅលើចៅក្រមស៊ើបសួរជាអ្នកកែប្រែ ឬលុបចោលបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទ ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ក្នុងករណីជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។

ការត្រួតពិនិត្យតាមផ្លូវតុលាការមានគោលដៅសំខាន់ៗខាងក្រោមៈ[65]

- ដើម្បីធានាឱ្យជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។
- បន្ថយសេរីភាពមួយចំនួន កុំឱ្យកើតបទល្មើសបន្តទៀត។
- ដាក់កំហិតនូវការព្យាបាលផ្នែកសង្គម និងផ្នែកវិជ្ជសាស្ត្រ។
- ដាក់ប្រាក់ធានាដើម្បីទុកសងការខូចខាតដល់ជនរងគ្រោះ។

---

[63] មាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[64] សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ទំព័រ ៧៩ រៀបរៀងដោយ ឧត្តមសេនីយ៍ អាន សុរីដា

[65] សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ទំព័រ ៨៤ រៀបរៀងដោយ ឧត្តមសេនីយ៍ អាន សុរីដា

បន្ថែមលើបទបញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖[66]

- ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប
- ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឱ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប។

**២.២.៣.៥ ការដោះលែងឱ្យនៅក្រៅឃុំ**

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នលែងចាំបាច់ មានន័យថាបទបញ្ញត្តិនៃមាត្រា ២០៥ លែងចាំបាច់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ដោយជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងអនីតិជននៅក្រៅឃុំភ្លាមបាន ដោយមិនចាំបាច់សុំយោបល់ព្រះរាជអាជ្ញា ប៉ុន្តែត្រូវបញ្ជាក់ពីមូលហេតុនៃការបន្ទាន់នេះក្នុងដីកាសម្រេចរបស់ខ្លួន។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ។[67]

**២.២.៣.៦ ការបិទការស៊ើបសួរ**

នៅពេលចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ នៅពេលដែលព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញាអាចប្តឹងសុំចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់[68]។

**២.២.៣.៧ ដីកាដំណោះស្រាយ**

[66] មាត្រា ៤០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[67] មាត្រា ៤១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[68] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដីកាដំណោះស្រាយធ្វើឡើងដោយចៅក្រមស៊ើបសួរ ដោយត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងភាគីពាក់ព័ន្ធទាំងអស់។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់។ រាល់ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ[69]។ មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្តីពីការប៉ានប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីរបាយការណ៍ស្តីពីការប៉ានប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឱ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើបាន ដោយមិនឱ្យលើសរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។ ចំពោះដីកាដំណោះស្រាយលើកលែងចោទប្រកាន់មានអានុភាពនាំឱ្យដោះលែងអនីតិជនដែលជាប់ឃុំទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ[70]។

ក្នុងករណីជនត្រូវចោទកំពុងឃុំខ្លួនបណ្តោះអាសន្ន ក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ ដោយស្របនឹងមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន។ សេចក្តីសម្រេចអានុភាពរយៈពេល ៤ខែ។ ប៉ុន្តែក្នុងករណីដែលជនត្រូវចោទត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដីកាដំណោះស្រាយគឺជាសេចក្តីសម្រេចមួយមានអានុភាពបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

### ២.២.៤ ដំណាក់កាលជំនុំជម្រះ

#### ២.២.៤.១ សមត្ថកិច្ចរបស់សាលាដំបូង

សាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន ជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន។ សាលាដំបូងសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម។

តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន។ ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំជំនុំជម្រះ តុលាការត្រូវពិចារណា

[69] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[70] មាត្រា ៤២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឱ្យមានសេរីភាព ករណីដែលរឿងក្ដីត្រូវបានលើកពេលជំនុំជម្រះ តុលាការត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឱ្យមានសេរីភាព[71]។

**ក. នីតិវិធីមុនពេលសវនាការ**

មុនពេលសវនាការ តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្ដល់ដោយភ្នាក់ងារសង្គមកិច្ច។ ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឱ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះ តាមតម្រូវការ[72]។

**ខ. សវនាការ**

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី។ ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្ដាប់ចម្លើយ។ ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្ដីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ មានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្ដីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការលើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្ដមប្រយោជន៍របស់អនីតិជន។

ជំនួយរបស់មេធាវីត្រូវតែមានជាច់ខាតនៅក្នុងសវនាការ បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្ដើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។ សោហ៊ុយសម្រាប់ធ្វើការ ចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ។ តុលាការត្រូវផ្ដល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿង ទៅឱ្យមេធាវីសម្រាប់រៀបចំការការពារ។ សោហ៊ុយសម្រាប់ធ្វើការចម្លងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន។[73]

នៅពេលចាប់ផ្ដើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បានអំពីសិទ្ធិដូចខាងក្រោម៖[74]

[71] មាត្រា ៤៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[72] មាត្រា ៤៦ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[73] មាត្រា ៥០ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[74] មាត្រា ៥១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោម និងសិទ្ធិប្តឹងឧទ្ធរណ៍។

តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រ គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ។ ចម្លើយសារភាពមិនត្រូវចាត់ទុកជាភស្តុតាង នៃពិរុទ្ធភាពឡើយ។

ក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឱ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឱ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ ក្នុងករណីអនីតិជនពិតជាបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានដើមបណ្តឹងរដ្ឋប្បវេណី។

ការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែលសម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ។ ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស។

### គ. អំណាចរបស់តុលាការក្នុងការបង្វែរ

នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ ក្រោម ១៨ ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម តុលាការត្រូវពិចារណាជាបឋម ទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី១០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោសអាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ។ ក្នុងលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញ តុលាការត្រូវចេញសាលក្រមបង្អង់រឿងទុកសិន បន្ទាប់មកត្រូវ៖

- ពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធផ្សេងទៀត
- រៀបចំផែនការបង្វែរ
- ឱ្យអនីតិជនចុះហត្ថលេខា ឬផ្តិតម្រាមដៃអនុវត្តផែនការបង្វែរ។

តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ។ ប្រសិនបើអនីតិជនកំពុងជាប់ឃុំ តុលាការត្រូវបង្គាប់ឱ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជ-

អាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីដែលអនីតិជនត្រូវការការពារ និងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព។

ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យនូវផែនការបង្វែរ ដោយមានរបាយការណ៍បញ្ជាក់រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ តុលាការត្រូវចេញសាលក្រមសម្រេចឱ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែបើក្នុងករណីការអនុវត្តផែនការបង្វែរបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឱ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនរបស់អនីតិ-ជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី។

**ឃ. ការប្រកាសសាលក្រម**

សាលក្រមត្រូវបានប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ ជាគោលការណ៍សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្ដី។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ[75]។

**២.២.៤.២ សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់**

សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពជាចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប[76]។ សាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវលើកយករឿងក្ដីរបស់អនីតិជនមកចាត់ការជំនុំជម្រះជាអាទិភាព ពិសេសរឿងក្ដីអនីតិជនជាប់ឃុំ។

សាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវលើកយករឿងក្ដីរបស់អនីតិជនមកចាត់ការ ជំនុំជម្រះជាអាទិភាពពិសេសរឿងក្ដីអនីតិជនដែលជាប់ឃុំ។ ចំពោះរឿងក្ដីដែលអនីតិជនជាប់ឃុំ ត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ (បី) ខែ យ៉ាងយូរគិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសត្យានុម័តដែលមិនអាចជម្រះបាន។ ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឱ្យមានសេរីភាព។ ក្នុងករណីរឿងក្ដីត្រូវបានលើកពេល

[75] មាត្រា ៥៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[76] មាត្រា ៥៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឱ្យមានសេរីភាព។

**ក. ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ និងតុលាការកំពូល**

ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្ដឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជម្រះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន។ ក្នុងករណីមានបណ្ដឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅតុលាការកំពូលក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្ដឹងសាទុក្ខ លើកលែងតែមានកាលៈទេសៈមិនអាចជម្រះបានដែលត្រូវតែមានបញ្ជាក់ក្នុងលិខិតបញ្ជូន។

**ខ. អំណាចរបស់សាលាឧទ្ធរណ៍ក្នុងការបង្វែរ**

បទបញ្ញត្តិមាត្រា ៥២ (អំណាចរបស់តុលាការក្នុងការបង្វែរ) នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ត្រូវយកមកអនុវត្តចំពោះអំណាចក្នុងការបង្វែររបស់សាលាឧទ្ធរណ៍។ រាល់វិធានដែលត្រូវអនុវត្តចំពោះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធាននោះមានភាពផ្ទុយពីលក្ខណៈនៃវិធានដែលអនុវត្តនៅតុលាការជាន់ខ្ពស់[77]។

[77] មាត្រា ៥៨ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# ជំពូកទី៣
# ទោសព្រហ្មទណ្ឌចំពោះអនីតិជន

# ជំពូកទី៣

# ទោសព្រហ្មទណ្ឌចំពោះអនីតិជន

## ៣.១ ប្រភេទទោសដែលអនុវត្តចំពោះអនីតិជន

បទល្មើសព្រហ្មទណ្ឌទាំងឡាយដែលជនល្មើសបានប្រព្រឹត្តទោះដោយចេតនាក្តី ឬអចេតនាក្តី ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដែលអំពើទាំងនោះបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមជាតិ ជនទាំងនោះត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេ។ យោងតាមគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗ ដោយត្រូវទទួលទោសព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ[78] ពុំអាចបុគ្គលណាម្នាក់មកទទួលទោសជំនួសបានឡើយ។ កាលបើបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ មានអាយុគ្រប់តាមដែលច្បាប់បានកំណត់ នោះច្បាប់នឹងធ្វើការផ្តន្ទាទោសតាមទំហំនៃអំពើដែលបុគ្គលនោះបានប្រព្រឹត្ត។ នៅក្នុងប្រទេសកម្ពុជានីតិភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ អញ្ញត្រកម្មអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅក៏ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ចំពោះអំពើល្មើសរបស់ពួកគេ។ ដូច្នេះហើយថា តើទណ្ឌកម្មចំពោះអ-នីតិជនមានលក្ខណៈដូចគ្នាទៅនឹងមនុស្សពេញវ័យដែរឬទេ? ហើយចំពោះប្រភេទនៃទោស មានដូចជា មូលទោស ទោសបន្ថែម ទោសការងារសហគមន៍ ការព្យួរទោសសាកល្បង តើអាចអនុវត្តចំពោះអនីតិជនទេ ហើយការអនុវត្តមានលក្ខណៈដូចម្តេចខ្លះ? បន្ទាប់មកយើងនឹងធ្វើស្វែងយល់នូវអត្ថបទខាងក្រោម៖

### ៣.១.១ មូលទោស

យោងតាមក្រមព្រហ្មទណ្ឌ មូលទោសជាប្រភេទទោសមួយក្នុងចំណោមប្រភេទទោសដែលផ្តន្ទាទោសដល់ជនល្មើសដែលបានបង្កឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសង្គមជាតិ។ មូលទោស គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស ឬជាទោសមួយប្រភេទដែលតុលាការព្រហ្មទណ្ឌអាចសម្រេចប្រកាសផ្តន្ទាទោសរួម ឬដាច់ដោយឡែកតែឯងបានពីទណ្ឌកម្មផ្សេងទៀត[79]ក៏បានអាស្រ័យលើការយល់ឃើញរបស់ចៅក្រមដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់ដែលមានកំណត់ជាធរមាន។ មួយវិញទៀតមូលទោសគឺជាប្រភេទទោសមានទាំងការពិន័យជាប្រាក់ និងផ្តន្ទាទោសដាក់ពន្ធនាគារ[80]។ ចំពោះប្រព័ន្ធគតិយុត្ត នៃទោសសម្រាប់អនុវត្តចំពោះអនីតិជនមានភាពខុសប្លែកពីរបបគតិយុត្តដែលអនុវត្តចំពោះនីតិជន ពោលគឺមានរបបគតិយុត្តពិសេសអំពីរបបទោសរបស់អនីតិជន។ យោងតាមក្រមព្រហ្មទណ្ឌបានធ្វើការ

[78] មាត្រា ៧២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[79] សៀវភៅនីតិព្រហ្មទណ្ឌទូទៅ ទំព័រ ៨០ រៀបរៀងដោយ សាស្ត្រាចារ្យ ហ៊ាង ឡេង

[80] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

កំណត់អំពីរបបគតិយុត្តពិសេសសម្រាប់អនីតិជនដែលមានន័យថានៅក្នុងរបបគតិយុត្តនោះ កំណត់តែទោសដែលអនុវត្តចំពោះអនីតិជនតែប៉ុណ្ណោះ ដោយបានធ្វើការកំណត់ថាកាលណាដែលតុលាការបានធ្វើការសម្រេចសេចក្តីផ្តន្ទាទោសទៅលើអនីតិជនដែលជាជនល្មើសបទល្មើសព្រហ្មទណ្ឌ ហើយអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំនោះ។ ការផ្តន្ទាទោសចំពោះអនីតិជននឹងមានការសម្រាលឱ្យតិចជាងទណ្ឌកម្មរបស់នីតិជនដែលមានលក្ខណៈដូចជា[81]៖

- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។
- ប្រសិនបើអតិបរមា នៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី១(មួយ)ថ្ងៃ។
- អប្បបរមា និងអតិបរមា នៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។
- ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទបញ្ញត្តិនៃមាត្រានេះ មានអនុភាពបន្ថយ អតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

បានជាមានការកំណត់បែបនេះ ដោយហេតុថាអនីតិជន គឺជាជនដែលមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិចារណា វិនិច្ឆ័យឱ្យច្បាស់លាស់នូវអំពើរបស់ខ្លួនថាខុស ឬក៏ត្រូវ ដែលលក្ខណៈខុសពីនីតិជន ហើយការទទួលខុសត្រូវរបស់អនីតិជនត្រូវបានកម្រិតដោយច្បាប់[82] និងគោរពតាមគោលការណ៍នូវច្បាប់អន្តរជាតិដែលកម្ពុជាបានទទួលស្គាល់។ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ គឺមានន័យថាតុលាការមិនអាចធ្វើការសម្រេចផ្តន្ទាទោសទៅលើអនីតិជនប្រភេទនេះបានទេ សូម្បីតែការចោទតាមនីតិវិធីព្រហ្មទណ្ឌ ក៏មិនអាចចោទប្រកាន់ទៅលើអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំផងដែរ ដែលជាទូទៅចៅក្រមមិនធ្វើការចោទប្រកាន់ទេ។

### ៣.១.២ ទោសបន្ថែម

ទោសបន្ថែម គឺជាប្រភេទមួយនៃទោសព្រហ្មទណ្ឌដែលតុលាការមិនអាចសម្រេចផ្តន្ទាទោសដាច់ដោយឡែកតែឯងបានទេ តែជាប្រភេទទោសដែលតុលាការអាចផ្តន្ទាទោសបន្ថែមទៅលើមូលទោសឱ្យកាន់តែមានទម្ងន់ នៃទោសធ្ងន់ធ្ងរបន្ថែមទៀត[83]។ ទោសបន្ថែមបង្កើតឡើងក្នុងគោលបំណងឱ្យការដាក់ទណ្ឌកម្មមានភាព

---

[81] មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[82] សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ លេខរៀងទី១៦០

[83] សៀវភៅនីតិព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌខ្មែរ ឯកឧត្តម សេង ស៊ីវុត្ថា

កម្រិតសមស្របទៅនឹងអំពើល្មើសដែលបានប្រព្រឹត្ត ឬនិយាយម្យ៉ាងទៀតបានថាដើម្បីធានាដល់ការអនុវត្តគោលការណ៍ឯកត្តកម្ម នៃទោស។

ចំពោះទោសបន្ថែមដែលអនុវត្តចំពោះអនីតិជនក៏បានធ្វើការកំណត់ដាច់ដោយឡែកពីនីតិជនផងដែរ ដែលទោសបន្ថែមរបស់អនីតិជនមានដូចជា[84]៖

- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទ។

ជាក់ស្តែងទោសបន្ថែមនេះអាចអនុវត្តបានតែចំពោះអនីតិជនដែលមានអាយុចាប់ ១៤ (ដប់បួន) ឆ្នាំឡើងតែប៉ុណ្ណោះ ដោយសារតែអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ គឺច្បាប់មិនអនុញ្ញាតឱ្យអនុវត្តមូលទោស ដូច្នេះហើយទោសបន្ថែមក៏មិនអាចអនុវត្តទៅលើអនីតិជនបានទេ។ ពីព្រោះទោសបន្ថែម គឺជាទោសដែលត្រូវបានចៅក្រមសម្រេចបន្ថែមទៅលើមូលទោស ដែលយើងអាចនិយាយបានថា បើគ្មានការអនុវត្តមូលទោសទេ ស្មើនឹងគ្មានការអនុវត្តទោសបន្ថែមដូចគ្នាដែរ។

**៣.១.៣ ទោសសហគមន៍**

ជាទូទៅទោសការងារសហគមន៍ ជាផ្នែកមួយនៃទោសព្រហ្មទណ្ឌដែលតុលាការអាចប្រកាសផ្តន្ទាទោសទៅលើជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនោះត្រូវផ្តន្ទាទោសជាប់ពន្ធនាគារដែល មានអតិបរមាតិចជាង ឬស្មើនឹង ៣ ឆ្នាំ នឹងមានថិរវេលាក្នុងការបំពេញកិច្ចការត្រូវចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ[85]។ ចំណែកឯទោសសហគមន៍ដែលអាចអនុវត្តចំពោះអនីតិជនបាន លុះត្រាតែអ-នីតិជននោះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។ ហើយចំពោះថិរវេលាដែលអាចឱ្យអនីតិជននោះធ្វើការងារមិនឱ្យលើសពី ១០០ (មួយរយ) ម៉ោងទេ[86] មានន័យថាទោសសហគមន៍ចំពោះអនីតិជនច្បាប់កំណត់ត្រឹមពាក់កណ្តាល នៃថិរវេលារបស់នីតិជន។ ម្យ៉ាងវិញទៀតចំពោះការងារគឺត្រូវជ្រើសការងារមួយដែលសមស្របសម្រាប់អនីតិជននោះ ពិសេសគឺស្ថានភាពរបស់អនីតិជនដែល

[84] មាត្រា ១៦១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
[85] មាត្រា ៧២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
[86] មាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ទាក់ទង នឹងការបណ្តុះបណ្តាល និងស្ថានភាពដែលអនុញ្ញាតឱ្យកែសម្រួល អនីតិជនកែប្រែ អប់រំអនីតិជននោះឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញបានងាយស្រួល។ ចំពោះហេតុផលដែលអនីតិជនអាយុ ១៦ ឆ្នាំ ទើបត្រូវបានអនុវត្តទោសសហគមន៍ ព្រោះយោងតាមច្បាប់ស្តីពីការងារ បានកំណត់ថាកុមារដែលមានអាយុ ១៥ ឆ្នាំ អាចធ្វើការងារជាកម្មករនយោជិតបាន[87] ព្រោះការងារនេះបានកម្រៃ ដើម្បីចិញ្ចឹមគ្រួសារ និងខ្លួនឯង ហេតុនេះបើមានវ័យប៉ុណ្ណឹង គឺល្មមធ្វើការងារបានហើយ ក៏ប៉ុន្តែទោសការងារសហគមន៍ គឺគ្មានកម្រៃទេ ដូច្នេះការកំណត់អាយុត្រឹម ១៦ ឆ្នាំឡើងជាការប្រសើរចំពោះអនីតិជន។

## ៣.២ ការអនុវត្តន៍ទោសចំពោះអនីតិជន

ជាទូទៅនៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើស វិធានការអនុវត្តចំពោះអនីតិជនមានតែវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ[88] ដែលមានដូចជា៖

- ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងទំនុកចិត្ត។
- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនទៅអង្គការឯកជន ដែលមាននីតិសម្បទានៅក្នុងការទទួលអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកជន។
- ការដាក់នីតិជនឱ្យស្ថិតនៅក្រោមការពាររបស់តុលាការ ត្រង់ន័យនេះមានន័យថាតុលាការត្រូវចាត់តាំងបុគ្គលមួយរូបដែលត្រូវទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនោះត្រូវផ្ញើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនោះត្រូវផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ[89]។

ប៉ុន្តែចំណុចដែលមានភាពលំបាក ដោយហេតុថាក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើសដែលមានស្ថានទម្ងន់ទោសធ្ងន់ធ្ងរណាមួយ នឹងមានការអនុវត្តទណ្ឌកម្មបែបណា។ ដូច្នេះហើយ ក្រមព្រហ្មទណ្ឌបានធ្វើការកំណត់ថាតុលាការអាចធ្វើការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅបាន ប្រសិនបើកាលៈទេសនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ ដោយនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនបានកំណត់ឱ្យបានច្បាស់លាស់ឡើយអំពីពាក្យថាកាលៈទេសៈ នៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន។ ចំពោះការប្រកាសទោសទាំងអស់ត្រូវធ្វើការពិចារណាថាអនីតិជនបានប្រព្រឹត្ត

[87] មាត្រា ១៧៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

[88] មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[89] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

បទល្មើសនៅស្ថានភាពបែបណា ឬសតិស្មារតីបែបណានៅពេលប្រព្រឹត្តបទល្មើស ដោយហេតុនេះមុនពេលចៅក្រមធ្វើការសម្រេចផ្តន្ទាទោស ត្រូវពិនិត្យលើការវិនិច្ឆ័យតាមបបរិជ្ជសាស្ត្រតាមរយៈការវិនិច្ឆ័យរបស់វេជ្ជបណ្ឌិត ហើយនៅពេលជួបប្រទះនូវករណីណាមួយដែលធ្ងន់ធ្ងរ ច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការដែលគេអាចនិយាយម៉្យាងទៀតថាជាឆន្ទានុសិទ្ធិក្នុងការពិចារណាថាអនីតិជនអាចនឹងត្រូវទទួលខុសត្រូវដោយការពិន័យជាប្រាក់ (៣.២.១) ឬក៏អាចនឹងត្រូវបានតុលាការអនុវត្តទោសពន្ធនាគារ (៤.២.២)។ ប៉ុន្តែទោះជាដូច្នេះក៏ដោយ កុមារក៏ត្រូវបានច្បាប់ធ្វើការគាំពារយ៉ាងខ្លាំងផងដែរក្នុងការការពារ ថែទាំ អប់រំ និងក្នុងការស្តារនីតិ-សម្បទាឡើយវិញ។

### ៣.២.១ ការអនុវត្តទោសពិន័យ

ទោសពិន័យ គឺជាទោសព្រហ្មទណ្ឌមួយស្ថិតក្នុងប្រភេទទោស នៃមូលទោស ដែលមានភាពខុសប្លែកពីទណ្ឌកម្មផ្សេងៗទៀត ដែលចៅក្រមបានធ្វើការប្រកាសផ្តន្ទាទោស។ ទោសពិន័យជាប្រាក់ គឺជាទោសដែលតម្រូវឱ្យទណ្ឌិតធ្វើការបង់ប្រាក់តាមកាលកំណត់ ដោយប្រាក់ពិន័យត្រូវគិតជារូបិយវត្ថុជាតិ ឬគិតជារៀល[90] ហើយរាល់ប្រាក់ពិន័យទាំងអស់ត្រូវបង់ចូលថវិការដ្ឋ។ ដោយយើងបានដឹងហើយថាអនីតិជនជាជនដែលមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើង អាចនឹងត្រូវចៅក្រមប្រកាសទោសពិន័យជាប្រាក់។ ហើយចំពោះការពិន័យនេះទៀតសោត ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យតាមការកំណត់ អង្គភាពរតនាគារនឹងធ្វើការជូនដំណឹងទៅដល់ព្រះរាជអាជ្ញា នៃតុលាការអមសាលាដំបូង។ បន្ទាប់ពីព្រះរាជអាជ្ញាបានធ្វើការជូនដំណឹងដល់ទណ្ឌិតរួចហើយ ព្រះរាជអាជ្ញានឹងធ្វើការកំណត់រយៈពេល ដើម្បីទណ្ឌិតដែលជាអនីតិជនចូលមកបង់ប្រាក់ពិន័យក្នុងរយៈពេល នៃការកំណត់នេះ មិនអាចតិចជាង ១០ (ដប់) ថ្ងៃ នោះទេ។ មួយវិញទៀតចំពោះការជូនដំណឹងដែលព្រះរាជអាជ្ញាធ្វើការជូនទៅទណ្ឌិតជាអនីតិជន អាចធ្វើឡើងដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ហើយត្រូវធ្វើកំណត់ហេតុស្តីពីការជូនដំណឹងនេះផងដែរ។ រីឯចំពោះកំណត់ហេតុនេះត្រូវតែការចុះហត្ថលេខាពីទណ្ឌិត ឬស្នាមម្រាមដៃរបស់ទណ្ឌិត[91]។ ចំពោះទណ្ឌិតដែលមិនបានធ្វើការបង់ប្រាក់ពិន័យ ប្រាក់ពន្ធនីតិវិធី និងប្រាក់សំណង តុលាការនឹងធ្វើការអនុវត្តទោសដោយការបង្ខំដល់រូបរាងកាយទណ្ឌិតនោះ។ អ្វីដែលជាបញ្ហាចោទក្នុងករណីទណ្ឌិតបានអះអាងថាខ្លួនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ពិន័យ តាមគោលការណ៍បង្ខំដល់រូបរាងកាយក៏អាចអនុវត្តផងដែរ ប៉ុន្តែចំពោះការបកស្រាយនេះវាពិតជាប៉ះពាល់ដល់សិទ្ធិមនុស្ស ដែលពួកគេបែរជាត្រូវជាប់ពន្ធនាគារដោយសារមូលហេតុបែបនេះ ដូច្នេះថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានធ្វើការចែងជាក់លាក់ ដោយតាមការអនុវត្តជាក់ស្តែង

[90] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[91] មាត្រា ៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំណុចនេះ គឺសំដៅដល់ទណ្ឌិតដែលមានបំណងចង់គេចវេសមិនបង់ប្រាក់ពិន័យ មិនមែនសំដៅដល់ទណ្ឌិតដែលមិនមានលទ្ធភាព ដូច្នេះគួរតែមានយុត្តិសាស្ត្រកំណត់នូវចំណុចនេះឱ្យច្បាស់ ដើម្បីជាការធានានូវការគោរពសិទ្ធិ និងសេរីភាពរបស់មនុស្ស។ វិធានការបង្ខំរូបកាយនេះទៀតសោត មិនអាចធ្វើការអនុវត្តចំពោះទណ្ឌិតជាអនីតិជនបាននោះទេ ដោយសារអនីតិជនជាជនដែលកំពុងរីកលូតលាស់ ដូច្នេះបើមានការអនុវត្តការបង្ខំរូបកាយអាចបណ្តាលឱ្យប៉ះពាល់ដល់ការរីឌ្ឍន៍របស់ពួកគេជាក់ជាពុំខាន។ គោលដៅ នៃវិធានការបង្ខំរូបរាងកាយ គឺមានបំណងធានាឱ្យបាននូវការគោរពសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌឱ្យមានប្រសិទ្ធភាព ហើយចំពោះការបង្ខំដល់រូបរាងកាយនេះក៏មានការយោគយល់ក្រោមរូបភាពមនុស្សធម៌ផងដែរ។

**៣.២.២ ការអនុវត្តទោសពន្ធនាគារ**

ការកំណត់អាយុកុមារ ដែលអាចជាប់ពន្ធនាគារក្នុងប្រព័ន្ធពន្ធនាគារមានភាពខុសគ្នាទៅតាមច្បាប់ប្រទេសនីមួយៗ ក្រៅពីនេះនៅក្នុងពន្ធនាគារនៅប្រទេសមួយចំនួនអនីតិជន និងមនុស្សពេញវ័យ មានអាយុខុសគ្នាត្រូវបានឃុំឃាំងជាមួយគ្នា ដែលផ្ទុយពីគោលការណ៍ នៃច្បាប់អន្តរជាតិ។ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារបានធ្វើការលើកឡើងថាអាយុអប្បបរមាសម្រាប់ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋត្រូវមានអាយុ ១២ (ដប់ពីរ) ឆ្នាំ ហើយមិនមានការកំណត់ការទទួលស្គាល់ក្រោមអាយុនេះទៀតឡើយ។

នៅក្នុងប្រទេសកម្ពុជា អាយុអប្បបរមាអនីតិជនដែលទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពី ១៤ (ដប់បួន) ឆ្នាំ ហើយនៅពេលពួកគេបានប្រព្រឹត្តបទល្មើស តុលាការអាចចេញសេចក្តីសម្រេចប្រកាសផ្តន្ទាទោសដោយការប្រកាសផ្តន្ទាទោសសម្រាប់អនីតិជនក្រៅពីទោសពិន័យជាប្រាក់ តុលាការក៏អាចធ្វើការប្រកាសទណ្ឌកម្មដាក់ពន្ធនាគារផងដែរ។ ការដាក់ពន្ធនាគារសំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ ដែលរួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលកែប្រែផងដែរ[92]។ យោងតាមគោលការណ៍គ្រឹះ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានធ្វើការកំណត់ថាការឃុំខ្លួនមុន ឬក្រោយការជំនុំជម្រះគួរតែជាមធ្យោបាយចុងក្រោយបំផុតដែលគួរធ្វើឡើងចំពោះកុមារ[93]ហើយមិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងៗទៀតដែលឃោរឃៅ អមនុស្សធម៌ចំពោះអនីតិជនឡើយ។ ព្រោះថាការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទាជាអាទិ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងការផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយឱ្យអនីតិជនធ្វើការកែប្រែខ្លួន វិវឌ្ឍន៍ខ្លួន ពង្រឹងខ្លួនឯងឱ្យក្លាយទៅជាពលរដ្ឋល្អ សុចរិត និងក្លាយជាយុវជនមួយដែលសង្គមជាតិត្រូវការក្នុងការអភិវឌ្ឍន៍[94]នៅពេលដែលពួកគេត្រូវ

[92] មាត្រា ៤ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[93] មាត្រា ៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[94] មាត្រា ៧៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បានដោះលែង។ ជនជាប់ឃុំត្រូវសំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូលមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ[95]។ ចំពោះជនជាប់ឃុំជាស្ត្រីភេទ និងជនជាប់ឃុំជាអនីតិជន ត្រូវមានបញ្ជីដោយឡែកហើយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីរប្រភេទនេះ[96]ចំណែកឯការឃុំខ្លួនជនជាប់ឃុំដែលជាជនត្រូវចោទ ឬពិរុទ្ធជន ត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត និងជនជាប់ឃុំដែលជាអនីតិជន ត្រូវដាក់បំបែកពីជនជាប់ឃុំដ៏ទៃទៀត[97]។ ការរក្សាខ្លួនអនីតិជនត្រូវនៅក្នុងមណ្ឌលយុវនីតិសម្បទា ហើយអនីតិជនដែលមានភេទផ្សេងគ្នា ប្រភេទ និងស្ថានភាពបទ-ល្មើសផ្សេងគ្នា អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ត្រូវឃុំខ្លួននៅអគារដាច់ដោយឡែកពីគ្នា រីឯអនីតិជនភេទស្រី ត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា។ ប្រសិនបើទណ្ឌិតជាអនីតិ-ជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាននឹងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទាទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលនីតិសម្បទាបន្តរហូតដល់អាយុ ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតមានអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន[98]។

ប្រទេសកម្ពុជាក្នុងឆ្នាំ២០២០ មានអ្នកជាប់ឃុំប្រមាណជាង ៤ (បួន) ម៉ឺននាក់ ដែលក្នុងនោះមានអនីតិ-ជនជាង ១៥០០ នាក់ ដោយសាររដ្ឋាភិបាលមមាញឹកនឹងជំងឺកូវិត១៩ បិទប្រទេស បិទទីក្រុង ដែលធ្វើឱ្យទិន្នន័យមិនមានភាពក្បោះក្បាយ រីឯនៅអំឡុងឆ្នាំ២០២១ ចំនួនអនីតិជនដែលបានឃុំខ្លួនមានចំនួន ១៤២២ នាក់ ក្នុងនោះបទល្មើសគ្រឿងញៀនចំនួន ៤៥២ នាក់ ស្មើនឹង ៣១.៨ ភាគរយ ប្លន់ និងលួចមានស្ថានភាពទម្ងន់ទោសចំនួន ១២៥ នាក់ ស្មើនឹង ៨.៧៩ ភាគរយ លួច ចំនួន ១០៩ នាក់ ស្មើរនឹង ៧.៦៧ ភាគរយ មនុស្សឃាត និងឃាតកម្ម ចំនួន ៣៤ នាក់ ស្មើនឹង ២.៣៩ ភាគរយ រំលោភសេពសន្ថវៈ ៣១ នាក់ ស្មើនឹង ២.១៣ ភាគរយ និងផ្សេងៗ ចំនួន ៦៧១ នាក់ ស្មើនឹង ៤៧.៧២ ភាគ ដែលក្នុងពន្ធនាគារទាំងអស់ទូទាំងប្រទេស ក្នុងនោះទីតាំងដែលមានច្រើនជាងគេ រួមមានមណ្ឌលអប់រំកែប្រែទី២ (ម២) នៅរាជធានីភ្នំពេញច្រើនជាងគេមានចំនួន ២៦៨ នាក់ ខេត្តកណ្តាល មានចំនួន ១៦០ នាក់ ខេត្តសៀមរាប មានចំនួន ១៩១ នាក់ ខេត្តបន្ទាយមានជ័យ មានចំនួន ១២៦ នាក់ និងខេត្តព្រះសីហនុ មានចំនួន ១០៤ នាក់ ខណៈខេត្តមណ្ឌលគិរី មានចំនួនតិចជាងគេ គឺមានចំនួន ២ នាក់[99]។ យោងតាមការិយាល័យសិទ្ធិមនុស្សរបស់អង្គការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បង្ហាញថាគិតត្រឹមខែ

[95] មាត្រា ៤ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[96] មាត្រា ២១ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[97] មាត្រា ២៦ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[98] មាត្រា ៨២ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[99] របាយការណ៍សម្រេចប្រចាំឆ្នាំ២០២១ នៃក្រសួងមហាផ្ទៃ

មេសា ឆ្នាំ២០២២ មានអនីតិជនកំពុងជាប់ឃុំ ១៣៤៦ នាក់ ដែលជាទិន្នន័យចុងក្រោយបំផុតដែលសម្រាប់ឆ្នាំ ២០២២។

ការគ្រប់គ្រងពន្ធនាគារ គឺជាការទទួលខុសត្រូវរបស់ប្រធានពន្ធនាគារដែលអង្គភាពនេះស្ថិតក្រោមចំណុះរបស់ក្រសួងមហាផ្ទៃ។ មន្ត្រីពន្ធនាគារអាចធ្វើការឆែកឆេរជនជាប់ឃុំ និងកន្លែងនានាក្នុងពន្ធនាគារ ដើម្បីធានាសន្តិសុខ និងសុវត្ថិភាពរបស់ពន្ធនាគារ។ ជនជាប់ឃុំត្រូវអនុញ្ញាតឱ្យគ្រួសារ ឬញាតិមិត្តមកសួរសុខទុក្ខតាមការកំណត់ លើកលែងតែមានការហាមឃាត់ពីអាជ្ញាធរតុលាការ។ ប្រធានពន្ធនាគារ ត្រូវបិទផ្សាយជាសាធារណៈនូវពេលវេលា និងរយៈពេលសួរសុខទុក្ខដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ[100]។ ប្រធានពន្ធនាគារត្រូវទទួលខុសត្រូវអំពីសន្តិសុខ សុវត្ថិភាពចំពោះការនាំខ្លួន ឬបញ្ជូនជនជាប់ឃុំទៅកាន់តុលាការ ឬទៅកាន់មន្ទីរពេទ្យខាងក្រៅ។ ដូចដែលយើងដឹងហើយថាការឃុំខ្លួនអនីតិជនត្រូវធ្វើការដាក់ដាច់ដោយឡែកពីនីតិជនពោលនៅពេលដែលតុលាការធ្វើការប្រកាសទោសឃុំខ្លួនដល់អនីតិជន នោះមានន័យថាអនីតិជននឹងត្រូវធ្វើការឃុំខ្លួនក្នុងមណ្ឌលយុវនីតិសម្បទា។

### ៣.២.៣ ការអនុវត្តទោសក្នុងមណ្ឌលយុវនីតិសម្បទា

បន្ទាប់ពីចេញសេចក្តីសម្រេចជាស្ថាពរទណ្ឌិតដែលជាអនីតិជនមានទោសពន្ធនាគារនឹងត្រូវឃុំខ្លួននៅក្នុងមណ្ឌលយុវនីតិសម្បទា។ ប៉ុន្តែកន្លងមកការអនុវត្តន៍នៅកម្ពុជាមិនទាន់ស្របតាមច្បាប់អន្តរជាតិទាំងស្រុងពោលដោយសារពន្ធនាគារដែលធ្វើការឃុំខ្លួនទណ្ឌិតដែលជាអនីតិជន មិនស្របទៅតាមច្បាប់អន្តរជាតិ ហើយក៏មានភាពចង្អៀត ការរស់នៅគ្មានអនាម័យ មិនសូវមានការយកចិត្តទុកដាក់ចំពោះទណ្ឌិត មានការបំពានសិទ្ធិដែលទណ្ឌិតជាអនីតិជនគួរទទួលបាន ដោយសារបញ្ហានេះធ្វើឱ្យរដ្ឋាភិបាលមានការខ្វល់ខ្វាយជាខ្លាំង ទើបថ្មីៗនេះរដ្ឋាភិបាលបានធ្វើការសាងសង់ និងសម្ពោធដាក់ប្រើនូវមណ្ឌលយុវនីតិសម្បទា មានទីតាំងស្ថិតនៅឃុំបាគូរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ក្នុងការគាំពារកុមារដែលទំនាស់នឹងច្បាប់ឱ្យទទួលបានសិទ្ធិដែលពួកគេគួរទទួលបាន។ បន្ទាប់ពីមានការសម្ពោធឱ្យប្រើប្រាស់នូវមណ្ឌលនេះ ក៏មានការផ្ទេរទណ្ឌិតពីពន្ធនាគារមកមណ្ឌលយុវនីតិសម្បទាចំនួន ៥០ នាក់ ដើម្បីជាការសាកល្បង ហើយការផ្ទេរទណ្ឌិតនេះទៀតសោតត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួង គឺក្រសួងសង្គមកិច្ច ក្រសួងយុតិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងការងារ ដែលក្រសួងទាំងនេះត្រូវជាការប្រកាសមួយ ដើម្បីផ្ទេរអនីតិជនពីពន្ធនាគារ។ មួយវិញទៀតអនីតិជនដែលជាប់ឃុំទាំងអស់ នឹងទទួលបានសិទ្ធិដូចជា៖

- សិទ្ធិទទួលបានការអប់រំ

[100] មាត្រា ៥៥ នៃច្បាប់ស្តីពន្ធនាគារ ឆ្នាំ២០១១

- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ថោកបន្ទាប ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឱ្យនៅឯកា ការដាក់កំហិត ឬបដិសេធ មិនឱ្យមានប្រាស្រ័យទាក់ទងជាមួយគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូរបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំបទបញ្ជាផ្ទៃក្នុង និងអំពីសិទ្ធិ កាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឱ្យមានការសួរសុខទុកជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងៗទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន។

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលយុវនីតិសម្បទាទាំងអស់ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដោយធ្វើការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួន ដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន និងផ្តល់ការសិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា និងសេវាផ្សេងទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឱ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឱ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឱ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីដោះលែង[101]។

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែកចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នាៈ

- ✓ ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
- ✓ ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជន ដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
- ✓ ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរកម្ម[102]។

[101] មាត្រា ៨១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[102] មាត្រា ៧៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

សរុបជារួមមណ្ឌលយុវនីតិសម្បទា ជាមណ្ឌលដែលឃុំកុមារដែលទំនាស់នឹងច្បាប់ ប៉ុន្តែមណ្ឌលនេះក៏ផ្តល់ការអប់រំ កែប្រែ គាំពារកុមារ មើលថែការពារធ្វើយ៉ាងណាធានាឱ្យបានថានៅពេលកុមារទទួលបានការដោះលែង ពួកគេនឹងក្លាយជាយុវជនដែលល្អប្រសើមួយរូបដែលសង្គមជាតិត្រូវការ។

## ៣.៣ ការដោះលែងដោយមានលក្ខខណ្ឌ

ជនជាប់ឃុំដែលជាអនីតិជន អាចនឹងត្រូវបានតុលាការធ្វើការអនុគ្រោះដោយធ្វើការដោះលែងមុនកាលកំណត់ នៃការអនុវត្តទោស ប៉ុន្តែត្រូវអាស្រ័យលើអាប្បកិរិយាមាយាទរបស់ជនជាប់ឃុំ ឬបុគ្គលដែលបានធ្វើការស្នើសុំឱ្យមានការដោះលែង។

### ៣.៣.១ ការដោះលែងដោយផ្អែកលើអត្តចរិត

ទោះបីទណ្ឌិតអនុវត្តទោសរបស់ខ្លួនមិនទាន់ចប់ក៏ដោយ ក៏អាចដោះលែងឱ្យនៅក្រៅឃុំបានដែរ ប្រសិនបើ៖

- ទណ្ឌិតបានបង្ហាញឱ្យឃើញថាខ្លួនមានគំនិត មារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅសង្គមវិញបាន។
- អនុវត្តទោសបានពាក់កណ្តាល ប្រសិនបើទោសនោះតិចជាង ឬស្មើ ១(មួយ) ឆ្នាំ។
- អនុវត្តទោសបានពីរភាគបី ក្នុងករណីផ្សេងទៀត
- អនុវត្តទោសបាន ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើទោសនោះអស់មួយជីវិត។[103]

ប៉ុន្តែចំពោះការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឱ្យទណ្ឌិតជាអនីតិជន ដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

- ចំនួនមួយភាគបីនៃទោស ប្រសិនបើតុលាការបានធ្វើការផ្តន្ទាទោសតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីដែលអនីតិជនមានបញ្ហាសុខភាព ឬមានគភ៌ ឬក្នុងករណីផ្សេងៗទៀត។[104]

### ៣.៣.២ ការដោះលែងតាមការស្នើសុំ

ក្រៅពីសេចក្តីសម្រេចរបស់តុលាការ ក្នុងការដោះលែងជនជាប់ឃុំជាអនីតិជនមុនកាលកំណត់ការដោះលែងនេះក៏បានកើតឡើងបានដែរ ប្រសិនបើមានការស្នើសុំ ហើយបុគ្គលដែលមានសិទ្ធស្នើសុំឱ្យមានការដោះលែងនេះមានដូចជា៖

- ✓ ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- ✓ អ្នកតំណាងដែលច្បាប់បានកំណត់

[103] មាត្រា ៥១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[104] មាត្រា ៧២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- ✓ ប្រធានមណ្ឌលយុវនីតិសម្បទា
- ✓ ភ្នាក់ងារសង្គមកិច្ចដែលពាក់ពន្ធនឹងរឿងក្ដីអនីតិជននោះ
- ✓ បេសកកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស។

សរុបមកជនជាប់ឃុំជាអនីតិជនអាចនឹងត្រូវបានធ្វើការដោះលែងមុនកាលកំណត់ ប្រសិនបើមានសេចក្ដីសម្រេចរបស់តុលាការ ប៉ុន្តែការដោះលែងនេះមិនមែនជាការដោះលែងទាំងស្រុងនោះទេ ព្រោះថាជននោះនឹងត្រូវបានឃ្លាំមើល តាមដាន ត្រួតពិនិត្យ ដោយសមត្ថកិច្ចតុលាការ នៅពេលបញ្ជូនពួកគេទៅក្នុងសង្គមវិញ ហើយចំពោះបែបបទ នៃការដោះលែងនេះត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ ក្នុងករណីដែលទណ្ឌិតជាអនីតិជនត្រូវបានដោះលែងហើយ ប៉ុន្តែមានការផ្ដន្ទាទោសជាថ្មី ឬមិនគោរពលក្ខខណ្ឌដែលបានកំណត់ដោយដីកាទេ ប្រធានតុលាការជាន់ដំបូងអាចដកហូតសេចក្ដីសម្រេចរបស់ខ្លួនវិញបាន ហើយទណ្ឌិតត្រូវទទួលទោសរបស់ខ្លួនដែលនៅសេសសល់។ រយៈពេលសេសសល់ ត្រូវគិតចាប់ពីពេលដែលទណ្ឌិតបានទទួលសេចក្ដីសម្រេចឱ្យដោះលែងដោយមានលក្ខខណ្ឌ។

**ឧទាហរណ៍៖** លោក ក ត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ។ ក្រោយពីបានអនុវត្តន៍បាន ៦(ប្រាំមួយ) ខែ ត្រូវបានតុលាការដោះលែងដោយមានលក្ខខណ្ឌ។ ពេលនៅក្រៅឃុំលោក ក បានបំពានលក្ខខណ្ឌ(មិនបានអនុវត្តន៍កាតព្វកិច្ច)។ ដូច្នេះតុលាការនឹងដកហូតការដោះលែងដោយមានលក្ខខណ្ឌវិញ ដោយលោក ក ត្រូវអនុវត្តន៍ទោសដែលនៅសេសសល់ ៦ ខែទៀត។[105]

## ៣.៤ ការស្ដារនីតិសម្បទាឡើងវិញ

### ៣.៤.១ ការស្ដារនីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ការផ្ដល់នីតិសម្បទាឡើងវិញ គឺជាសមត្ថកិច្ចរបស់សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍។ ពាក្យសុំអាចធ្វើឡើងដោយទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន។ ពាក្យសុំឱ្យមាននីតិសម្បទាឡើងវិញអាចដាក់ជូនសភាព្រហ្មទណ្ឌពិនិត្យបានលុះត្រាតែផុតរយៈពេលដូចតទៅ៖

- ✓ ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ✓ ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ✓ ១ (មួយ) ខែ ចំពោះបទលហុ

[105] សៀវភៅដំណើរការរឿងក្ដីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន ទំព័រ ១២៩ រៀបរៀងដោយ ឧត្តមសេនីយ៍ត្រី អាន សុវីដា

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសផុតអាជ្ញាយុកាល[106]។ ក្នុងករណីតុលាការបដិសេធពាក្យសុំសាមីជនមិនអាចជូនពាក្យសុំថ្មីទៀតមុនផុតរយៈពេល ២ (ពីរ) ឆ្នាំ បានឡើយ។

**ឧទាហរណ៍** លោក ក ជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ហើយអនុវត្តទោសរួច នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១១។ ចាប់ពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៣ តទៅ លោក ក អាចដាក់សុំឱ្យមាននីតិសម្បទាឡើងវិញជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន។

### ៣.៤.២ ការស្តារនីតិសម្បទាឡើងវិញដោយពេញច្បាប់

នីតិសម្បទាមានឡើងវិញដោយពេញច្បាប់ នៅក្នុងករណីដូចទៅ៖

- ✓ ៣ (បី) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ✓ ១ (មួយ) ឆ្នាំ ចំពោះបទមជ្ឈិម
- ✓ ៣ (បី) ខែ ចំពោះបទលហុ

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល[107]។

---

[106] មាត្រា ៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[107] មាត្រា ៧៥ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាពីប្រធានបទ "**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**" រួចមក យើងសង្កេតឃើញថាអនីតិជនដែលបានប្រព្រឹត្តបទល្មើស គឺត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់នូវអំពើដែលខ្លួនបានប្រព្រឹត្តដូចនឹងនីតិជនដែរ ប៉ុន្តែអាចទទួលខុសត្រូវមួយផ្នែក។ ដោយសារអនីតិជន ជាជនដែលស្ថិតក្នុងវ័យកំពុងលូតលាស់ទាំងផ្នែកចិត្តគំនិត ប្រាជ្ញាស្មារតី និងការពិចារណារបស់ពួកគេនូវមានកម្រិត។ ហេតុនេះ ស្ថាប័នតុលាការត្រូវតែធ្វើការពិចារណាឱ្យបានល្អិតល្អន់ទាក់ទងនឹងលទ្ធភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌដល់ពួកគេ ដូចជាពិនិត្យលើបញ្ហាទាក់ទងនឹងកត្តាអាយុ កត្តាកាលៈទេសៈ នៃបទល្មើស និងបុគ្គលិកលក្ខណៈ នៃអនីតិជន ថាតើអនីតិជននោះមានលទ្ធភាពទទួលខុសត្រូវឬទេ? ឬអាចទទួលខុសត្រូវត្រឹមកម្រិតណា? ទើបច្បាប់ស្តីពីយុត្តិធម៌អនីតិជនបញ្ញត្តិជាពិសេសអំពីវិធានការបង្វែរ ដែលមានលទ្ធភាពអាចជំនួសការឃុំខ្លួន ឬក្រោយការផ្តន្ទាទោសដល់អនីតិជន។ ការឃុំឃាំងគួរតែជាវិធានការចុងក្រោយបង្អស់សម្រាប់អនីតិជន ពីព្រោះការឃុំឃាំងទោះបីមានរយៈពេលខ្លីយ៉ាងណា ក៏អាចធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាពផ្លូវចិត្ត រាងកាយ និងការវិវឌ្ឍផ្នែកការយល់ដឹងផងដែរ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបង្កើតឡើងក្នុងគោលបំណងធានាការពារសិទ្ធិ ឧត្តមប្រយោជន៍របស់អនីតិជននៅពេលពួកគេប្រព្រឹត្តបទល្មើស ហើយក៏គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ឡើងវិញ។ ច្បាប់នេះក៏បានចែងអំពីគោលការណ៍ជាមូលដ្ឋាន និងសិទ្ធិជាមូលដ្ឋានដែលធានាការពារដល់អនីតិជននៅគ្រប់ដំណាក់កាល នៃនីតិវិធីទាំងអស់ចាប់តាំងពីដំណាក់នគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលជំនុំជម្រះ។ មួយវិញទៀត ច្បាប់នេះចែងការពារឧត្តមប្រយោជន៍ដល់អនីតិជនមានលក្ខណៈស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម លិខិតតុបករណ៍អន្តរជាតិនានា ថែមទាំងវិធានការប៉េកាំងដែលបានចែងអំពីការពិន័យជាប្រាក់ ការប្រើប្រាស់វិធានការបង្វែរមុននឹងឈានដល់ការប្រកាសពីទណ្ឌកម្មព្រហ្មទណ្ឌដល់អនីតិជន។

សរុបមករដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ជាខ្លាំងចំពោះអនីតិជន ជាពិសេសអនីតិជនដែលបានប្រព្រឹត្តបទល្មើសដោយបានបង្កើតជាយន្តការការពារ សេចក្តីណែនាំ និងច្បាប់ ដែលមានលក្ខណៈស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ។ មួយវិញទៀត កម្ពុជាក៏បានបង្កើតមណ្ឌលយុវនីតិសម្បទាដើម្បីជម្រុញការអនុវត្តច្បាប់ស្តីពីយុត្តិ-ធម៌អនីតិជនតាមរយៈការពង្រឹងការអប់រំ បណ្តុះបណ្តាល និងស្តារនីតិសប្បទា ស្របតាមស្ថានភាពវិវឌ្ឍន៍ជាក់ស្តែងរបស់កម្ពុជា និងដើម្បីអប់រំកែប្រែពួកគេក្លាយទៅយុវជនល្អ ជាធនធានមនុស្សដ៏រឹងមាំសម្រាប់សង្គមជាតិនាពេលអនាគត។

# អនុសាសន៍

# អនុសាសន៍

តាមការសង្កេតឃើញថាសិទ្ធិរបស់អនីតិជនត្រូវបានការពារក្រោមច្បាប់ជាតិ និងអន្តរជាតិ ប៉ុន្តែច្បាប់ដែលពាក់ព័ន្ធនឹងកុមារហាក់ដូចជាមិនមានភាពទូលំទូលាយក្នុងការគាំពារកុមារឱ្យទទួលសិទ្ធិដែលពួកគេគួរទទួលបាននោះទេ។ ដោយសារហេតុនេះនៅពេលមានការអនុវត្តទោសចំពោះអនីតិជនមិនថាជាទោសពិន័យ ឬទោសជាប់ឃុំក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា ជាគោលការណ៍មានលក្ខណៈស្របទៅតាមច្បាប់ជាតិ និងអន្តរជាតិ ជាពិសេសស្របតាមច្បាប់ស្តីយុត្តិធម៌អនីតិជនដែលធានារក្សាការពារផលប្រយោជន៍របស់អនីតិ-ជនជាចម្បង ប៉ុន្តែទោះបីជាច្បាប់បានកំណត់ដូច្នេះក៏ដោយចំពោះករណីមួយចំនួនក៏នៅតែមានការរំលោភបំពានសិទ្ធិមួយចំនួនលើអនីតិជនផងដែរ។ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសផ្សេងៗ អត្តសញ្ញាណរបស់អនីតិជនមិនត្រូវបានលាក់បាំងទៅតាមសិទ្ធិដែលគាត់បានទទួលនោះទេ ហើយការអនុវត្តរបស់សមត្ថកិច្ចយុត្តិធម៌ចំពោះអនិតិជនបែបនេះវាធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ កិត្តិយសរបស់អនីតិជន។ យើងឃើញថាទាំងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិគឺបានចែងអំពីការការពារសិទ្ធិក៏ដូចជាឧត្តមប្រយោជន៍របស់អនីតិជនយ៉ាងណាក៏ដោយក៏គេនៅតែសង្កេតឃើញថាមានរឿងក្តីពាក់ព័ន្ធនឹងអនីតិជនមួយចំនួនត្រូវបានធ្វើការជំនុំជម្រះនៅសាលាដំបូងហើយការជំនុំជម្រះហាក់ដូចជាមិនសូវអនុវត្តទៅតាមគោលការណ៍ដែលមានចែងក្នុងច្បាប់ជាតិ និងអន្តជាតិនោះទេ។ ការឃុំខ្លួនបណ្តោះអាសន្នពាក់ព័ន្ធទៅនឹងអនីតិជនជាវិធានការចុងក្រោយក្នុងការអនុវត្តចំពោះអនីតិជនដែលច្បាប់គាំទ្រឱ្យអនុវត្តវិធានការអប់រំ វិធានការតាមដាន វិធានការការពារ និងវិធានឧបត្ថម្ភ ជាជម្រើសដំបូង។ ប៉ុន្តែតាមសង្កេតឃើញការឃុំខ្លួនបណ្តោះអាសន្នចំពោះកុមារមានករណី ៨៧% នៃអនីតិជនត្រូវបានគេដាក់ឱ្យស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅពេលដែលរឿងក្តីមិនទាន់សម្រេច ដែលវាជាការបង្ហាញថាប្រព័ន្ធយុត្តិធម៌មិនបានអនុវត្តឱ្យបានពេញលេញ នូវប្រព័ន្ធយុត្តិធម៌អនីតិជនទាក់ទងនឹងសិទ្ធិទទួលបានក្នុងការជំនុំជម្រះដោយយុត្តិធម៌នោះទេ ព្រោះសិទ្ធិទាំងនេះពាក់ព័ន្ធយ៉ាងជាក់លាក់ចំពោះកុមារ។ ចំណែកចំពោះទីកន្លែងឃុំខ្លួនក៏ដូចគ្នាការដាក់ដាច់ដោយឡែករវាងអនីតិជន និងនីតិជន ហាក់បីដូចជាមានការអនុវត្តមិនទាន់ល្អទាំងស្រុងនោះទេដែលករណីបណ្តាលមកពីកង្វះធនធានសង្គម និងរចនាសម្ព័ន្ធ កង្វះមនុស្សដែលជាមន្ត្រីសង្គមកិច្ច ឬជាមេធាវីស្ម័គ្រចិត្តក្នុងការការពារសិទ្ធិនៅពេលដែលអនីតិជនគ្មានសមត្ថភាពក្នុងការជួល។

បច្ចុប្បន្នអនីតិជនដែលប្រព្រឹត្តបទល្មើសនៅកម្ពុជា ហាក់ដូចគ្មានការថយចុះគួរឱ្យកត់សម្គាល់នោះទេ យោងតាមទិន្នន័យដែលយើងបានបង្ហាញពីខាងលើចាប់ពីឆ្នាំ២០២០ ដល់បច្ចុប្បន្ន កត្តាទាំងអស់នេះអាចបណ្តាលឡើងដោយសារកង្វះការកំណត់វិធានក្រៅពីច្បាប់ស្តីពីយុត្តិធម៌អនីតិជន មានតែបទញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីបានចែងអំពីតែនិយមន័យសង្ខេប និងមានភាពទន់ខ្សោយក្នុងការរៀបចំយុត្តិធម៌អនីតិ-ជន។ ដូច្នេះជាការបង្ក្រាប និងបង្កាកុំឱ្យមានបទល្មើសកើតឡើងដោយអនីតិជន រដ្ឋាភិបាលក៏ដូចជាស្ថាប័ន

តុលាការ សមត្ថកិច្ច ដែលគួរតែមានដំណោះស្រាយ និងវិធានការណ៍ច្បាស់លាស់ ហើយក៏ត្រូវមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋផងដែរ។ ជំហានដំបូងរដ្ឋាភិបាលគួរតែបង្កើតកម្មវិធីក្នុងការផ្សព្វផ្សាយ ណែនាំអំពីសិទ្ធិកុមារដល់អនីតិជនទូទាំងប្រទេសតាមរយៈគ្រប់វិធី ជាពិសេសបញ្ចូលកម្មវិធីអប់រំទាក់ទងនឹងសិទ្ធិរបស់អនីតិជនទៅតាមសាលានៅក្នុងប្រទេស ដោយហេតុថានៅពេលពួកគេមានការយល់ដឹងពីសិទ្ធិរបស់ខ្លួន នោះពួកគេនឹងអាចពិចារណាថាទង្វើបែបណាអាចនឹងបង្កបានជាបទល្មើស ហើយពេលមានបទល្មើសកើតឡើងពួកគេនឹងត្រូវទទួលទណ្ឌកម្ម ដូច្នេះពួកគេនឹងមិនប្រព្រឹត្តទង្វើដែលផ្ទុយនឹងច្បាប់។ មួយវិញទៀតក្រុមគ្រួសារគួរតែធ្វើការបង្ហាត់បង្រៀនបន្ថែមទៀតចំពោះកូនទាក់ទងនឹងសិទ្ធិ និងទណ្ឌកម្មចំពោះអំពើល្មើស ជាពិសេសសាមីខ្លួនត្រូវតែមានចិត្តស្វែងយល់អំពីសិទ្ធិទូទៅ និងសិទ្ធិនៅពេលមានអំពើល្មើសកើតឡើង ព្រោះថាបច្ចុប្បន្នអនីតិជនភាគច្រើនមានទូរស័ព្ទរៀងៗខ្លួនដែលជាភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន ម៉្យាងវិញដោយសារតែជឿនលឿន នៃប្រទេសយើងទាំងផ្នែកសម្ភារៈ អាហារហូបចុក និងការអប់រំ ការផ្សព្វផ្សាយធ្វើឱ្យអនីតិជនមានការយល់ដឹងដូចនឹងនីតិជនដែរ។ ដោយហេតុនេះអនីតិជនដែលច្បាប់បានការពារ ពោលអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំដែលមានអត្តចរិត មាយាទខិលខូចដោយដឹងថាខ្លួនត្រូវបានការពារដោយច្បាប់ក៏ទៅប្រព្រឹត្តបទល្មើសដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមជាតិ។ ដូច្នេះហើយតើរដ្ឋាភិបាលគួរតែធ្វើការពិចារណាអំពីអាយុក្នុងការទទួលខុសត្រូវរបស់អនីតិជនដែរឬទេដោយផ្អែកលើបរិបទសព្វថ្ងៃ? អ្វីដែលរដ្ឋាភិបាលកាន់តែគួរយកចិត្តទុកដាក់ការអនុវត្តចំពោះអនីតិជននៅពេលមានដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋាភិបាលគួរតែបង្កើតអង្គភាពក្នុងការត្រួតពិនិត្យទៅលើស្ថាប័នដែលទាក់ទងនឹងកុមារជៀសវាសពីការរំលោភសិទ្ធិកុមារ និងបង្កើតវិធានការពារ និងគាំពារកុមារឱ្យកាន់តែមានភាពតឹងរឹងស្របតាមបទបញ្ញត្តិអន្តរជាតិ។

ជាចុងក្រោយសម្រាប់ទស្សនរបស់ក្រុមយើងខ្ញុំមើលឃើញថាបច្ចុប្បន្នការអនុវត្តច្បាប់យុត្តិធម៌អនីតិជននៅកម្ពុជាមានភាពល្អប្រសើរគួរសម ដោយសាររដ្ឋាភិបាលបានធ្វើការយកចិត្តក្នុងការបង្កើតមណ្ឌលយុវនីតិ-សម្បទា ដើម្បីធានាឱ្យការដាក់អនីតិជនដាច់ដោយឡែកពីនីតិជន ហើយការអនុវត្តនីតិវិធីចំពោះអនីតិជនក៏មានភាពល្អប្រសើរដែរ។ ម៉្យាងទៀតរដ្ឋាភិបាលក៏បានបង្កើតវិធានខ្លះក្នុងការគាំពារ និងការពារកុមារផងដែរ ប៉ុន្តែរដ្ឋាភិបាលគួរតែពង្រឹងវិស័យយុត្តិធម៌អនីតិជនឱ្យកាន់តែមានភាពល្អប្រសើរបន្ថែមទៀត ដើម្បីជាការធានាឱ្យបាននូវការការពារអនីតិជន សេចក្តីថ្លៃថ្នូរ កិត្តិយស និងឧត្តមប្រយោជន៍អនីតិជនដែលបានប្រព្រឹត្តបទល្មើសឱ្យកាន់តែមានសុក្រឹត្យភាព។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

### ក.លិខិតបទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦។
- ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
- ច្បាប់ស្តីពីការងារ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧។
- ច្បាប់ស្តីពីជនផល ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦។

### ខ.លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

- អនុសញ្ញាស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩។
- វិធានជាបទដ្ឋានអប្បបរមានៃអង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន ឆ្នាំ១៩៨៥ (វិធានប៉េកាំង)។
- ច្បាប់របស់អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាពរបស់ពួកគេ (វិធាន Havana ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០)។

## ២.សៀវភៅពាក់ព័ន្ធ និងអត្ថបទផ្សេងៗ

- សៀវភៅព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ កៅ សីហា បោះពុម្ពឆ្នាំ២០១៣។
- សៀវភៅសារណា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន រៀបរៀងដោយលោក គា ភារ៉ា និងលោក ហេង វឌ្ឍនៈ ឆ្នាំ២០១៧។
- សៀវភៅសារណា នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជននៅក្នុងរឿងក្តីព្រហ្មទណ្ឌ រៀបរៀងដោយលោក ផល សុភ័ក្រ្តិទ្ធ និងកញ្ញា សុវណ្ណ ថាវឌ្ឍន៍ ឆ្នាំ២០២១។
- សៀវភៅ ដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន រៀបរៀងដោយ ឧត្តមសេនីយ៍ត្រី អាន សូរីដា។
- ផែនការយុត្តិសាស្ត្រ និងផែនការប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។
- គោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៩។
- របាយការណ៍សម្រេចឆ្នាំ២០២១ នៃក្រសួងមហាផ្ទៃ។

- សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អញ្ជើញចូលរួមការសម្ពោធសមិទ្ធផល "មណ្ឌលយុវនីតិសម្បទា" ស្ថិតនៅឃុំបាគូរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។
- សន្ធានុក្រមពាក្យថ្មី រៀបរៀងដោយសាស្ត្រាចារ្យ ទូច គីមស្រ៊ាង ឆ្នាំ២០១៤។

# ឧបសម្ព័ន្ធ

## បញ្ជីនៃឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១ ៖** ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។
- **ឧបសម្ព័ន្ធទី២ ៖** ដីកាបង្គាប់ឱ្យឃុំខ្លួន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។
- **ឧបសម្ព័ន្ធទី៣ ៖** សាលក្រមព្រហ្មទណ្ឌលេខ ៤៦ "ដ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តសៀមរាប។ (អំពើលួច)
- **ឧបសម្ព័ន្ធទី៤ ៖** សាលក្រមព្រហ្មទណ្ឌលេខ ០៣ "ឆ.២" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តសៀមរាប។ (ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន)
- **ឧបសម្ព័ន្ធទី៥ ៖** សាលក្រមព្រហ្មទណ្ឌលេខ ៤៧១ "ម" ក្រ៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។ (ហិង្សាដោយចេតនា មានស្ថានទម្ងន់ទោសប្រើដាវសុាំម៉ូរ៉ៃ)
- **ឧបសម្ព័ន្ធទី៦ ៖** សាលក្រមព្រហ្មទណ្ឌលេខ ០៦ "ឃ" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង។ (ឃាតកម្ម)
- **ឧបសម្ព័ន្ធទី៧ ៖** សាលដីកាលេខ ២៨ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់តុលាការកំពូល។ (រំលោភសេពសន្ថវៈ)

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ: ១៨២៨
ចុះថ្ងៃទី១៨.០៤.២០២២
សំណុំរឿងស៊ើបសួរលេខ: ១៤៣១
ចុះថ្ងៃទី ១៩.០៤.២០២២
លេខ: 2247 "យ១" ដ.ព.ស

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោកស្រី ជាក្រឡាបញ្ជីផង ។

-បានឃើញ មាត្រា ២០៣ ដល់មាត្រា ២០៦ និងមាត្រាផ្សេងៗទៀតនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលទាក់ទង និងការឃុំខ្លួនបណ្តោះអាសន្ន ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១៣៩៣ អ.យ.ឈ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដែលបានបើកការស៊ើបសួរលើ៖

-ឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ផ្លូវលំ ភូមិ០១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មុខរបរ មិនពិតប្រាកដ ឪពុកឈ្មោះ "រស់/ស្លាប់" ម្តាយឈ្មោះ "រស់/ស្លាប់" នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន។

-ឃាត់ខ្លួននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២ ។

-ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចនៅចំណុចស្ពានទី៧ ផ្លូវជាតិលេខ៦ ក្រុមទី៤ ភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

-បានឃើញ កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ និងការកត់សម្គាល់របស់ភាគី

## I.ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១.ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ ត្រូវបានចោទបទ: **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា។**

២.ប្រព្រឹត្តនៅចំណុចនៅចំណុចស្ពានទី៧ ផ្លូវជាតិលេខ៦ ក្រុមទី៤ ភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២។

-កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ វេលាម៉ោងប្រហែល០១ និង៣០នាទី រំលងអាធ្រាត មានជនសង្ស័យមួយក្រុមមានគ្នា៩នាក់ ១.ឈ្មោះ ភេទប្រុស ២.ឈ្មោះ ភេទប្រុស ៣.ឈ្មោះ ភេទប្រុស ៤.ឈ្មោះ ភេទប្រុស ៥.ឈ្មោះ ភេទប្រុស ៦.ឈ្មោះ ភេទប្រុស ៧.ឈ្មោះ ភេទប្រុស ៨.ឈ្មោះ ភេទប្រុស និង៩.ឈ្មោះ ភេទប្រុស ជិះម៉ូតូ០៤គ្រឿងឌុបគ្នាចេញធ្វើសកម្មភាពវាយប្លន់យកម៉ូតូរបស់ប្រជាពលរដ្ឋ ពេលជិះមកដល់ចំណុចស្ពានទី៧ ផ្លូវជាតិលេខ៦ ក្រុមទី៤ ភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ក៏ឃើញជនរងគ្រោះឈ្មោះ ភេទប្រុស ជិះម៉ូតូ០១គ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០២០ឡើងតែបឆ្នាំ២០២២ ពាក់ស្លាកលេខភ្នំពេញ 1Q-៥៧០៥ តែម្នាក់ឯង ភ្លាមនោះជនសង្ស័យឈ្មោះ

បានជិះម៉ូតូភ៌ទៅអែបទន្ទឹមនឹងជនរងគ្រោះ រួចធាក់ម៉ូតូជនរងគ្រោះបណ្តាលឱ្យដួលបោកទៅនឹងថ្នល់ ហើយជនសង្ស័យឈ្មោះ បានជិះម៉ូតូបុកជនរងគ្រោះបន្ថែមទៀត ចំណែកឈ្មោះ បានដកខ្សែក្រវ៉ាត់វាយជនរងគ្រោះបណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ រីឯឈ្មោះ ជាអ្នកលើកម៉ូតូជនរងគ្រោះជិះគេចខ្លួន និងយកម៉ូតូនោះទៅលក់នៅម៉ុយឃ្លាំងរំសេវ បានប្រាក់ចំនួន៦០០$ចែកគ្នាចាយអស់។

៣.តំណាងអយ្យការបានស្នើសុំឱ្យឃុំខ្លួន ☑ មិនឱ្យឃុំខ្លួន □ បណ្តោះអាសន្នលើជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ផ្អែកលើសំអាងហេតុថា៖

☑ បញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

□ រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ

☑ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☑ រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

☑ ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

☑ ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

## II.សំអាងហេតុនៃសេចក្តីសម្រេច

១. ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទឧក្រិដ្ឋ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ដែលច្បាប់កំណត់ដាក់ពន្ធនាគារលើសពី ០១ (មួយ) ឆ្នាំ ។ (មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

២.មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទគឺដើម្បី៖ (មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

-បញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

-ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី

-ធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

-ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹងនិងអាចធានាឱ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចនូវគោលដៅខាងលើ ។

-ហេតុផលជាមូលដ្ឋានពីថេរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន និងមានយោងតាមបញ្ញត្តិមាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌការឃុំខ្លួនមិនអោយលើសរយៈពេល ០៦ខែ (ប្រាំមួយខែ) បានទេ។

## ហេតុដូច្នេះសម្រេច

-ឃុំខ្លួនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ជាបណ្តោះអាសន្នរយៈពេល អតិបរិមា០៦ខែ (ប្រាំមួយខែ) ។

ថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

# លិខិតបញ្ជូន

យើង បានប្រគល់ដីកាសម្រេចឃុំបណ្ដោះអាសន្នលេខ:.........................."ឃ ១"ដ.ព.ស

ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដល់ឈ្មោះខាងក្រោម នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ។

**អ្នកប្រគល់**

**ព្រះរាជអាជ្ញា**

**អ្នកទទួល**
**មេធាវីជនត្រូវចោទ**

**ជនត្រូវចោទ**

**សំគាល់**: តាមរយៈពេលនៃការជូនដំណឹងនេះ ជនត្រូវចោទត្រូវប្រាប់ថា: ជនត្រូវចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ និងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៦៧ និងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "យ១"

លេខ.3047.យ១.ដ.យ.ដ

## ដីកាបង្គាប់ឱ្យឃុំខ្លួន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា ២០៦, ២១៩, ២២០, ២២១ និងមាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ១៨២៨ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១៣៩៣ អ.យ.ឈ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ: ១៤៣១ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ដែលទាក់ទងនឹង:

-ឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល ផ្លូវលំ ភូមិ០១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ រស់/ស្លាប់" ម្ដាយឈ្មោះ "រស់/ស្លាប់" នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន។

-ឃាត់ខ្លួននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២ ។

-ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចនៅចំណុចស្ពានទី៧ ផ្លូវជាតិលេខ៦ ក្រុមទី៤ ភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញាតិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ224."យ១"ដ.ព.ស ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ។

## បង្គាប់

១-ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ទៅឱ្យលោកប្រធានពន្ធនាគាររាជធានីភ្នំពេញ (PJ) ដោយអនុវត្តឱ្យបានត្រឹមត្រូវតាម ច្បាប់ ។

២-ឱ្យលោកប្រធានពន្ធនាគាររាជធានីភ្នំពេញ (PJ) ទទួល និងឃុំខ្លួនជននេះ រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣-ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈ ទាំងអស់សហការអនុវត្តឱ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់ ។

ថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

**ចៅក្រមស៊ើបសួរ**

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ
១៣១៦ ចុះថ្ងៃទី ២៩.១២.២០១៥
សំណុំរឿងជំនុំជម្រះលេខ
១៧៣ ចុះថ្ងៃទី ០៧.០៣.២០១៦
សាលក្រមលេខ: ៨៦ "ជ"
ះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦

**<u>តាងនាមប្រជារាស្ត្រខ្មែរ</u>**

សាលាដំបូងខេត្តសៀមរាប បានបើកសវនាការជាសាធារណៈ
នៅនាទីសាលាដំបូងខេត្តសៀមរាប សាលសវនាការលេខ ២
កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ វេលាព្រឹក
កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១៦ វេលាព្រឹក

**<u>ចៅក្រមជំនុំជម្រះ</u>**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តសៀមរាប

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៣១៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥ និងសំណុំរឿងជំនុំជម្រះលេខ: ១៧៣ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ៖

១- ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិតាភុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបររៀនជួសជុលទូរស័ព្ទ កំរិតវប្បធម៌ថ្នាក់ទី១០ថ្មី នៅលីវ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៨.១២.២០១៥ ។
- ឃុំខ្លួនថ្ងៃទី ២៩.១២.២០១៥ ។

២- ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ កំរិតវប្បធម៌ថ្នាក់ទី៦ថ្មី នៅលីវ ឪពុកឈ្មោះ [redacted] ាយឈ្មោះ: [redacted] ) ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៨.១២.២០១៥ ។
- ឃុំខ្លួនថ្ងៃទី ២៩.១២.២០១៥ ។

៣- ឈ្មោះ [redacted] ភេទប្រុស អាយុ ១៩ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិតាភុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ មុខរបររត់ម៉ូតូឌុប កំរិតវប្បធម៌ថ្នាក់ទី១០ថ្មី នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន។ (ក្នុងឃុំ)

- ចាប់ខ្លួនថ្ងៃទី ២៨.១២.២០១៥ ។

- ឃុំខ្លួនថ្ងៃទី ២៩.១២.២០១៥ ។

ត្រូវជាប់ចោទពីបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

- ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ហៅដូច ។

✓- ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]

**ភាគីដើមបណ្តឹងរដ្ឋប្បវេណី**

- ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១០១ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

- បានឃើញ ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៦៣២ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ២៥៦ ពស.ព្រជ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

**ឯអង្គហេតុកើតមានឡើងដូចតទៅ**

កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ៨ ម៉ ៣០នាទី មានករណីអំពើលួចនៅចំណុចភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដែលបង្កឡើងដោយជនជាប់ចោទចំនួន ៣នាក់ ទី [redacted] ទី២ [redacted] ហៅដូប និងទី [redacted] បានធ្វើសកម្មភាពលួចយកកុំព្យូទ័រយួរដៃចំនួន ២ (ពីរ)គ្រឿង និងទូរស័ព្ទចំនួន ១ (មួយ)គ្រឿង បន្ទាប់ពីធ្វើសកម្មភាពរួច ជនជាប់ចោទទាំងបីនាក់ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនបាន។

**សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

- ជនជាប់ចោទឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា៖ សូមតុលាការសម្រេចឲ្យខ្លួនរួចខ្លួនពីបទចោទ។

- ជនជាប់ចោទឈ្មោះ [redacted] បានធ្វើការកត់សម្គាល់ថា៖ សូមតុលាការជួយសម្រាល

ទោសដល់រូបខ្លួនផង។

- ជនជាប់ចោទឈ្មោះ [redacted]ានធ្វើការកត់សម្គាល់ថា៖ សូមតុលាការសម្រេចឲ្យខ្លួនរួចខ្លួនពីបទចោទ។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ៖ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ១០១ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦ ទុកជាបានការដដែល និងសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] បានសន្និដ្ឋានការពារថា៖ តាមចម្លើយ ជនជាប់ចោទទាំងបីនាក់ជាមិត្តភក្តិនឹងគ្នា។ ក្រោយពេលលួចបាន ឈ្មោះ [redacted]នប្រគល់កុំព្យូទ័រដែលលួចបាន ឲ្យជួយដោះលេខកូដតែប៉ុណ្ណោះ កូនក្តីខ្លួនមិនបានដឹងថា កុំព្យូទ័រនោះបានមកពីការលួចទេ។ ហេតុនេះសូមតុលាការសម្រេចដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពឡើងវិញ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោ[redacted]នសន្និដ្ឋានការពារថា៖ កូនក្តីខ្លួនបានឆ្លើយសារភាពអស់ហើយ គាត់ជាអនីតិជន។ សូមតុលាការផ្តល់ស្ថានសម្រាលទោសដល់ខ្លួនដោយអនុគ្រោះ។

<u>ផ្អែកតាមកិច្ចពិភាក្សាដេញដោល</u>

ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ការអានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ការអានចម្លើយរបស់សាក្សី

ក្រោយពីបានពិនិត្យភស្តុតាងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានស្តាប់ការកត់សម្គាល់របស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់។

## <u>សំអាងហេតុ</u>

- តាមរយៈដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៦៣២ ពស.ព្រស ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ឈ្មោ[redacted]ឯឈ្មោះ [redacted] ទៅជំនុំជម្រះពីបទ: អំពើលួច ប្រព្រឹត្តនៅភូមិតាគុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

- កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៥ ពិតជាមាន *អំពើលួច* បានកើតឡើងនៅភូមិតាគុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប បង្កឡើងដោយជនជាប់ចោទឈ្មោ[redacted] និងឈ្មោះ [redacted]ដមែន។

- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted]ានឆ្លើយសារភាពថា: កាលពីថ្ងៃទី ២៨

ខែ ធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ៥ព្រឹក ខ្លួនត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនពីបទអំពើលួច ដោយឈ្មោះ [redacted]ានទូរស័ព្ទឲ្យជួយយកកុំព្យូទ័រទៅលក់ ដោយប្រាប់ថាជាកុំព្យូទ័ររបស់ឈ្មោះ[redacted] បន្ទាប់មកខ្លួនក៏បានយកកុំព្យូទ័រទៅផ្ទះរបស់ខ្លួន ពេលដែលបើកខ្លួនឃើញមានរូបមនុស្សមិនស្គាល់ រួចក៏បានបិទ ហើយយកទៅឲ្យ[redacted] នៅពេលនោះខ្លួនមិនទាន់បានត្រឡប់ទៅផ្ទះរបស់ខ្លួនវិញទេ មួយសន្ទុះក្រោយមកស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនឈ្មោះ[redacted] ចម្លើយសារភាពនេះ មានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- ពេលសវនាការជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយសារភាពថា: ខ្លួនត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនបាននៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ៥ព្រឹក ដោយខ្លួនបានដើរម្នាក់ឯងទៅដេកក្នុងវត្តកេសរារាមក៏ប្រទះឃើញកុំព្យូទ័រយួរដៃចំនួន ២គ្រឿង ដាក់សាកក្នុងផ្ទះសំណាក់ មិនឃើញមានមនុស្ស ពេលនោះក៏កើតចិត្តចង់បាន ក៏បានដើរចូលទៅយកកុំព្យូទ័រចំនួន២គ្រឿង និងទូរស័ព្ទដៃចំនួន១គ្រឿង។ ពេលដែលលួចបានខ្លួនក៏បានទូរស័ព្ទហៅឈ្មោះ[redacted]មកដល់ក៏បានទូរស័ព្ទហៅឈ្មោះ[redacted]ឲ្យយកកុំព្យូទ័រនោះទៅតម្លើងកម្មវិធីថ្មី បន្ទាប់មករហូតដល់ភ្លឺក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង។ ចម្លើយសារភាពនេះមានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- ពេលសវនាការជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយសារភាពថា: កាល ពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥ វេលាម៉ោង ៨ភ្លឺ ខ្លួននៅបេនម៉ូតូម៉ុំផ្លូវបាក់ខែង ពេលនោះឈ្មោះ [redacted] ទូរស័ព្ទហៅខ្លួនទៅឧបវ៉ានៅមុខសាលាកេសរារាម ពេលទៅដល់ខ្លួនបានឧបវ៉ាយកកុំព្យូទ័រទៅលក់ វាបានសួរខ្លួនថាស្គាល់កន្លែងលក់អត់ ខ្លួនថាមិនស្គាល់ទេ ហើយខ្លួនក៏បានទូរស័ព្ទទៅឈ្[redacted] ជួយយកទៅលក់ ខ្លួនក៏បានដឹក[redacted] ហើយក៏ត្រឡប់មកបេនវិញប្រហែល១០នាទីក្រោយមកសមត្ថកិច្ចបានមកចាប់ខ្លួន ហើយបានសួរនាំ ខ្លួនមិនដឹងរឿងអីគេក៏ឲ្យខ្លួនទៅផ្ទះវិញ ពេលខ្លួនជិះម៉ូតូទៅផ្ទះមិនទាន់បានដល់ផង ក៏ត្រូវសមត្ថកិច្ចធ្វើការចាប់ខ្លួនម្តងទៀត។ ចម្លើយសារភាពនេះ មានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- ពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ាមចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយបញ្ជាក់ថា: នៅវេលាម៉ោង ០០ ម៉ ៣៥នាទី ខ្លួន និងអ្នកគ្រប់គ្រងឈ្មោះ [redacted]ភេទប្រុស ស្នាក់នៅផ្ទះសំណាក់ជាមួយខ្លួន បានយកកុំព្យូទ័រចំនួនចំនួន ២ (ពីរ) គ្រឿង មានម៉ាក Dell ពណ៌ខៀវចំនួន ១ (មួយ)គ្រឿង និងម៉ាក Acer ពណ៌ទឹកប្រាក់ចំនួន ១ (មួយ) គ្រឿង និងទូរស័ព្ទម៉ាក HUAWEIP7.L10 ពណ៌ស ចំនួន ១ (មួយ)គ្រឿង ទុកនៅលើតុទទួលភ្ញៀវ រួចក៏នាំគ្នាចូលសំរាក។ រហូតដល់ម៉ោង ៣ ម៉ ១៥នាទី ថ្ងៃខែឆ្នាំដដែល ឈ្មោះ[redacted]បានគេទូរស័ព្ទមកប្រាប់ខ្លួនថា មានជនមិនស្គាល់មកលួចកុំព្យូទ័រ និងទូរស័ព្ទទៅបាត់ហើយ។ ពេលទៅដល់ផ្ទះសំណាក់ខ្លួនឆែកតាម Google មើលដឹងថានៅចំណុចផ្សារពោធិ៍ បន្ទាប់មកខ្លួនបានរាយការណ៍ឲ្យសមត្ថកិច្ចកងរាជអាវុធហត្ថតែម្តង។ ចម្លើយនេះមានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- ពេលសវនាការសាក្សីឈ្មោះ[redacted]ន) តាមចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយបញ្ជាក់ថា: នៅវេលាម៉ោង ០០ ម៉ ៣០នាទី ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥ ភ្ញៀវនៅ

ផ្ទះសំណាក់បានចូលសម្រាកអស់ រូបខ្លួនក៏ចាប់ផ្តើមរៀបចំបិទទ្វារចាក់សោររបង រួចក៏ចូលសម្រាក។ លុះដល់ម៉ោង ២ ម៉ ៣០នាទី ថ្ងៃខែឆ្នាំដដែល ខ្លួនភ្ញាក់ពីដេករូបខ្លួនក៏រកមើលទូរស័ព្ទម៉ាក HUAWEIP7.L 10 ពណ៌ស និងកុំព្យូទ័រចំនួន ២ (ពីរ)គ្រឿង ដែលទុកក្នុងបន្ទប់ទទួលភ្ញៀវស្រាប់តែបាត់ ពេលនោះរូបខ្លួនចាប់ផ្តើមឆែកតាម Google Device Manager ស្រាប់តែឃើញចំណុចដែលចោរយកទូរស័ព្ទ និងកុំព្យូទ័រនៅចំណុចផ្លូវកែងតាគុល ទល់មុខសណ្ឋាគារជោគលែន ពេលដែលដឹងចំណុចហើយ រូបខ្លួនបានទូរស័ព្ទទៅម្ចាស់ផ្ទះសំណាក់អង្គរខ្មែរមេហ្សុង ហើយរូបគាត់បានទូរស័ព្ទប្តឹងសមត្ថកិច្ចកងរាជអាវុធហត្ថខេត្តសៀមរាប ។ ចម្លើយនេះ មានហេតុផលសមរម្យអាចឲ្យតុលាការជឿបាន។

- តាមរបាយការណ៍សរុបលេខ: ៣៩០/០១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៥ របស់ការិយាល័យបទល្មើសព្រហ្មទណ្ឌនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តសៀមរាប បានបញ្ជាក់ថា៖ កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៥ ឈ្មោះ [redacted] ហៅជួប ពិតជាបានធ្វើសកម្មភាពលួចយកកុំព្យូទ័រយួរដៃចំនួន ២ (ពីរ)គ្រឿង និងទូរស័ព្ទចំនួន ១ (មួយ) គ្រឿង របស់ជនរងគ្រោះឈ្មោះ [redacted] ប្រាកដមែន។

- ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ង ឈ្មោះ [redacted] លក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី ព្រមទាំងឯកសារដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់ថា៖ កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ៤ ម៉ ៣០នាទី ពិតជាមានករណីអំពើលួចនៅចំណុចភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប បង្កឡើងដោយជនជាប់ចោទចំនួន ៣នាក់ ទី១ ឈ្មោះ [redacted] ទី២ [redacted] ជួប និង [redacted] ដែលបានធ្វើសកម្មភាពលួចយកកុំព្យូទ័រយួរដៃចំនួន ២ (ពីរ)គ្រឿង និងទូរស័ព្ទចំនួន ១ (មួយ)គ្រឿង។ បន្ទាប់ពីធ្វើសកម្មភាពរួច ជនជាប់ចោទទាំងបីនាក់ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនបានប្រាកដមែន។

- ជនជាប់ចោទ [redacted], ឈ្មោះ [redacted] ឈ្មោះ: [redacted] ហៅជួប មានចេតនាទុច្ចរិត ដោយបានធ្វើសកម្មភាពលួចយកទ្រព្យសម្បត្តិរបស់អ្នកដទៃក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលអំពើនេះច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទ: *អំពើលួច* ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ៖ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ១០១ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទុកជាបានការដដែល និងសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ឃើញថាការប្តឹងសុំនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ហៅជួប ដែលបានស្នើសុំឲ្យតុលាការដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាពវិញ ឃើញថា ការស្នើសុំនេះមិនមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់អាចឲ្យតុលាការជឿបានទេ។

- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ល បានស្នើសុំឲ្យតុលាការផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួន ឃើញថា ការស្នើសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិនិត្យពិចារណាចំពោះការស្នើសុំនេះ។

- ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោ[redacted]ឈ្មោះ: [redacted] ហៅ[redacted]ហៅ[redacted]មានបញ្ហាខាងស្មារតីឡើយ ជនជាប់ចោទពិតជាបានយល់ដឹងពីផលវិបាកដែលកើតឡើងពីអំពើប្រព្រឹត្តរបស់ខ្លួន ។

- *<u>ក្រោយពីបានពិនិត្យពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់គាត់តុលាការប្រកាសថា</u>* ៖

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ: [redacted] ឈ្មោ[redacted] និងឈ្មោះ: [redacted]ពីបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

- អំពើដែលជនជាប់ចោទឈ្មោ[redacted]បានប្រព្រឹត្តធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ សន្តិសុខសណ្តាប់ធ្នាប់ សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ។

- ជនជាប់ចោទឈ្មោ[redacted]ាអនីតិជន តប្បិតុលាការសម្រេចផ្តន្ទាទោសដោយផ្អែកតាមបញ្ញត្តិមាត្រា ១៦០ កថាខណ្ឌទី១ ចំណុច១,៣ នៃក្រមព្រហ្មទណ្ឌ។

- ជនរងគ្រោះឈ្មោះ: [redacted] បានទទួលទ្រព្យសម្បត្តិរបស់ខ្លួនវិញអស់ហើយ តាមរយៈកំណត់ហេតុប្រគល់ និងទទួលលេខ: ១១៨/២០១៥ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៥ ហើយមិនបានចូលខ្លួនមកប្តឹងទាមទារសំណងជម្ងឺចិត្តទេ តប្បិតុលាការមិនពិនិត្យពិចារណាចំពោះបញ្ហានេះឡើយ។

- វត្ថុចាប់យកដូចមាននៅក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ: ០២ វត/ព្រទ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ មានដូចជា៖ ទូរស័ព្ទដៃចំនួន ២ (ពីរ)គ្រឿង ទូរស័ព្ទដៃម៉ាក Q-Mobile Model Q113 ពណ៌ខ្មៅលាយឈាម ជ្រូក ចំនួន ១ (មួយ)គ្រឿង និងទូរស័ព្ទដៃម៉ាក LG Model GS102 ពណ៌ខ្មៅលាយឈាមជ្រូកចំនួន ១ (មួយ) គ្រឿង គឺជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន មិនមែនជាវត្ថុតាងនៃបទល្មើសទេ តប្បិតុលាការសម្រេចប្រគល់ឲ្យ ម្ចាស់ដើមវិញ។ តាមមាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះទើបសម្រេចសេចក្តី</u>

១- ផ្តន្ទាទោស៖

ក- ឈ្មោះ: [redacted]ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ (មួយ) [redacted]

ខ- ឈ្មោ[redacted]ទប្រុស អាយុ ១៧ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ (មួយ)ឆ្នាំ ៦ (ប្រាំមួយ)ខែ ។

គ- ឈ្មោះ: [redacted]ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ (មួយ)ឆ្នាំ ៣ (បី)ខែ ។

ពីបទ: **អំពើលួច** ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ ,មាត្រា ៣៥៦ និងមាត្រា ១៦០ កថាខណ្ឌទី១ ចំណុច១,៣ នៃក្រមព្រហ្មទណ្ឌ។

២- វត្ថុចាប់យកដូចមាននៅក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ: ០២ វត/ ព្រទ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៦ មានដូចជា៖ ទូរស័ព្ទដៃចំនួន ២ (ពីរ)គ្រឿង ទូរស័ព្ទដៃម៉ាក Q-Mobile Model Q113 ពណ៌ខ្មៅលាយឈាមជ្រូក ចំនួន ១ (មួយ)គ្រឿង និងទូរស័ព្ទដៃម៉ាក LG Model GS102 ពណ៌ខ្មៅលាយឈាមជ្រូកចំនួន ១ (មួយ)គ្រឿង **សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ**។ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted]

- ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| សៀមរាប , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ | សៀមរាប , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ |
| **ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

១៣៤៣
២៣-០៥-១៧
06:00

សំណុំរឿងព្រហ្មទណ្ឌលេខ ១៣១១
ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦
សំណុំរឿងជំនុំជម្រះលេខ ១៦៧
ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧
សាលក្រមលេខ៖ ០៣ "ឆ.២"
ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាអសាធារណៈនៅសាលាដំបូងខេត្តសៀមរាប។
កាលបរិច្ឆេទបើកសវនាការ ៖ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៧ ។
កាលបរិច្ឆេទប្រកាសសាលក្រមជាអសារណៈ ៖ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៧។

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ឋានៈ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ឋានៈ ចៅក្រមប្រឹក្សាជំនុំជម្រះ
លោក [redacted] ឋានៈ ចៅក្រមប្រឹក្សាជំនុំជម្រះ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ឋានៈព្រះរាជអាជ្ញារង

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ឋានៈក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៣១១ អ.ក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស កើតនៅភូមិទក្សិណខាងត្បូង ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាបកាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី០៧ មានទីលំនៅភូមិទក្សិណខាងត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន។ ក្នុងឃុំ

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៨៨៨/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

២. ឈ្មោះ [redacted] ភេទប្រុស អាយុ១៨ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិទក្សិណខាងត្បូង សង្កាត់ គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី០២ មុខរបរគ្មាន ទីលំនៅសព្វថ្ងៃនៅភូមិទក្សិណខាងត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុន គ្មាន។ (ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩៨៩/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

៣. ឈ្មោះ [redacted] ភេទប្រុស អាយុ២១ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី០៨ មុខរបរគ្មាន ទីលំនៅសព្វថ្ងៃ នៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩៩០/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

៤. ឈ្មោះ [redacted] ភេទស្រី អាយុ១៦ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជ្រៃ ឃុំខ្វាស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាន់សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី០៧ ទីលំនៅសព្វថ្ងៃនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោ[redacted]) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុន គ្មាន។ (ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៩៩១/២០១៦ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។.

ត្រូវជាប់ចោទពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ កថាខណ្ឌ១ និងកថាខណ្ឌ២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥. ឈ្មោះ [redacted] ភេទប្រុស អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ ជាជនត្រូវចោទ មុខរបរ កម្មករ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិទក្សិណត្បូង ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ ទី០៦ ឪពុកឈ្មោ[redacted]ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted]មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (គេចខ្លួន)

៦. ឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ ជាជនត្រូវចោទ មុខរបរ គ្មាន កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិខ្មៀន ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅ បច្ចុប្បន្ននៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០៧ ឪពុកឈ្មោះ ហាន [redacted]ម្តាយ ឈ្មោះ [redacted]) នៅលីវ ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ត្រូវជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្មៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- លោក [redacted]មធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] និង [redacted]។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ០៩/២០១៧ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

បានចេញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៣៨ ពស.ព្រស/២០១៧ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង១៧និង២០នាទី ស្ថិតនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កម្លាំងសមត្ថកិច្ចបានចុះល្បាតលើដងផ្លូវ បានប្រទះឃើញឈ្មោះ [redacted] និងឈ្មោះ [redacted] ហើយសមត្ថកិច្ចបានធ្វើការសួរចម្លើយ ពួកគេបានសារភាពថា ពួកគេពិតជាបានធ្វើសកម្មភាពប្រើប្រាស់ថ្នាំញៀន ប្រភេទម៉ាទឹកកកពិតប្រាកដមែន ដែលថ្នាំញៀននេះពួកគេបានចូល លុយគ្នាទិញពីឈ្មោះ [redacted] ឈ្មោះ [redacted] និងមនុស្សប្រុសមិនស្គាល់ឈ្មោះប្រើប្រាស់លេខទូរស័ព្ទ ០៦៩៧៩៥៩៧២ និងលេខ ០៩៨ ៨៦៨ ៨៩៨ ។ ក្រោយពីធ្វើការសួរចម្លើយហើយ សមត្ថកិច្ចបានបន្តធ្វើ ការឃាត់ខ្លួនឈ្មោះ [redacted] និងឈ្មោះ [redacted] ហើយពួកគេទាំងពីរនាក់បានឆ្លើយសារភាពថា ពួកគេ ពិតជាធ្លាប់ប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក ពិតប្រាកដមែន ដោយថ្នាំញៀននោះពួកគេបានចូលលុយគ្នា ទិញពីឈ្មោះ [redacted]

**នាពេលសវនាការ**

១.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួន កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ពេលខ្លួនកំពុងជិះម៉ូតូដើរលេង ដោយសារប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ទិញពីឈ្មោះ [redacted] ថ្លៃ ១០០០០រៀល ទៅ ២០០០០រៀល បានបូនលើក យកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] ទើបប្រើប្រាស់ ០៤ដង មកពីដើរតាមគេ។ ខ្លួនអត់ដែលចាត់ចែងឲ្យគេប្រើប្រាស់គ្រឿងញៀនទេ ថ្នាំញៀន ឈ្មោះ [redacted] ជាអ្នកទិញ ពេលសមត្ថកិច្ចឃាត់ខ្លួនអត់បានដកហូតអ្វីទេ ខ្លួនទទួលយកបទប្រើប្រាស់គ្រឿងញៀន។ ខ្លួនទៅទិញថ្នាំញៀនជាមួយឈ្មោះ [redacted] ចូលលុយគ្នាទិញម្នាក់ ១០០០០រៀល ពីឈ្មោះ [redacted] ស្គាល់លេខទូរស័ព្ទតាមគេ។ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] និងឈ្មោះ [redacted] ទេ។ បន្ទាប់ពីទិញថ្នាំញៀនរួច យកមកប្រើប្រាស់ជាមួយគ្នា។

២.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួន និងឈ្មោះ [redacted] ទៅទិញថ្នាំញៀនជាមួយគ្នា ចូលលុយគ្នាទិញ នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ចំពោះឧបករណ៍ប្រើប្រាស់ជួយគ្នាធ្វើ។ ពេលសមត្ថកិច្ចចាប់ខ្លួន អត់បានប្រើប្រាស់គ្រឿងញៀនទេ ខ្លួនប្រើប្រាស់គ្រឿងញៀនបាន ០៤ដង ជាមួយឈ្មោះ [redacted] ខ្លួននិងឈ្មោះ [redacted] ទៅទិញថ្នាំញៀនជាមួយគ្នា ០៤ដង អត់ដែលទៅម្នាក់ឯងទេ លុយចូលគ្នា ពេលខ្លះលុយរបស់ឈ្មោះ [redacted] អ្នកលក់នៅភូមិជាមួយគ្នា អត់គេទាក់ទងទិញទេ ដើរទៅទិញ ចេះប្រើប្រាស់តាមគេ ខ្លួនជាអ្នកនាំឈ្មោះ [redacted] ប្រើប្រាស់។ ថ្នាំញៀននេះ ខ្លួនទិញពីឈ្មោះ [redacted] អត់បានទិញពីអ្នកផ្សេងទេ អត់ដែលស្គាល់ឈ្មោះ [redacted] ទេ។

៣.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ថ្នាំញៀនដែលប្រើប្រាស់ទិញពីមនុស្សមិន

ស្គាល់ តាមឈ្មោះ [redacted] ឲ្យលេខ ហើយតាមរៀង ខ្លួនអ្នកទាក់ទងទិញផ្ទាល់ តម្លៃ ១០ម៉ឺនរៀល លុយរបស់ឈ្មោះ [redacted] ទៅទិញគ្នា ០៣នាក់។ ខ្លួនអត់ដឹងថាជាប់ប៉ុន្មានរឿងទេ ជាប់បានមួយខែ តែហៅមកសួរទៀត ពេលឃាត់ខ្លួនអត់បានដកហូតអ្វីទេ។ ខ្លួនធ្លាប់ទិញពីឈ្មោះ [redacted] ម្តង ។

៤. ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនបានទិញថ្នាំញៀនពីមនុស្សមិនស្គាល់ តែតាមទូរស័ព្ទ បានលេខពីឈ្មោះ [redacted] តម្លៃ ១០ម៉ឺនរៀល ជក់ជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] លុយជារបស់ឈ្មោះ [redacted] ឲ្យទិញយកមកប្រើប្រាស់ ចេះប្រើប្រាស់គ្រឿងញៀនកាលពីខែតុលា ឆ្នាំ២០១៦ ចេះប្រើប្រាស់ដោយសារធ្វើការងារយប់ងងុយដេក។ ខ្លួនអត់ដែលស្គាល់អ្នកលក់ទេ ស្គាល់តាមឈ្មោះ [redacted] ត្រូវជាមិត្តរបស់ឈ្មោះ [redacted] ខ្លួនក៏ធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] ដែរ។ ខ្លួនអត់ដែលស្គាល់ឈ្មោះ [redacted] ទេ។ ចំពោះឧបករណ៍ប្រើប្រាស់ គឺឈ្មោះ [redacted] និងឈ្មោះ [redacted] ធ្វើ។

៥. ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួននៅម្តុំខាងក្រោយអូរឫស្សី... 

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយនាពេលសវនាការ ពិនិត្យអង្គហេតុ និងតាមការពិនិត្យភស្តុតាងនានាដែលមានក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទបានសារភាពថាពិតជាបានប្រព្រឹត្តអំពើ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមែន ដែលថ្នាំញៀនប្រើប្រាស់ទិញពីឈ្មោះ [redacted] ចំណែកឈ្មោះ [redacted] បានឆ្លើយលាក់បាំងការពិត ពុំអាចឲ្យតុលាការជឿជាក់បាន ដូច្នេះ តំណាងអយ្យការនៅរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ព្រមទាំងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted]។
- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និង [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនជាអនីតិជន ហើយនាពេលសវនាការក៏បានឆ្លើយសារភាពការពិត ទទួលស្គាល់កំហុស ដូចនេះ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។
- ជនជាប់ចោទឈ្មោះ [redacted] ធ្វើសំណូមពរជាសម្តីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយ

បន្ធូរបន្ថយទោសផង។

- ជនជាប់ចោទឈ្មោះ [redacted] ធ្វើសំណូមពរជាសម្ដីចុងក្រោយបង្អស់ថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសផង។

  - ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ។
  - ក្រោយបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។
  - ក្រោយបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ។
  - ក្រោយបានស្ដាប់សំណូមពរជាសម្ដីចុងក្រោយបង្អស់របស់ជនជាប់ចោទ។
  - ក្រោយពីបានពិនិត្យភស្ដុតាងជាឯកសារ និងកំណត់ហេតុផ្សេងៗ។
  - ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងខេត្តសៀមរាប**

**យល់ឃើញថា**

១.កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ថិតនៅចំណុចភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ [redacted] ភេទស្រី អាយុ ១៦ឆ្នាំ ,ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ បានធ្វើសកម្មភាពចូលលុយគ្នា និងបានទៅទិញថ្នាំញៀនពីឈ្មោះ ហៀង [redacted] ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ដើម្បីយកមកប្រើប្រាស់ជាមួយគ្នា និងបានសហការគ្នារៀបចំឧបករណ៍សម្រាប់ប្រើប្រាស់។

២.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួន កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ពេលខ្លួនកំពុងជិះម៉ូតូដើរលេង ដោយសារប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ទិញពីឈ្មោះ [redacted] តម្លៃ ១០០០០រៀល ទៅ ២០០០០រៀល បានបួនលើក យកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] ទើបប្រើប្រាស់ ០៤ដង មកពីដើរតាមគេ។ ខ្លួនអត់ដែលចាត់ចែងឲ្យគេប្រើប្រាស់គ្រឿងញៀនទេ ថ្នាំញៀន ឈ្មោះ [redacted] ជាអ្នកទិញ ពេលសមត្ថកិច្ចឃាត់ខ្លួនអត់បានដកហូតអ្វីទេ ខ្លួនទទួលយកបទប្រើប្រាស់គ្រឿងញៀន។ ខ្លួនទៅទិញថ្នាំញៀនជាមួយឈ្មោះ [redacted] ចូលលុយគ្នាទិញម្នាក់ ១០០០០រៀល ពីឈ្មោះ [redacted] ស្គាល់លេខទូរស័ព្ទតាមគេ។ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] ងឈ្មោះ [redacted] ទ។ បន្ទាប់ពីទិញថ្នាំញៀនរួច យកមកប្រើប្រាស់ជាមួយគ្នា។

៣.ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួន និងឈ្មោះ [redacted] ទៅទិញថ្នាំញៀនជាមួយគ្នា ចូលលុយគ្នាទិញ នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ចំពោះឧបករណ៍ប្រើប្រាស់ជួយគ្នាធ្វើ។ ពេលសមត្ថកិច្ចចាប់ខ្លួន អត់បានប្រើប្រាស់គ្រឿងញៀនទេ ខ្លួនប្រើប្រាស់គ្រឿងញៀនបាន ០៤ដង ជាមួយឈ្មោះ [redacted] ខ្លួននិងឈ្មោះ [redacted] ទៅទិញថ្នាំញៀនជាមួយគ្នា ០៤ដង អត់ដែលទៅម្នាក់ឯងទេ លុយចូលគ្នា ពេលខ្លះលុយរបស់

ឈ្មោះ[redacted] អ្នក[illegible] អត់គេទាក់ទងទិញទេ ដើរទៅទិញ ចេះប្រើប្រាស់តាមគេ ខ្លួនជាអ្នកនាំឈ្មោះ[redacted]ប្រើប្រាស់។ ថ្នាំញៀននេះ ខ្លួនទិញពីឈ្មោះ[redacted] អត់បានទិញពីអ្នកផ្សេងទេ អត់ដែលស្គាល់ឈ្មោះ[redacted]ទេ។

៤. ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា ថ្នាំញៀនដែលប្រើប្រាស់ទិញពីមនុស្សមិនស្គាល់ តាមឈ្មោះ[redacted] ឲ្យលេខ វេលុយតាមវីង ខ្លួនអ្នកទាក់ទងទិញផ្ទាល់ តម្លៃ ១០ម៉ឺនរៀល លុយរបស់ឈ្មោះ[redacted]ទៅទិញគ្នា ០៣នាក់។ ខ្លួនអត់ដឹងថាជាប់ប៉ុន្មានរឿងទេ ជាប់បានមួយខែគេហៅមកសួរទៀត ពេលឃាត់ខ្លួនអត់បានដកហូតអ្វីទេ។ ខ្លួនធ្លាប់ទិញពីឈ្មោះ[redacted]។

៥. ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា ខ្លួនបានទិញថ្នាំញៀនពីមនុស្សមិនស្គាល់ គេតាមទូរស័ព្ទ បានលេខពីឈ្មោះ[redacted]តម្លៃ ១០ម៉ឺនរៀល ដក់ជាមួយឈ្មោះ[redacted]និងឈ្មោះ[redacted]លុយជារបស់ឈ្មោះ[redacted]ឲ្យទិញយកមកប្រើប្រាស់ ចេះប្រើប្រាស់គ្រឿងញៀនកាលពីខែតុលា ឆ្នាំ២០១៦ ចេះប្រើប្រាស់ដោយសារធ្វើការងារយប់ងងុយដេក។ ខ្លួនអត់ដែលស្គាល់អ្នកលក់ទេ ស្គាល់តាមឈ្មោះ[redacted] ត្រូវជាមិត្តរបស់ឈ្មោះ[redacted] ខ្លួនក៏ធ្លាប់ទិញថ្នាំញៀនពីឈ្មោះ[redacted]ផងដែរ។ ខ្លួនអត់ដែលស្គាល់ឈ្មោះ[redacted]ទេ។ ចំពោះឧបករណ៍ប្រើប្រាស់ គឺឈ្មោះ[redacted]និងឈ្មោះ[redacted]អ្នកធ្វើ។

៦. ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួននៅម្តុំខារ៉ាអូខេរ៉េកភ៉ក។ កន្លងមក ខ្លួនអត់ដែលលក់គ្រឿងញៀនទេ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន។ ខ្លួនមានបងប្អូន ០៧នាក់ អត់ស្គាល់ទេ អត់ប្រើប្រាស់ទូរស័ព្ទទេ ប្រើប្រាស់មួយខ្សែ អត់ចាំលេខ បងប្អូនជាប់ពន្ធនាគារជាមួយ ០៣នាក់ ។

៧. ផ្អែកតាមចម្លើយរបស់ឈ្មោះ[redacted]និងឈ្មោះ[redacted]នាពេលសវនាការឃើញថា នៅថ្ងៃកើតហេតុ ពួកខ្លួនបានទៅទិញថ្នាំញៀនទាំងអស់គ្នាពីឈ្មោះ[redacted]ដោយបានចូលលុយគ្នាទិញម្នាក់ ១០០០០រៀល ចំនួន ០១កញ្ចប់តូច បន្ទាប់មក ក៏បាននាំគ្នារៀបចំឧបករណ៍ប្រើប្រាស់នៅផ្ទះរបស់ឈ្មោះ[redacted]តែម្តង។ ចម្លើយនេះ គឺប្រហាក់ប្រហែលគ្នាទៅនឹងចម្លើយផ្សេងទៀត ដែលបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលអាចឲ្យតុលាការជឿជាក់បាន។

៨. ផ្អែកតាមចម្លើយរបស់ឈ្មោះ[redacted]និងឈ្មោះ[redacted]នាពេលសវនាការឃើញថា នៅថ្ងៃកើតហេតុ គឺពួកខ្លួនបានទៅទិញថ្នាំញៀនពីជនមិនស្គាល់ឈ្មោះ ដែលស្គាល់តាមរយៈឈ្មោះ[redacted] ហើយលុយដែលទិញថ្នាំញៀនជារបស់ឈ្មោះ[redacted]បន្ទាប់ពីទិញថ្នាំញៀនបានហើយ ក៏នាំគ្នារៀបចំឧបករណ៍ប្រើប្រាស់ទាំងអស់គ្នាតែម្តង។ ចម្លើយនេះ គឺប្រហាក់ប្រហែលគ្នាទៅនឹងចម្លើយផ្សេងទៀត ដែលបានឆ្លើយនៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលអាចឲ្យតុលាការជឿជាក់បាន។

៩. ផ្អែកតាមចម្លើយជនជាប់ចោទឈ្មោះ[redacted]ឈ្មោះ[redacted],ឈ្មោះ[redacted]និង

ឈ្មោះ [redacted] បានបញ្ជាក់ថា ថ្នាំញៀនដែលបានទិញយកមកប្រើប្រាស់នោះ គឺបានទិញពីឈ្មោះ [redacted] ភេទប្រុស អាយុ ៣០ឆ្នាំ ។ ជនជាប់ចោទឈ្មោះ [redacted] បានរត់គេចខ្លួន និងមានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៣៦៦/១៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ។

១០.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការឃើញថា ជនជាប់ចោទពុំបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនទេ គឺបានបដិសេធនូវការចោទប្រកាន់របស់តុលាការ ដែលជាចម្លើយលាក់បាំងនូវការពិតនូវអំពើដែលខ្លួនបានប្រព្រឹត្ត ដែលពុំអាចឲ្យតុលាការជឿជាក់បានទេ ព្រោះផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] បានបញ្ជាក់ថា ធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ [redacted] បានម្តង។ តាមរបាយការណ៍របស់សមត្ថកិច្ច បានផ្តល់សារគាជាតិរបស់ជនជាប់ចោទថា ឈ្មោះ [redacted] ហៅក្រៅ [redacted] ភេទប្រុស កើតឆ្នាំ១៩៩០ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិខ្វៀន ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ ហាន [redacted] ម្តាយឈ្មោះ [redacted] នៅលីវ។ បើពិនិត្យផ្ទៀតផ្ទាត់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] និងភស្តុតាងឃើញថា ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ដែលបានបង្ហាញខ្លួននាពេលសវនាការ គឺពិតជាជនជាប់ចោទដែលបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។ ជនជាប់ចោទរូបនេះ បានរត់គេចខ្លួន និងមានដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៣៦៥/១៦ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ ប៉ុន្តែជននេះត្រូវបានឃុំខ្លួននៅក្នុងសំណុំរឿងផ្សេង និងត្រូវបានបង្គាប់ឲ្យពន្ធនាគារយកមកធ្វើការពិភាក្សាដេញដោលនាពេលសវនាការជាសាធារណៈ។ តុលាការនឹងបង្គាប់ឲ្យបញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនពាបអំណាចសាលក្រមនេះ។

១១.ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ,ឈ្មោះ [redacted] ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ គឺជានីតិជន ដែលមានស្មារតី ដឹងខុសត្រូវគ្រប់គ្រាន់ដូច្នេះ រាល់អំពើរបស់ជនជាប់ចោទរូបនេះសុទ្ធតែបានឆ្លងកាត់ការពិចារណាច្បាស់លាស់។

១២.ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ១៦ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជាអនីតិជន ប៉ុន្តែតាមកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ឃើញថា ជនជាប់ចោទមានស្មារតីយល់ដឹងខុសត្រូវ នូវអំពើដែលខ្លួនបានប្រព្រឹត្ត ដូច្នេះ រាល់អំពើរបស់ជនជាប់ចោទរូបនេះសុទ្ធតែបានឆ្លងកាត់ការពិចារណាច្បាស់លាស់។

១៣.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គមជាតិ ព្រមទាំងបំពានលើច្បាប់ជាធរមានរបស់រដ្ឋ ។

១៤.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំក្សាបទចោទប្រកាន់ និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ព្រមទាំងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted]

ក្រម ដើម្បីយកមកអនុវត្តទោស ។ តុលាការយល់ឃើញថា ការប្តឹងចោទប្រកាន់របស់តំណាងអយ្យការ គឺមានទំនាក់ទំនងអង្គហេតុ និងអង្គច្បាប់ ដើម្បីគាំទ្រដល់ការចោទប្រកាន់លើជនជាប់ចោទ។ តុលាការពិចារណា។

១៥.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារស្នើសុំតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ព្រោះកូនក្តីខ្លួនជាអនីតិជន។តុលាការនឹងពិចារណាលើការបន្ធូរបន្ថយទោសដល់ជនជាប់ចោទទាំងពីរនាក់ តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៦.មានភស្តុតាងបញ្ជាក់ពីពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ ,ឈ្មោះ [redacted] ភេទស្រី អាយុ ១៦ឆ្នាំ ,ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៧.មានភស្តុតាងបញ្ជាក់ពីពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៨.វត្ថុចាប់យក ស្រោមសំបុត្រពណ៌ខ្លឹមខ្នុរ បិទជិតមានស្នាមមេដៃជនត្រូវចោទឈ្មោះ [redacted] ចំនួន ០១ (ឧបករណ៍ប្រើប្រាស់គ្រឿងញៀន) ដូចក្នុងដីកាបង្គាប់ឲ្យក្សាទុកវត្ថុតាងដែលចាប់យកលេខ ៤៤២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ តុលាការនឹងសម្រេចរឹបអូស តាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**<u>ហេតុដូច្នេះ ទនិច្ឆ័យសេចក្ត</u>**

**១.** ផ្តន្ទាទោសជនជាប់ចោទ៖

**ក.**ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **<u>០១(មួយ)ឆ្នាំ</u>** ។

**ខ.**ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **<u>០១(មួយ)ឆ្នាំ</u>** ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យ

គ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

គ.ឈ្មោះ [redacted]ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ អនុវត្តទោស ០១(មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ទោសនៅសល់ត្រូវព្យួរធម្មតា ។

ឃ.ឈ្មោះ[redacted]ភេទប្រុស អាយុ២១ឆ្នាំ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ អនុវត្តទោស ០១(មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ទោសនៅសល់ត្រូវព្យួរធម្មតា ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ ១ និងកថាខណ្ឌ ២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ [redacted]ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ។

ច.ឈ្មោ[redacted]ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ (ដូចមានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ និងកថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២. បង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោ[redacted]ដូចមានក្នុងអត្តសញ្ញាណខាងលើ) យកទៅអនុវត្តទោសនៅក្នុងពន្ធនាគារខេត្តសៀមរាប តាមអំណាចសាលក្រមនេះ។

៣. បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទឈ្មោ[redacted]តាមអំណាចសាលក្រមនេះ។

៤. បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៣៦៥/១៦ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ.២០១៦ តាមអំណាចសាលក្រមនេះ។

៥. វត្ថុចាប់យក ស្រោមសំបុត្រពណ៌ខ្ចីមខ្មរ បិទជិតមានស្នាមមេដៃជនត្រូវចោទឈ្មោះ[redacted] ចំនួន ០១ (ឧបករណ៍ប្រើប្រាស់គ្រឿងញៀន) ដូចក្នុងដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងដែលចាប់យកលេខ ៤៤២ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ សម្រេចរឹបអូស។

៦. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាអសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ[redacted]

[redacted] និង [redacted] និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និង [redacted] និងកំបាំងមុខជនជាប់ចោទ ឈ្មោះ [redacted] ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា [redacted] | [redacted] | [redacted] | ហត្ថលេខា និងត្រា [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
សៀមរាប,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី 19 ខែ [illegible] ឆ្នាំ២០17
ក្រឡាបញ្ជី

[redacted]



Scanned by CamScanner

# ឧបសម្ព័ន្ធទី៥

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៦៥៨
ុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧

សាលក្រម
លេខ ៨៧១ "ម" ក្រ៦
ុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ១៤:៣០នាទីរសៀល ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៥៨ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិឧកញ៉ាប៉ាង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវបេតុង ភូមិដំណាក់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយ ឈ្មោ [redacted] ជាអនីតិជនទោសពីមុនគ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨០៥ "ធ" ដ.យ.ដ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ១១២B ផ្លូវ១៧៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

២-ឈ្មោះ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិព្រែកធំ ឃុំអ្នកលឿង ស្រុកព្រៃវែង ខេត្តព្រៃវែង មានអាសយដ្ឋាន

ស្នាក់នៅភូមិវិមានទ្រង់ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ នៅលើវ ឪពុក ឈ្មោ[redacted]ស់ ម្ដាយឈ្មោ[redacted] ជាអនីតិជន ទោសពីមុនគ្មាន ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ១១២B ផ្លូវ១៧៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ជនជាប់ចោទពីបទ៖ **ហិង្សាយដោយចេតនា (មានស្ថានទម្ងន់ទោសប្រើដាវស៊ាំម៉ូរ៉ៃ)** ប្រព្រឹត្តនៅចំណុចមុខបុរីពិភពថ្មី ផ្លូវអើ ភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃស្នាក់នៅភូមិក្រាំងអង្ក្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

-បានឃើញរបាយការណ៍សំយោគលេខ ០៦០/២០១៧ រ.ប.ក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាដំណោះស្រាយលេខ ១៧៤៧ "ធ" ជ.ជ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចរក្សាជនជាប់ចោទឲ្យនៅជាប់ឃុំបណ្ដោះអាសន្នលេខ ៣៥៣១ "ធ" ដ.ឃ.ជ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ មានករណីហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសប្រើដាវស៊ាំម៉ូរ៉ៃ) បង្កឡើងដោយជនត្រូវចោទចំនួន០៤នាក់ ១.ឈ្មោះ[redacted]ភេទប្រុស អាយុ១៧ឆ្នាំ, ២.ឈ្មោះ[redacted]ភេទប្រុស អាយុ២១ឆ្នាំ, ៣.ឈ្មោ[redacted]ភេទប្រុស អាយុ១៩ឆ្នាំ និង ៤.ឈ្មោះ[redacted]ភេទប្រុស អាយុ១៧ឆ្នាំ ដោយមុនពេលកើតហេតុ ជនរងគ្រោះឈ្មោ[redacted]ាសន្តិសុខយាមនៅមុខបុរីពិភពថ្មី ផ្លូវអើ ភូមិក្រាំងអង្ក្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពេលនោះក្រុមជនត្រូវចោទបានជិះម៉ូតូចំនួន០២គ្រឿង លឿនដូចហោះនៅក្នុងបុរីពិភពថ្មី ពេលនោះជនរងគ្រោះបានស្រែកឲ្យក្រុមជនត្រូវចោទទាំងនោះថា "ម៉េចក៏ជិះម៉ូតូលឿនម្ល៉េះ" ហើយជនរងគ្រោះ និងក្រុមជនត្រូវចោទក៏មានទំនាស់សំដីគ្នាឡើង រហូតមានជម្លោះជាមួយក្រុមជនត្រូវចោទទាំងនោះ រួចក៏បែកគ្នាទៅ ។ ពេលនោះជនត្រូវចោទឈ្មោះ [redacted] ជាអ្នកកាន់ដាវស៊ាំម៉ូរ៉ៃជាប់និងដៃខាងស្ដាំ ដោយជនត្រូវចោទឈ្មោះ[redacted]បានបើកម៉ូតូឌុបជនត្រូវចោទឈ្មោះ[redacted]ជិះមកដល់ចំណុចកើតហេតុខាងលើ ភ្លាមនោះជនត្រូវចោទឈ្មោះ[redacted]បានចុះពីលើម៉ូតូកាន់ដាវស៊ាំម៉ូរ៉ៃ ស្ទុះចូលទៅកាប់ជនរងគ្រោះឈ្មោះ[redacted]ត្រូវចំដៃខាងឆ្វេងបណ្ដាលឲ្យរងរបួស ស្របពេលនោះក៏មានសមត្ថកិច្ចចុះល្បាតក្នុងមូលដ្ឋានមកទាន់ហេតុការណ៍ ក៏ធ្វើការឃាត់ខ្លួនជនត្រូវចោទឈ្មោះ[redacted]មទាំងវត្ថុតាង ចំណែកឯជនត្រូវចោទ ០៣នាក់ទៀត បានរត់គេចខ្លួនបាត់ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១៩៖៣០ នាទី មុនពេលកើតហេតុខ្លួន និងមិត្តភ័ក្រ្ត ០៣នាក់ឈ្មោ[redacted]ឈ្មោះ[redacted] និងឈ្មោះ[redacted]បានជុំគ្នាអង្គុយលេងនៅសួនច្បារ នៅក្នុងបុរីពិភពថ្មី ផ្លូវអ៊ី ភូមិអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ ពេលខ្លួននិងមិត្តភ័ក្រ្តកំពុងអង្គុយជជែកគ្នាលេង ស្រាប់តែសន្តិសុខយាមក្នុងបុរីចូលមកស្រែនាំខ្លួនថា៖ "ពួកខ្លួនមកអុកឡុងនៅក្នុងបុរីពិភពថ្មី" ហើយសន្តិសុខម្នាក់នោះក៏បានវាយខ្លួនចំចុងចិញ្ចើមក្រោមភ្នែកខាងស្តាំចំនួន០១ដៃ ភ្លាមនោះក្រុមរបស់ខ្លួនបាននាំគ្នាជិះម៉ូតូ ចេញក្រៅបុរីពិភពថ្មី ដោយឈ្មោះ[redacted]បានយកដាវស៊ាំម៉ូរ៉ៃចំនួនមួយដើមមកប្រគល់ឲ្យខ្លួន ខ្លួនជាអ្នកកាន់ រីឯឈ្មោ[redacted]អ្នកបើកម៉ូតូឌុបឈ្មោះ[redacted]លុះជិះមកដល់សួនច្បារក្នុងបុរីពិភពថ្មី បានឃើញសន្តិសុខយាមនៅក្នុងបុរីពិភពថ្មី ដែលវាយខ្លួនកំពុងឈរនៅចិញ្ចើមផ្លូវក្បែរសួនច្បារ ភ្លាមនោះខ្លួនបានចុះពីលើម៉ូតូ កាន់ដាវស៊ាំម៉ូរ៉ៃ ស្ទុះទៅកាប់សន្តិសុខម្នាក់នោះត្រូវចំដៃ រីឯបក្ខពួករបស់ខ្លួនចំនួន០៣នាក់ទៀត កាន់ដុំថ្មជាប់ដៃគប់ទៅលើសន្តិសុខនោះដែរ ខណៈពួកខ្លួនកំពុងធ្វើសកម្មភាព ស្រាប់តែសមត្ថកិច្ចមកដល់ ក៏ធ្វើការឃាត់ខ្លួនតែម្តង ។

-ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការស្តាប់ចម្លើយជនរងគ្រោះឈ្មោ[redacted]បានឆ្លើយថា៖ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ខ្លួនបានចេញទៅយាមនៅតាមគោលដៅនៅក្នុងបុរីពិភពថ្មី ដែលស្ថិតនៅភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មុនពេលកើតហេតុម៉ោងប្រហែល ១៦៖១០នាទី មានក្រុមក្មេងស្ទាវមួយក្រុមពុំស្គាល់អត្តសញ្ញាណ បានជិះ ម៉ូតូចំនួន ០២គ្រឿ ង លឿនដូចហោះក្នុងបុរីពិភពថ្មី ចំណែកឯខ្លួនបានស្រែកឲ្យក្រុមក្មេងស្ទាវទាំងនោះថា "ម៉េចក៏ជិះម៉ូតូលឿនម៉េស" ពេលនោះខ្លួនក៏មានទំនាស់សំដីជាមួយក្រុមក្មេងស្ទាវទាំងនោះ ។ លុះម៉ោងប្រហែល ១៩៖៣០ នាទី នៅពេលខ្លួនកំពុងតែអង្គុយយាមនៅចំណុចកើតហេតុខាងលើ ស្រាប់តែក្រុមក្មេងស្ទាវចំនួន ០៤នាក់ ដោយនៅក្នុងនោះមានម្នាក់យកដាវស៊ាំម៉ូរ៉ៃមកកាប់ខ្លួនបណ្តាលឲ្យមានរបួសស្នាម ភ្លាមនោះសមត្ថកិច្ចដែលកំពុង ល្បាតនៅក្បែរនោះ មកធ្វើកាឃាត់ខ្លួនឈ្មោះ[redacted]ចំណែកជនល្មើសចំនួន ០៣នាក់ ទៀតបានរត់គេចខ្លួនបាត់តែម្តង ។

<u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ:</u>

ឆ្លងតាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ជនរងគ្រោះ និងវត្ថុចាប់យក ស៊ុសង្វាក់ទៅនឹងអង្គហេតុ ដែលបានធ្វើការចោទប្រកាន់ ហេតុនេះតំណាងអយ្យការប្តឹងសុំរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ១៣១៤ អ.យ.ប ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ ទុកដដែល និងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

<u>សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ៖</u>

ឆ្លងតាមចម្លើយរបស់កូនក្តីឃើញថាបានសារភាពអំពីអំពើប្រព្រឹត្តពុំបង្កការលំបាកដល់អង្គសវនាការទេ ហេតុនេះស្នើសុំតុលាការពិចារណាអំពីស្ថានសំរាលទោស ដោយសារគាត់ជាអនីតិជន ទើបតែប្រព្រឹត្តបទល្មើសលើកទី១ ដើម្បីមានឱកាសកែប្រែខ្លួនជាពលរដ្ឋល្អក្នុងសង្គម ។

<u>សម្ដីចុងក្រោយរបស់ជនជាប់ចោទ:</u> ស្នើសុំតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីស្ដាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្ដុតាង និងពិចារណាត្រឹមត្រូវច្បាស់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ មានករណីហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោស ប្រើដាវស៊ាំម៉ូរ៉ៃ) បង្កឡើងដោយជនល្មើសចំនួន០៤នាក់ ១.ឈ្មោ[redacted]ហៅ[redacted] ភេទប្រុស អាយុ ១៧ឆ្នាំ, ២. ឈ្មោះ[redacted]ភេទប្រុស អាយុ២១ឆ្នាំ, ៣.ឈ្មោះ[redacted]ភេទប្រុស អាយុ១៩ឆ្នាំ និង ៤.ឈ្មោ[redacted]ភេទ ប្រុស អាយុ១៧ឆ្នាំ ដោយមុនពេលកើតហេតុ ជនរងគ្រោះឈ្មោះ[redacted]ជាសន្តិសុខយាម នៅមុខបុរីពិភពថ្មី ផ្លូវអ៊ើ ភូមិក្រាំងអង្គ្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឃើញក្រុមជនល្មើស បានជិះម៉ូតូ ចំនួន០២គ្រឿង លឿនដូចហោះនៅក្នុងបុរីពិភពថ្មី ពេលនោះជនរងគ្រោះបានស្រែកឲ្យថា "ម៉េចក៏ ជិះម៉ូតូលឿនម្ល៉េះ" ហើយជនរងគ្រោះ និងក្រុមជនល្មើសក៏មានទំនាស់សំដីគ្នាឡើង រួចក៏បែកគ្នាទៅ ។ ក្រោយមក ជនល្មើសឈ្មោះ[redacted]កាន់ដាវស៊ាំម៉ូរ៉ៃជាប់និងដៃខាងស្ដាំ[redacted]បានបើកម៉ូតូឌុប ជនត្រូវចោទឈ្មោះ[redacted]ជិះមកដល់ចំណុចកើតហេតុខាងលើ ឈ្មោះ[redacted]បានចុះពីលើម៉ូតូ កាន់ដាវស៊ាំម៉ូរ៉ៃ ស្ទុះចូលទៅកាប់ជនរងគ្រោះឈ្មោះ[redacted]ត្រូវចំដៃខាងឆ្វេង បណ្ដាលឲ្យរងរបួស ស្របពេល នោះក៏មានសមត្ថកិច្ចចុះល្បាតក្នុងមូលដ្ឋានមកទាន់ហេតុការណ៍ ក៏ធ្វើការឃាត់ខ្លួនជនត្រូវចោទឈ្មោះ[redacted]បានរួមទាំងវត្ថុតាង ចំណែកឯជនល្មើស ០៣នាក់ទៀត បានរត់គេចខ្លួនបាត់ ។

២.ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ មុនពេលកើតហេតុ ខ្លួននិងមិត្តភ័ក្ត្រឈ្មោះ[redacted] ឈ្មោះ [redacted]និងឈ្មោ[redacted]បានជុំគ្នាអង្គុយលេងនៅ សួនច្បារ នៅក្នុងបុរីពិភពថ្មី ផ្លូវអ៊ើ ភូមិអង្គ្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ ពេលខ្លួននិងមិត្តភ័ក្ត្រកំពុងអង្គុយ ជជែកគ្នាលេង ស្រាប់តែឃើញសន្តិសុខយាមក្នុងបុរីពិភពថ្មីចូលមកសួរនាំខ្លួនថា៖ "ពួកខ្លួនមកអុកឡុកនៅក្នុង បុរីពិភពថ្មី" ហើយសន្តិសុខម្នាក់នោះក៏បានវាយខ្លួនចំចុងចិញ្ចើមក្រោមភ្នែកខាងស្ដាំ ចំនួន០១ដៃ ក្រុមខ្លួនបាន នាំគ្នាជិះម៉ូតូចេញក្រៅបុរីពិភពថ្មី ហើយឈ្មោ[redacted]យកដាវស៊ាំម៉ូរ៉ៃចំនួនមួយដើម មកប្រគល់ឲ្យខ្លួន រីឯឈ្មោះ[redacted]អ្នកបើកម៉ូតូឌុបឈ្មោ[redacted]ជិះមកដល់សួនច្បារក្នុងបុរីពិភពថ្មី កន្លែងកើតហេតុ បានឃើញសន្តិសុខ ដែលវាយខ្លួនកំពុងឈរនៅចិញ្ចើមផ្លូវក្បែរសួនច្បារ ភ្លាមនោះខ្លួនបានចុះពីលើម៉ូតូ កាន់ដាវស៊ាំម៉ូរ៉ៃ ស្ទុះទៅកាប់ សន្តិសុខម្នាក់នោះត្រូវចំដៃ រីឯបក្ខពួករបស់ខ្លួនចំនួន០៣នាក់ទៀត កាន់ដុំថ្មជាប់ដៃគប់ទៅលើសន្តិសុខនោះដែរ

ស្រាប់តែសមត្ថកិច្ចមកដល់ ក៏ធ្វើការឃាត់ខ្លួនរួមទាំងដាវស៊ាំម៉ូរ៉ៃ ។ ចំណែកបក្ខពួកខ្លួនចំនួន ០៣នាក់ទៀតបានរត់គេចខ្លួនបាត់ ។

៤.ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយថា៖ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ ខ្លួនបានចេញទៅយាមនៅតាមគោលដៅនៅក្នុង បុរីពិភពថ្មី ដែលស្ថិតនៅភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ លុះដល់ម៉ោងប្រហែល ១៦៖១០នាទី មានក្រុមក្មេងស្ទាវមួយក្រុមពុំស្គាល់អត្តសញ្ញាណ បានជិះម៉ូតូចំនួន ០២គ្រឿង លឿនដូចឃោះក្នុង បុរីពិភពថ្មី ចំណែកខ្លួនក៏បានស្រែកឲ្យក្រុមក្មេងស្ទាវទាំងនោះថា "ម៉េចក៏ជិះម៉ូតូលឿនម៉េស" ពេលនោះខ្លួនក៏មានទំនាស់សំដីជាមួយក្រុមក្មេងស្ទាវទាំងនោះ ។ លុះដល់ម៉ោងប្រហែល ១៨៖៣០ នាទី នៅពេលខ្លួនកំពុងតែអង្គុយ យាមនៅចំណុចកើតហេតុខាងលើ ស្រាប់តែក្រុមក្មេងស្ទាវចំនួន ០៤នាក់ ដោយនៅក្នុងនោះមានម្នាក់យកដាវ ស៊ាំម៉ូរ៉ៃមកកាប់ខ្លួនបណ្តាលឲ្យមានរបួសស្នាម ភ្លាមនោះសមត្ថកិច្ចដែលកំពុង ល្បាតនៅក្បែរនោះ មកធ្វើការឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ណែកជនត្រូវចោទចំនួន ០៣នាក់ ទៀតបានរត់គេចខ្លួនបាត់តែម្តង ។

៥.តាមរបាយការណ៍សំយោគ ចម្លើយជនរងគ្រោះ ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ពិតជាបាន ប្រព្រឹត្តអំពើ ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសប្រើដាវស៊ាំម៉ូរ៉ៃ) ប្រាកដមែន ។

៦.ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ជាសមត្ថជនមានស្មារតីល្អគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ទូរពល់អំពើដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់ ។

៧.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គមជាពិសេសបូរណភាពរូបរាងកាយជនរងគ្រោះ ហើយអំពើនេះ ត្រូវបានច្បាប់កំណត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោស ។

៨.មានភស្តុតាងជាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ៖ ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសប្រើដាវស៊ាំម៉ូរ៉ៃ) ប្រព្រឹត្តនៅចំណុចមុខមុខបុរីពិភពថ្មី ផ្លូវអើ ភូមិក្រាំងអង្ក្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃ ទី២៨ ខែមករា ឆ្នាំ២០១៧ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៩.ជនជាប់ចោទឈ្មោះ [redacted] ក្រោយពេលប្រព្រឹត្តបទល្មើសបានធ្វើការរត់គេចខ្លួនបាត់ ដែលបង្ហាញពីចេតនាគេចវេសពីការទទួលខុសត្រូវរបស់ខ្លួន ហេតុដូច្នេះតុលាការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទរូបនេះ ដើម្បីមកទទួលខុសត្រូវចំពោះមុខច្បាប់ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១០.វត្ថុចាប់យករួមមាន៖

-ដាវស៊ាំម៉ូរ៉ៃ ចំនួន០១ដើម

តុលាការគប្បី ពិចារណា និងសម្រេចតាមច្បាប់ ។

១១.ជនរងគ្រោះ [redacted] បានចូលអ្នកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងព្យាបាល នោះទេ ហេតុនេះតុលាការគប្បីទុកសិទ្ធិឲ្យប្តឹងទាមទារទៅតុលាការរដ្ឋប្បវេណីនៅពេលក្រោយ ។

**ហេតុដូច្នេះសម្រេច**

១. ផ្តន្ទាទោស៖

ក.ឈ្មោ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២,០០០,០០០៛ (ពីរលានរៀល) ។

ខ.ឈ្មោះ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២,០០០,០០០៛ (ពីរលានរៀល) ។

ពីបទ៖ **ហិង្សាដោយចេតនា (មានស្ថានទម្ងន់ទោសប្រើដាវស៊ាំម៉ូរ៉េ)** ប្រព្រឹត្តនៅចំណុចមុខបុរីពិភពថ្មី ផ្លូវអើ ភូមិក្រាំងអង្ក្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃ ទី២៤ ខែមករា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

២.បង្គាប់ឲ្យចាប់-ឃុំខ្លួនជនជាប់ចោទឈ្មោ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ យកមកទទួលទោសតាមអំណាចសាលក្រមនេះដោយអនុវត្តតាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ។

៣.ទុកសិទ្ធិឲ្យជនរងគ្រោះឈ្មោះ [redacted] ទាមទារសំណងទៅតុលាការរដ្ឋប្បវេណីនៅពេលក្រោយ ។

៤.វត្ថុចាប់យកត្រូវរឹបអូសមាន៖

-ដាវស៊ាំម៉ូរ៉េ ចំនួន០១ដើម

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ជនរងគ្រោះឈ្មោះ [redacted] និងប្រកាសសាធារណៈនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ។

រក្សាសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា: |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
**ចៅក្រមជំនុំជម្រះ**

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី...0 ខែ...តុលា ឆ្នាំ២០១៧
**ក្រឡាបញ្ជី**

[redacted]

[redacted]

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង

**គាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកោះកុង**

សំណុំរឿងព្រហ្មទណ្ឌលេខ១២១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ ដោយមានសមាសភាពដូចតទៅ:

សាលក្រម
លេខ ០៦ "យ"
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ាក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ:១២១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ ដែលរួមមានជនជាប់ចោទ៖

១/ឈ្មោ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ឪពុកឈ្មោ [redacted] ម្តាយឈ្មោះ [redacted]) ជាអនីតិជន ទោសពីមុន គ្មាន។ (ក្នុងឃុំ០៧.០៦.២០១៧)

ជាប់ចោទពីបទ:ឃាតកម្ម ប្រព្រឹត្តនៅចំណុចអន្លង់ក្រញូង ស្ថិតក្នុងភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះ លេខ២៣៣៨ ត.ព ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកោះកុង។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ១៦០ អ.យ/១៧ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

- បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៧២ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តកោះកុង។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង១៧:៣០នាទីល្ងាចជនសង្ស័យឈ្មោះ [redacted] បានអង្គុយលេងនៅលើស្ពានចុងថ្នល់ជាមួយមិត្តភក្តិ ស្រាប់តែឃើញឈ្មោះ [redacted] ភេទប្រុស ជិះម៉ូតូមកពីទិសខាងជើងតែម្នាក់ឯងមកដល់គល់ស្ពានខាងត្បូង ម៉ូតូក៏

របស់ខ្លួនមិត្តភក្តិម្នាក់ទៀត បានហៅឱ្យឈប់ បន្ទាប់មកបបួលគ្នាជិះម៉ូតូទៅលេងសាលាម្ខាង និងស្រែអំបិល ហើយក៏ត្រឡប់ទៅស្ពានស្រែអំបិលវិញ នៅវេលាម៉ោង២១ និង៣០នាទីយប់ ពេលនោះមិត្តភក្តិរបស់ខ្លួនក៏បានចូលផ្ទះរៀងៗខ្លួន។ ចំណែកឈ្មោះ [redacted] ជិះម៉ូតូម្នាក់ឯងសំដៅមកទិសខាងជើង ឃើញដូច្នេះរូបខ្លួនក៏ជិះម៉ូតូម្នាក់ឯង តាមពីក្រោយពេលមកដល់ចំណុចកើតហេតុឈ្មោះ [redacted] បានឈប់ម៉ូតូនៅកៀនថ្នល់ហើយបានស្រែកហៅខ្លួនឱ្យឈប់និយាយគ្នាសិន ពេលខ្លួនដើរទៅដល់ស្រាប់តែឈ្មោះ [redacted] បានយកដំបងឈើជ្រុងវាយមកលើខ្លួនប៉ុន្តែពុំត្រូវ ខ្លួនក៏រើសបានដំបងតាសេកនៅជិតនោះវាយវិញត្រូវបណ្តាលឱ្យឈ្មោះ [redacted] ដួល ឃើញដូច្នេះខ្លួនក៏យកដំបងឈើជ្រុងរបស់ឈ្មោះ [redacted] វាយបន្ថែមទៀតជាច្រើនដំបង ហើយក៏ត្រឡប់ទៅផ្ទះវិញដោយពុំបានដឹងថាឈ្មោះ ល[redacted] ស្លាប់នោះទេ។

-តុលាការប្រកាសបើកសវនាការ

-តុលាការប្រកាសអំពីសមាសភាពជំនុំជម្រះ

-តុលាការសួរអំពីអត្តសញ្ញាណជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់ជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់សាក្សី

-ជនជាប់ចោទមិនជំទាស់ និងសមាសភាពជំនុំជម្រះទេ

**នាពេលសវនាការ**

-តាមចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted] បានឆ្លើយសារភាពថា ៖ ពីមុនមកខ្លួន និងជនរងគ្រោះធ្លាប់មានទំនាស់នឹងគ្នាហើយមិនដែលនិយាយជាមួយគ្នានោះទេ។ រហូតមក ដល់ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៧ វេលាម៉ោង ១៧និង៣០ នាទី ខ្លួនកំពុងអង្គុយលេង នៅលើស្ពានចុងថ្នល់ជាមួយមិត្តភក្តិមួយចំនួនទៀត ស្រាប់តែឈ្មោះ [redacted] ជាជនរងគ្រោះជិះម៉ូតូមកម្នាក់ឯង មិត្តភក្តិខ្លួនម្នាក់ទៀតបានហៅឱ្យឈប់ បន្ទាប់មកបបួលគ្នាជិះម៉ូតូទៅ សាលាម្ខាងនិងស្រែអំបិល ហើយក៏ត្រឡប់ទៅស្ពានស្រែអំបិលវិញ នៅវេលាម៉ោង ២១និង ៣០នាទី ។ ពេលនោះមិត្តភក្តិខ្លួនបានចូលផ្ទះរៀងៗខ្លួនចំណែកឈ្មោះ [redacted] បានជិះម៉ូតូម្នាក់ឯងសំដៅមកទិសខាងជើង ឃើញដូច្នេះរូបខ្លួន ក៏ជិះម៉ូតូម្នាក់ឯងតាមពីក្រោយ ពេលមកដល់ចំណុចកើតហេតុ ឈ្មោះ [redacted] បានឈប់ម៉ូតូនៅកៀនថ្នល់ ហើយបានស្រែកហៅខ្លួនឱ្យឈប់និយាយគ្នាសិន ពេលខ្លួនដើរទៅដល់ស្រាប់តែ ឈ្មោះ [redacted] បានយកដំបងឈើជ្រុងវាយមកលើ ខ្លួនប៉ុន្តែពុំត្រូវខ្លួនក៏រើសបានដំបងតាសេកនៅជិតនោះវាយវិញត្រូវបណ្តាលឱ្យឈ្មោះ [redacted] ឃើញដូច្នេះខ្លួនក៏យកដំបងឈើជ្រុងរបស់ឈ្មោះ [redacted] វាយបន្ថែមទៀតជាច្រើន ដំបងហើយក៏ត្រឡប់ទៅផ្ទះវិញ ដោយពុំបានដឹងថាឈ្មោះ [redacted] ស្លាប់នោះទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមាននាពេលសវនាការ ។ ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចឱ្យក្រឡាបញ្ជីអានអំណានកំណត់ហេតុស្តាប់ចម្លើយនៅតំណាក់កាលស៊ើបសួរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារ និងសំណូមពរដល់តុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងទាមទារសំណងជំងឺចិត្តចំនួន៨.០០០.០០០(ប្រាំបីលាន)រៀល ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖

+ ដោយមានភាពស៊ីសង្វាក់រវាងសកម្មភាពប្រព្រឹត្ត និងភស្តុតាងគ្រប់គ្រាន់ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់។ ជាមួយគ្នានេះដែរ ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តនូវសកម្មភាពដូចមានក្នុងអង្គហេតុខាងលើពិតប្រាកដមែន អាស្រ័យហេតុនេះតំណាងអយ្យការសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងជួយបន្ធូរបន្ថយទោសដល់ជននេះផង ព្រោះជននេះជាអនីតិជន ដែលមិនមានប្រវត្តិប្រព្រឹត្តបទល្មើស មិនបានរៀនសូត្រចេះដឹង ។

+សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១៦០ អ.យ/១៧ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ ទុកជាបានការទាំងស្រុង និងសូមឲ្យចៅក្រមជំនុំជម្រះពិនិត្យសម្រេចតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់៖

+លោកមេធាវី [redacted]នធ្វើសេចក្តីសន្និដ្ឋានថា តាមរយៈការសួរដេញដោលជនជាប់ចោទបានឆ្លើយថា ជនរងគ្រោះបានវាយមកលើខ្លួនមុនហើយបានប្រតាយប្រតប់គ្នា រហូតបណ្តាលឲ្យជនគ្រោះស្លាប់ ។ ជនជាប់ចោទបានអះអាងទៀតថា ពេលប្រតាយប្រតប់គ្នា ខ្លួនមិនបានដឹងថាជនរងគ្រោះស្លាប់នោះទេ រហូតមានសមត្ថកិច្ចឃាត់ខ្លួនទើបដឹង ។ ខ្លួនគ្មានគំនុំជាមួយជនរងគ្រោះពីមុននោះទេ ។ អាស្រ័យហេតុនេះ ក្នុងនាមមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចប្តូរបទចោទ ពីបទឃាតកម្ម មិនបទហិង្សាមានស្ថានទម្ងន់ទោសបណ្តាលឲ្យជនរងគ្រោះស្លាប់ និងសុំបន្ធូរបន្ថយទោសដល់ជនជាប់ចោទដែលជាអនីតិជន ។

-សំដីចុងក្រោយរបស់ជនជាប់ចោទនៅចំពោះមុខសវនាការបានស្នើសុំដល់ចៅក្រមជំនុំជម្រះមេត្តាជួយបន្ធូរបន្ថយទោសព្រោះ ពួកគេបានយល់ពីទោសកំហុសរបស់ខ្លួន និងសុំប្តេជ្ញាចំពោះមុខអង្គសវនាការថាពួកគេនឹងខិតខំកែប្រែខ្លួនឲ្យល្អ និងឈប់ប្រព្រឹត្តល្មើស នឹងច្បាប់រដ្ឋតទៅទៀតហើយ ។

1) ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
2) ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
3) ក្រោយពីបានពិនិត្យភស្តុតាង
4) ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សាលាដំបូងខេត្តកោះកុង</u>**

**<u>យល់ឃើញថា</u>**

១.តាមចម្លើយរបស់ជនសង្ស័យឈ្មោ[redacted]ឆ្លើយសារភាពថា ៖ ពីមុនមកខ្លួន និងជនរងគ្រោះធ្លាប់មានទំនាស់នឹងគ្នាហើយមិនដែលនិយាយជាមួយគ្នានោះទេ។ រហូតមកដល់ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៧ វេលាម៉ោង ១៧និង៣០ នាទី ខ្លួនកំពង់អង្គុយលេងនៅលើស្ពានចុងថ្នល់ជាមួយមិត្តភក្តិមួយចំនួនទៀត ស្រាប់តែឈ្មោ[redacted]ជនរងគ្រោះជិះម៉ូតូមកម្នាក់ឯង មិត្តភក្តិខ្លួនម្នាក់ទៀតបានហៅឱ្យឈប់ បន្ទាប់មកបបួលគ្នាជិះម៉ូតូទៅ សាលាម្នាងនិងស្រែអំបិល ហើយក៏ត្រឡប់ទៅស្ពានស្រែអំបិលវិញ នៅវេលាម៉ោង ២១និង៣០នាទី ។ ពេលនោះមិត្តភក្តិខ្លួនបានចូលផ្ទះរៀងៗខ្លួនចំណែកឈ្មោ[redacted]នជិះម៉ូតូម្នាក់ឯងសំដៅមកទិសខាងជើង ឃើញដូច្នេះរូបខ្លួន ក៏ជិះម៉ូតូម្នាក់ឯងតាមពីក្រោយ ពេលមកដល់ចំណុចកើតហេតុ ឈ្មោ[redacted]នឈប់ម៉ូតូនៅកៀនថ្នល់ ហើយបានស្រែកហៅខ្លួន

ឱ្យឈប់និយាយគ្នាសិន ពេលខ្លួនដើរទៅដល់ស្រាប់តែ ឈ្មោះ[redacted]យកដំបងឈើជ្រុងវាយមកលើ ខ្លួនប៉ុន្តែពុំត្រូវខ្លួនក៏រើសបានដំបងតាសេកនៅពេលនោះវាយវិញត្រូវបណ្តាលឱ្យឈ្មោះ[redacted]ឃើញដូច្នេះខ្លួនក៏យកដំបងឈើជ្រុងរបស់ឈ្មោះ[redacted]របន្ថែមទៀតជាច្រើន[redacted]ដំបងហើយក៏ត្រឡប់ទៅផ្ទះវិញ ដោយពុំបានដឹងថាឈ្មោះ[redacted]ស្លាប់នោះទេ។ នៅត្រង់ចំណុចនេះក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ពិតជាមានហេតុការណ៍វាយតប់គ្នារវាងជនជាប់ចោទឈ្មោះ[redacted]ក៏យសកម្មភាពនេះបានបណ្តាលឲ្យឈ្មោះ[redacted]ស្លាប់ ។ ជាមួយគ្នានេះដែរតាមចម្លើយសារភាពរបស់ជនជាប់ចោទក្នុងពេលសវនាការបានបញ្ជាក់ជូនតុលាការថា ខ្លួនគ្មានចេតនាធ្វើឲ្យជនរងគ្រោះស្លាប់នោះទេ គឺនៅយប់កើតហេតុនៅពេលប្រតាយប្រតប់គ្នាខ្លួនបានទាញដំបងវាយទៅលើជនរងគ្រោះពិតមែន តែវាយក្នុងគោលបំណងកុំជនរងគ្រោះបន្តវាយមកលើខ្លួនទៀត បន្ទាប់មកខ្លួនបានឃើញជនរងគ្រោះដួល ខ្លួនក៏បានដើរចេញដោយមិនគិតថាជនរងគ្រោះស្លាប់នោះទេ ។ផ្អែកតាមចម្លើយសារភាពនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណាលើធាតុផ្សំនៃអំពើឃាតកម្ម និងអំពើហិង្សាមានស្ថានទម្ងន់ដែលបណ្តាលឲ្យជនរងគ្រោះស្លាប់ ។

២ -ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទចាប់តាំងពីតំណាក់កាលនគរបាលយុត្តិធម៌ តំណាក់កាលអយ្យការ ចៅក្រមស៊ើបសួរ និងក្នុងពេលសវនាការ ជនជាប់ចោទនៅតែរក្សាចម្លើយរបស់ខ្លួនដដែលថា ខ្លួនគ្មានចេតនាវាយជនរងគ្រោះស្លាប់នោះទេ ហេតុការណ៍បានផ្តើមចេញពីការដែលជនរងគ្រោះបានវាយខ្លួនមុន ហើយខ្លួនក៏វាយទៅវិញ ប៉ុន្តែមិនដែលគិតថា ធ្វើឲ្យជនរងគ្រោះស្លាប់ឡើយ ។ គប្បីក្រុមប្រឹក្សាពិចារណាផ្អែកលើធាតុផ្សំនៃបទល្មើស ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមាននាពេលសវនាការ ។ ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចឲ្យក្រឡាបញ្ជីអានអំណានកំណត់ហេតុស្តាប់ចម្លើយនៅតំណាក់កាលស៊ើបសួរ ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាដោយមានភាពស៊ីសង្វាក់រវាងសកម្មភាពប្រព្រឹត្ត និងភស្តុតាងគ្រាប់គ្រាន់ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់។ ជាមួយគ្នានេះដែរ ជនជាប់ចោទបានហ៊ានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តនូវសកម្មភាពដូចមានក្នុងអង្គហេតុខាងលើពិតប្រាកដមែន អាស្រ័យហេតុនេះតំណាងអយ្យការសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងជួយបន្ធូរបន្ថយទោសដល់ជននេះផង ព្រោះជននេះជាអនីតិជន ដែលមិនមានប្រវត្តិប្រព្រឹត្តបទល្មើស មិនបានរៀនសូត្រចេះដឹង ។ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា លើអង្គហេតុ និងអង្គច្បាប់ ។

៥ -លោកមេធាវី[redacted]នធ្វើសេចក្តីសន្និដ្ឋានថា តាមរយៈការសួរដេញដោលជនជាប់ចោទបានឆ្លើយថា ជនរងគ្រោះបានវាយមកលើខ្លួនមុនហើយបានប្រតាយប្រតប់គ្នា រហូតបណ្តាលឲ្យជនគ្រោះស្លាប់ ។ ជនជាប់ចោទបានអះអាងទៀតថា ពេលប្រតាយប្រតប់គ្នា ខ្លួនមិនបានដឹងថាជនរងគ្រោះស្លាប់នោះទេ រហូតមានសមត្ថកិច្ចឃាត់ខ្លួនទើបដឹង ។ ខ្លួនគ្មានគំនុំជាមួយជនរងគ្រោះពីមុននោះទេ ។ អាស្រ័យហេតុនេះ ក្នុងនាមមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចប្តូរបទចោទ ពីបទឃាតកម្ម មកបទហិង្សាមានស្ថានទម្ងន់ទោសបណ្តាលឲ្យជនរងគ្រោះស្លាប់ និងសុំបន្ធូរបន្ថយទោសដល់ជនជាប់ចោទដែលជាអនីតិជន ។ ក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថាការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទក្នុងការសុំប្តូរបទចោទពីបទឃាតកម្ម មកបទហិង្សាមានស្ថានទម្ងន់បណ្តាលឲ្យជនរងគ្រោះស្លាប់ មានភាពសមហេតុសមផល ដោយផ្អែកតាមអង្គហេតុ

ដែលកើតមានឡើង និងភស្តុតាងនានាដែលមានក្នុងសំណុំរឿង ។ អាស្រ័យហេតុនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាប្តូរបទចោទពីបទឃាតកម្ម តាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ មកបទ ហិង្សាមានស្ថានទម្ងន់ដោយសារមរណភាពរបស់ជនរងគ្រោះ តាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

៦-ផ្អែកតាមមាត្រា២០០ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ គប្បីក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណាដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿង ។

៧ - ជនជាប់ចោទឈ្មោ[redacted]ាអនិតិជន ដែលពុំធ្លាប់មានប្រវត្តិផ្តន្ទាទោសពីតុលាការឡើយ ។

៨-ផ្អែកតាមមាត្រា១០៦ និង មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណា ។

៩-វត្ថុតាងរួមមានដំបងឈើជ្រុងប្រវែង០.៧ម៉ែត្រ (សូន្យក្បៀសប្រាំពីរ) ចំនួន០១ដើម គប្បីរឹបអូសបំផ្លាញចោល ។

១០- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ។

១១ - ទោះបីដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមានក្នុងពេលសវនាការក៏ដោយ ក៏ប៉ុន្តែការខូចខាតដែលបានកើតឡើងដោយសារសកម្មភាពល្មើសរបស់ជនជាប់ចោទ គប្បី ក្រុមប្រឹក្សាជំនុំជម្រះ សម្រេចពិចារណា លើសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។

១២. យោងតាមមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១/. កែប្រែបទចោទពីបទឃាតកម្ម តាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ មកបទហិង្សាមានស្ថានទម្ងន់ដោយសារមរណភាពរបស់ជនរងគ្រោះ តាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

២/. ផ្តន្ទាទោស ជនជាប់ចោទ ឈ្មោះ គាន់ ធៀន ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៧(ប្រាំពីរ)ឆ្នាំ តែអនុវត្តទោសចំនួន០៥(ប្រាំ)ឆ្នាំ ។

ជាប់ចោទពីបទ: ហិង្សាមានស្ថានទម្ងន់ដោយសារមរណភាពរបស់ជនរងគ្រោះ ប្រព្រឹត្តនៅចំណុចអន្លង់ក្រញូង ស្ថិតក្នុងភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង. កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

៣/- បង្គាប់ឲ្យឈ្មោះ [redacted]ភេទប្រុស អាយុ១៧ឆ្នាំ សងសំណងជំងឺចិត្ត និងការខូចខាតផ្សេងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន៨.០០០.០០០(ប្រាំបីលាន)រៀល ។

៤/-វត្ថុតាងរួមមានដំបងឈើជ្រុងប្រវែង០.៧ម៉ែត្រ (សូន្យក្បៀសប្រាំពីរ) ចំនួន០១ដើម រឹបអូសបំផ្លាញចោល។

៥/ សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ និងប្រកាស ជាសាធារណៈ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជី** [redacted] **ចៅក្រមប្រឹក្សា** [redacted] **ចៅក្រមប្រឹក្សា** [redacted] **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

កោះកុង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

កោះកុង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

# ឧបសម្ព័ន្ធទី៧

76/9

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៤៦
ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣
សាលដីកា
លេខ: ២៨
ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥

# តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោកស្រី [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ០៦ "ក្រVបស" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ២៤៦ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់តុលាការកំពូល។

<u>ពីបទ:</u> រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិចង្ហោន ឃុំព្រៃកញ្ចោត ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា ៤០ ចំណុចទី៥ នៃក្រមព្រហ្មទណ្ឌ។

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មុខរបរសិស្សរៀនថ្នាក់ទី១០ កើតនៅភូមិព្រៃកអំពិល ឃុំកោះតូច ស្រុកកំពត ទីលំនៅបច្ចុប្បន្ន ភូមិព្រៃកអំពិល ឃុំកោះតូច ស្រុកកំពត ខេត្តកំពត ឪពុកឈ្មោ [redacted] ម្តាយឈ្មោ [redacted] នៅលីវ ទោសពីមុនគ្មាន។

ត្រូវបានចាប់ឃាត់ខ្លួន ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន នៅពន្ធនាគារខេត្តកំពត តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣២៤ ព្រ.ទ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១។

76/8

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ថ្ងៃខែ ឆ្នាំកំណើត ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៣ ជាតិខ្មែរ មុខរបរសិស្សរៀនថ្នាក់ទី១០ កើតនៅភូមិព្រែកអំពិល ឃុំកោះតូច ស្រុកកំពត ខេត្តកំពត ទីកន្លែងបច្ចុប្បន្ន ភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន។

ត្រូវបានចាប់ឃាត់ខ្លួន ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន នៅពន្ធនាគារខេត្តកំពត តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣២០ ព្រ.ទ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១។

៣-ជនជាប់ចោទឈ្មោះ [redacted] (ហៅស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ទីលំនៅបច្ចុប្បន្នភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត មុខរបរធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៧ ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន។

-មានមេធាវីការពារ លោកស្រី [redacted] ការពារក្តីឱ្យឈ្មោះ [redacted]

ត្រូវបានចាប់ឃាត់ខ្លួន ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពត តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣២២ ព្រ.ទ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១។

៤-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៨៨ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិព្រែកអំពិល ស្រុកទឹកឈូ ខេត្តកំពត កម្រិតវប្បធម៌ថ្នាក់ទី៧ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

៥-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ កើតឆ្នាំ១៩៩០ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត មុខរបរធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៣ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

៦-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៧ឆ្នាំ កើតឆ្នាំ១៩៨៤ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត។ មុខរបរ ធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៣ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន។ (គេចខ្លួន)

៧-ជនជាប់ចោទឈ្មោះ [redacted] អាយុ ២៩ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩២ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត មុខរបរធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៣ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

៨-ជនជាប់ចោទឈ្មោះ [redacted] អាយុ ២០ឆ្នាំ កើតឆ្នាំ១៩៩១ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិចង្ហោន ឃុំព្រែកត្នោត

ស្រុកទឹកឈូ ខេត្តកំពត មុខរបរធ្វើស្រែក កម្រិតវប្បធម៌ថ្នាក់ទី៤ ឪពុកឈ្មោ[redacted]ៈ ម្តាយឈ្មោ[redacted] នៅលើរ ទោសពីមុនគ្មាន។ (គេចខ្លួន)

៩-ជនជាប់ចោទឈ្មោះ [redacted]ភេទប្រុស អាយុ ២៦ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៨៥ ជាតិខ្មែរ មុខរបរ នេសាទ កើតនៅភូមិព្រែកត្នោត ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោ[redacted]លើរ ទោសពីមុនគ្មាន។ (គេចខ្លួន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ភេទស្រី អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃពាយ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃពាយ ឃុំត្រពាំង ស្រុកឈូក ខេត្តកំពត។

-នៅមុនចូលឆ្នាំខ្មែរពីរថ្ងៃ ក្នុងខែមេសា ឆ្នាំ២០១១ ពេ[redacted]បានចេញពីផ្ទះរបស់ខ្លួនស្ថិតនៅភូមិព្រៃពាយ ឃុំត្រពាំងពាយភ្លាំង ស្រុកឈូក ខេត្តកំពត មកស្នាក់នៅផ្ទះមីងរបស់ខ្លួនឈ្មោ[redacted]នៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ក្រោយពេលបាននៅកន្លះខែឈ្មោះ [redacted] ក៏មានទំនាក់ទំនងស្រឡាញ់គ្នាជាមួយប្រុស ឈ្មោះ [redacted] លុះដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ប្រមាណ១០ ឈ្មោះ [redacted] បានទៅដើរលេងនៅម្តុំផ្ទះចាស់របស់បារាំងនៅខាងលិចស្ពានក្បាត ស្ថិតក្នុងភូមិ ចង្ហោន ក៏បានជួបឈ្មោះ [redacted] រួចឈ្មោះ [redacted] ក៏ឧប [redacted]ដើរលេងហើយក៏ចូលទៅក្នុងផ្ទះមិត្តភក្តិរបស[redacted]ឈ្មោះ [redacted]ដែលផ្ទះនេះទុកចោលពុំមានមនុស្សរស់នៅស្ថិតនៅខាងលិចសាលាបឋមសិក្សាក្បាត។ ឈ្មោះ [redacted] ក៏បានរួមភេទជាមួយគ្នានៅក្នុងផ្ទះនោះ។ ក្រោយមកឈ្មោ[redacted]ក៏បានដឹកនាង[redacted] ទៅដាក់ត្រង់ផ្ទះចាស់របស់បារាំងខាងលើ ដែលគេបោះបង់ចោលភ្លាមនោះក៏មានឈ្មោះ[redacted] បានមកកៀកកនាង [redacted]ហើយមានឈ្មោ[redacted]ឈ្មោ[redacted]បានរួមគ្នាធ្វើសកម្មភាពរំលោភសេពសន្ថវៈលើនាង[redacted]រហូតបានសម្រេចម្នាក់ម្តងៗ។ ក្រោយពេលអ្នកទាំងនោះបាន ធ្វើសកម្មភាពរំលោភសេពសន្ថវៈរួចហើយឈ្មោះ [redacted]កដល់ហើយនិយាយដោះសារ ប្រាប់នាង[redacted] ថាមិនស្គាល់អ្នកដែលបានចាប់រំលោភនាងទេ។ មកដល់ថ្ងៃទី១៣ ខែឆ្នាំដដែល វេលាម៉ោង ប្រមាណ៩ និង៣០នាទីយប់ នា[redacted]បានមកជួបឈ្មោ[redacted]និយាយលួងលោម បបួលទៅដើរលេងនៅម្តុំសាលាបឋមសិក្សាក្បាតហើយក៏បានរួមភេទ ជាមួយគ្នាទៀតក្រោយមកឈ្មោះ[redacted]បានប្រើល្បិចថាទៅបត់ជើងតូចបន្ទាប់មកមានឈ្មោ[redacted] បានចូលរួមធ្វើសកម្មភាព រំលោភសេបសន្ថវៈ លើនាង[redacted]បានសម្រេចម្នាក់ម្តងៗទៀត។ លុះស្អែកឡើងថ្ងៃទី១៤ នាង[redacted]បានចេញពីផ្ទះមានបំណងទៅសម្លាប់ខ្លួនក៏ត្រូវបានមីងឈ្មោះ [redacted]បរកឃើញ ហើយបានសួរនាំដែលដឹងរឿងហេតុដែលកើតឡើងរួចក៏ប្តឹងសមត្ថកិច្ចនគរបាលតែម្តង។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពតថា: ប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេច៖

-បញ្ជូនជនត្រូវចោទឈ្មោះ [redacted] ទៅជំនុំជម្រះតាមច្បាប់។

-លើកលែងចោទប្រកាន់លើឈ្មោះ [redacted] និងឈ្មោះ [redacted] មច្បាប់។

-បានឃើញដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលបានសម្រេច៖

-លើកលែងចោទប្រកាន់លើឈ្មោ [redacted] ងឈ្មោ [redacted] រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦២ "ខ" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ដែលបានសម្រេច៖

១.ផ្តន្ទាទោស៖

ក.ឈ្មោ [redacted] ទប្រុស អាយុ ១៧ឆ្នាំ ថ្ងៃខែឆ្នាំ កំណើត ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ជាតិខ្មែរ មុខរបរសិស្សរៀនថ្នាក់ទី១០ កើតនៅភូមិព្រែកអំពិល ឃុំកោះតូច ស្រុកកំពត ខេត្តកំពត។ ទីលំនៅបច្ចុប្បន្ន ភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត។ ឪពុកឈ្មោ [redacted] ាប់ ម្តាយឈ្មោះ [redacted] នៅលើវ ទោសពីមុនគ្មាន។

ខ.ឈ្មោះ [redacted] ទប្រុស អាយុ ១៧ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៣ ជាតិខ្មែរ មុខរបរសិស្សរៀនថ្នាក់ទី១០ កើតនៅភូមិព្រែកអំពិល ឃុំកោះតូច ស្រុកកំពត ខេត្តកំពត។ ទីលំនៅបច្ចុប្បន្ន ភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ។ឪពុកឈ្មោ [redacted] ម្តាយឈ្មោះ [redacted] នៅលើវ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ៣(បី)ឆ្នាំ ៦ (ប្រាំមួយ)ខែ។

គ.ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្ន ភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ។ មុខរបរធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៧ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលើវ ទោសពីមុនគ្មាន។

ឃ.ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៨៨ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត។ ទីលំនៅបច្ចុប្បន្ន ភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត ។ កម្រិតវប្បធម៌ថ្នាក់ទី៧ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោ [redacted] នៅលើវ ទោសពីមុនគ្មាន។ (គេចខ្លួន)

ង.ឈ្មោះ [redacted] ទប្រុស អាយុ ២១ឆ្នាំ កើតឆ្នាំ១៩៩០ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្នភូមិចង្ហោន ឃុំព្រែកត្នោត

ស្រុកទឹកឈូ ខេត្តកំពត។ មុខរបរធ្វើស្រែ កម្រិតវប្បធម៌ ថ្នាក់ទី៣ ឪពុកឈ្មោះ[redacted] ម្ដាយឈ្មោះ[redacted]នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

ច.ឈ្មោះ: [redacted]អាយុ ២៧ឆ្នាំ កើតឆ្នាំ១៩៨៤ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត។ ទីលំនៅបច្ចុប្បន្ន ភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត ។ មុខរបរធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៣ ឪពុកឈ្មោះ[redacted] ម្ដាយឈ្មោះ[redacted]នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

ឆ.ឈ្មោះ[redacted]អាយុ ១៩ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩២ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ។ទីលំនៅបច្ចុប្បន្ន ភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត ។ មុខរបរធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៣ ឪពុកឈ្មោះ: [redacted] ម្ដាយឈ្មោះ: [redacted]នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

ជ.ឈ្មោះ[redacted]អាយុ ២០ឆ្នាំ កើតនៅឆ្នាំ១៩៩១ ជាតិខ្មែរ កើតនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកកំពត ។ ទីលំនៅបច្ចុប្បន្ន ភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត ។ មុខរបរធ្វើស្រែ កម្រិតវប្បធម៌ថ្នាក់ទី៤ ឪពុកឈ្មោះ: [redacted]ម្ដាយឈ្មោះ: [redacted]នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

ឈ.ឈ្មោះ: [redacted]ភេទប្រុស អាយុ ២៦ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៨៥ ជាតិខ្មែរ មុខរបរនេសាទ កើតនៅភូមិព្រែកត្នោត ឃុំព្រែកត្នោត ស្រុកកំពត ខេត្តកំពត។ ទីលំនៅបច្ចុប្បន្ន ភូមិព្រែកអំពិល ឃុំកោះតូច ស្រុកទឹកឈូ ខេត្តកំពត។ ឪពុកឈ្មោះ: [redacted] ម្ដាយឈ្មោះ: [redacted]នៅរស់ ទោសពីមុនគ្មាន។ (គេចខ្លួន)

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ៩ (ប្រាំបួន)ឆ្នាំ។

ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើស ប្រព្រឹត្តនៅភូមិចង្ហោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត។ កាលពីថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា២៤០ចំណុច៥ នៃក្រមព្រហ្មទណ្ឌ។

២-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនពិរុទ្ធជនឈ្មោះ[redacted] ឈ្មោះ: [redacted]និងឈ្មោះ: [redacted]យកមកឃុំខ្លួនក្នុងពន្ធនាគារតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឈ្មោះ: [redacted]មេធាវីការពារសិទ្ធិជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ: [redacted] និងឈ្មោះ[redacted] មានសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ: [redacted] និងបណ្ដឹងឧទ្ធរណ៍លេខ ១០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ:

76/84

[redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៦២ "ខ" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: តម្កល់សាលក្រមនេះ ទុកជាបានការ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ០៦ "ក្រVបស" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ [redacted]កជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខៈ១០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ [redacted]កជាត្រឹមត្រូវតាមច្បាប់។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦២ "ខ" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ទុកជាបានការដដែល លើកលែងតែចំណុចទី១ "ក" ការផ្តន្ទាទោសលើឈ្មោះ [redacted]ត្រូវតែកែប្រែពីអនុវត្តទោសពន្ធនាគារ ៣ (បី) ឆ្នាំ ៦ (ប្រាំមួយ) ខែ មកអនុវត្តទោសពន្ធនាគារ២ឆ្នាំ ទោសនៅសល់ត្រូវព្យួរ (ទោសព្យួរធម្មតា)វិញ។ ចំណុចផ្សេងពីនេះរក្សាទុកដដែល។

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ និងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ដោយសម្រេចសេចក្តី:

-ចំពោះមុខជនជាប់ចោទឈ្មោ[redacted]

-បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប

-បានឃើញបណ្តឹងសាទុក្ខលេខ ៨១ (ស្ទួន) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ឈ្មោះ [redacted]ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ០៦ "ក្រVបស" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពាររបស់ឈ្មោះ [redacted]ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទខាងលើពីបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចង្អោន ឃុំព្រែកត្នោត ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី១២-១៣ ខែឧសភា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា ២៤០ ចំណុចទី៥ នៃក្រមព្រហ្មទណ្ឌ។

76/3

២-ចម្លើយដោះបន្ទុករបស់ជនរងគ្រោះ និងចម្លើយដោះសាររបស់ជនជាប់ចោទម្នាក់ៗ ដែលបានឆ្លើយនៅដំណាក់កាលតុលាការថ្នាក់ក្រោម ពុំមានភស្តុតាងផ្ទុយបញ្ជាក់គួរឱ្យជឿជាក់បានឡើយ។ ចម្លើយទាំងនោះ គឺអាចកើតមានដោយសារការត្រូវរ៉ូវគ្នារវាងគូភាគីជនជាប់ចោទ និងភាគីជនរងគ្រោះ។

៣-ការសម្រេចតម្កល់របស់សាលាឧទ្ធរណ៍ លើសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តកំពត មានមូលដ្ឋានត្រឹមតាមច្បាប់ហើយ។

៤-សូមក្រុមប្រឹក្សាជំនុំជម្រះ តម្កល់សាលដីការបស់សាលាឧទ្ធរណ៍លេខ ០៦ "ក្រVបស" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រីមេធាវី [redacted]ារពារឱ្យជនជាប់ចោទឈ្មោះ [redacted]ាពេលសវនាការថា កូនក្តីនាងខ្ញុំត្រូវបានតុលាការចោទប្រកាន់ពីបទ រំលោភសេពសន្ថវៈ ទៅលើឈ្មោះ [redacted]ពោះរឿងនេះ កូនក្តីនាងខ្ញុំមិនបានប្រព្រឹត្តដូចដែលតុលាការចោទប្រកាន់នោះទេ ហើយ [redacted]ក៏មិនបានប្តឹងកូនក្តីខ្ញុំដែរ ដូច្នេះ ការចោទប្រកាន់នេះ គឺជាការមិនពិតដូចការចោទប្រកាន់ពីតុលាការ។ ចំពោះអ្នកប្រព្រឹត្តជាក់ស្តែងបែរជារួចខ្លួនគ្មានទោសអ្វីទាំងអស់ ចំណែកកូនក្តីនាងខ្ញុំមិនបានប្រព្រឹត្តសោះ ជាប់ទោស ៩ ឆ្នាំ។

<u>សំណូមពរ:</u> សូមឱ្យកូនក្តីនាងខ្ញុំរួចផុតពីបទចោទ។

-តំណាងមហាអយ្យការអមតុលាការកំពូលគ្មានយោបល់អ្វីបន្ថែមទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់មូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨១សួន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted]ឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦២ -ខ- ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត ដែលបានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោ[redacted]ដាក់ពន្ធនាគារកំណត់ ០៩ ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ លើជនរងគ្រោះឈ្មោះ [redacted]ាលពីថ្ងៃទី១២ និងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១១ ដោយសំអាងទៅលើចម្លើយរបស់ជនជាប់ចោទឈ្មោ[redacted] [redacted]

[redacted]ងចម្លើយរបស់ជនរងគ្រោះឈ[redacted]ដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ ក៏ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទឈ្មោ[redacted]ដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជាក់ថា ជនជាប់ចោទបានរួមភេទជាមួយជនរងគ្រោះឈ្មោះ[redacted]នៅក្នុងចម្លើយទាំងនោះពុំបានបង្ហាញពីការចាប់បង្ខិតបង្ខំទៅលើជនរងគ្រោះឡើយ ផ្ទុយទៅវិញ តាមសារណាការពារ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ជនជាប់ចោទឈ្មោ[redacted]ឆ្លើយថា នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៣ ខ្លួនគ្រាន់តែបានទៅចាប់ឈ្មោ[redacted]ចុះពីផ្ទះចាស់របស់បាវ៉ាំងប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត មានតែជនរងគ្រោះម្នាក់ប៉ុណ្ណោះដែលបានបញ្ជាក់ថា ជនជាប់ចោទ បានចាប់បង្ខំរូបខ្លួនដើម្បីរួមភេទ ហើយក្រោយមកទៀត ជនរងគ្រោះបានកែប្រែចម្លើយរបស់ខ្លួនទៅវិញ។ លើសពីនេះទៅទៀត ជនរងគ្រោះបានអះអាងថា ខ្លួនត្រូវជនជាប់ចោទជាច្រើននាក់ចាប់បង្ខំរួមភេទជាមួយនាង នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ ម្តង និងនៅថ្ងៃបន្ទាប់ជាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១១ ម្តងទៀត ដែលត្រង់ចំណុចនេះ ធ្វើឱ្យកើតមានភាពសង្ស័យទៅលើភាពសមហេតុផលនៃការអះអាងរបស់ជនរងគ្រោះ។

-យល់ឃើញថា យោងតាមខ្លឹមសារនៃមាត្រា ២៣៩ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ បទ រំលោភសេពសន្ថវៈ បង្កើតឡើងដោយសារតែអំពើបញ្ចូលអង្គជាតពីសំណាក់ចារី និងគ្មានការព្រមព្រៀងពីសំណាក់ជនរងគ្រោះ ក៏ប៉ុន្តែជាក់ស្តែងនៅក្នុងសំណុំរឿងនេះ សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកំពត ដោយមិនបានធ្វើការពិចារណារំលេចឱ្យឃើញច្បាស់លាស់នៅក្នុងសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួន អំពីធាតុផ្សំទីពីរនៃបទរំលោភសេពសន្ថវៈ ពោលគឺភាពគ្មានការព្រមព្រៀងពីសំណាក់ជនរងគ្រោះឡើយ។ ចំណុចនេះ គឺជាការបំពានច្បាប់ ដែលជាមូលហេតុនៃបណ្តឹងសាទុក្ខ ស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ជនជាប់ចោទមិនបានចូលរួមនាពេលសវនាការនេះទេ ប៉ុន្តែដោយអនុលោមតាមមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចជំនុំជម្រះបាន។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០៦ "ក្រVបស" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវតាមគតិច្បាប់។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៨១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ជនជាប់ចោទឈ្មោ[redacted]

២-បដិសេធសេចក្តីសម្រេចនៃសាលដីកាព្រហ្មទណ្ឌលេខ ០៦ "ក្រVបស" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ដែលសម្រេចតម្កល់ចំណុច

ទី១.គ- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] នៃសាលក្រមព្រហ្មទណ្ឌលេខ ៦២ (ខ) ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពត។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២៤៦ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីធ្វើការជំនុំជម្រះជាថ្មី លើចំណុចដែលត្រូវបដិសេធចោលតាមចំណុចទី២ ខាងលើនេះ។

៤-សាលដីកានេះ ជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ២០១៥

ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]